ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# ព្រឹត្តិបត្រប្រចាំត្រីមាស




## ត្រីមាសទី ១ និង ២

## លេខ ៤៧ ឆ្នាំ២០១៦

ចេញផ្សាយតាមប្រកាសលេខ ឆ៦-០១១-១២៣ ប្រ.ក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១

បោះពុម្ពផ្សាយដោយ

# ធនាគារជាតិ នៃ កម្ពុជា

| | | |
|---|---|---|
| អាសយដ្ឋាន | : | ២២-២៤ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា |
| ប្រអប់សំបុត្រ | : | ២៥ |
| ទូរស័ព្ទ | : | (៨៥៥) ២៣ ៧២២ ៥៦៣ |
| ទូរសារ | : | (៨៥៥) ២៣ ៤២៦ ១១៧ |
| គេហទំព័រ | : | www.nbc.org.kh |

*********

Published by

# National Bank of Cambodia

| | | |
|---|---|---|
| Address | : | 22-24 Preah Norodom Blvd.<br>Phnom Penh, Cambodia |
| P.O.BOX | : | 25 |
| Phone | : | (855) 23 722 563 |
| FAX | : | (855) 23 426 117 |
| Website | : | www.nbc.org.kh |

គណៈកម្មការព្រឹត្តិបត្រ

- ឯកឧត្តម ថា យ៉ាវ ប្រធាន
- ឯកឧត្តម ស៊ុំ សន្និសិទ្ធ និពន្ធនាយក

Review Commission

- H.E. Tha Yao — Chairman
- H.E. Dr. Sum Sannisith — Chief Editor

# អារម្ភកថា



## ឯកឧត្តម ជា ចាន់តូ
## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ប្រិយមិត្តអ្នកអានជាទីមេត្រី !**

ធនាគារជាតិនៃកម្ពុជាមានកិត្តិយសសូមផ្សព្វផ្សាយព្រឹត្តិបត្រប្រចាំត្រីមាសទី១ និងទី២ ឆ្នាំ២០១៦ ដើម្បីផ្តល់ជូនដល់សាធារណជននូវព័ត៌មានថ្មីៗអំពីស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធធនាគារកម្ពុជា និងការបំពេញមុខងារ និងតួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធររូបិយវត្ថុ និងជាអាណាព្យាបាលលើប្រព័ន្ធធនាគារកម្ពុជា។

នៅក្នុងព្រឹត្តិបត្រនេះ មានរាប់បញ្ចូលព័ត៌មានអំពីសកម្មភាពរបស់ធនាគារជាតិនៃកម្ពុជាក្នុងការរៀបចំវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពរបស់មន្ត្រីបុគ្គលិក និងការសហការជាមួយមជ្ឈមណ្ឌលស៊ាសិនក្នុងការរួមចំណែកពង្រឹងសមត្ថភាពរបស់មន្ត្រីធនាគារកណ្តាលក្នុងតំបន់ និងព័ត៌មានអំពីព្រឹត្តិការណ៍សំខាន់ពាក់ព័ន្ធនឹងវិស័យធនាគារ ដូចជាការរៀបចំសន្និសីទជាតិ ស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា កាលពីខែមីនាកន្លងទៅ ។ បន្ថែមលើនេះ ព្រឹត្តិបត្រលេខ៤៧នេះ ក៏បានបញ្ចូលនូវអត្ថបទស្រាវជ្រាវដោយមន្ត្រីបុគ្គលិកនៃនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជាអំពីកម្រិតសមស្របក្នុងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជាផងដែរ ដើម្បីឱ្យសាធារណជនទទួលបាននូវចំណេះដឹងបន្ថែមអំពីការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ។ ក្រៅពីនេះ ព្រឹត្តិបត្រលើកនេះមានបញ្ចូលនូវព័ត៌មានសំខាន់ៗអំពីស្ថានភាពបច្ចុប្បន្នរបស់ប្រព័ន្ធធនាគារ រួមមាន៖ អត្រាប្តូរប្រាក់ អត្រាការប្រាក់ ចំនួនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងសកម្មភាពនានារបស់ធនាគារជាតិនៃកម្ពុជាក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

**ប្រិយមិត្តអ្នកអានជាទីមេត្រី !**

នៅឆមាសទី១ ឆ្នាំ២០១៦ នេះ សេដ្ឋកិច្ចសកលបន្តងើបឡើងក្នុងល្បឿនយឺតនិងមិនស្មើសាច់ ដែលបណ្តាលមកពីសេដ្ឋកិច្ចនៃបណ្តាប្រទេសអាស៊ី ជាពិសេស ប្រទេសចិន ខណៈសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍បន្តងើបឡើងសន្សឹមៗ ។ កំណើនយឺតនៃសេដ្ឋកិច្ចសកលក្នុងឆមាសទី១នេះ គឺដោយសារការទទួលរងផលប៉ះពាល់ពី៖ i/- ភាពមិនច្បាស់លាស់នៃការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលអាមេរិក ii/- ការ

បោះឆ្នោតចាកចេញពីសហភាពអឺរ៉ុបរបស់ប្រទេសអង់គ្លេស (Brexit) iii/- ការថមថយកំណើនសេដ្ឋកិច្ចចិន និង iv/- ភាពមិនច្បាស់លាស់នៃស្ថានភាពទីផ្សារហិរញ្ញវត្ថុសកល ។

ក្នុងអំឡុងពេលនេះ សេដ្ឋកិច្ចកម្ពុជាក៏បានទទួលរងនូវផលប៉ះពាល់មួយចំនួនពីភាពមិនច្បាស់លាស់នៃកំណើនសេដ្ឋកិច្ចពិភពលោក ដែលបង្កឱ្យមានការថមថយកំណើនក្នុងវិស័យទេសចរណ៍ ។ ទន្ទឹមនេះ កត្តាអាកាសធាតុក៏បានពន្យារផលិតកម្មក្នុងវិស័យកសិកម្ម ។ ទោះជាយ៉ាងនេះក្តី វិស័យកាត់ដេរសម្លៀកបំពាក់ និងអចលនទ្រព្យ និងសំណង់ បន្តជំរុញកំណើនសេដ្ឋកិច្ចក្នុងឆមាសទី១ ឆ្នាំ២០១៦ ។ សម្រាប់គ្រាបន្ទាប់ កំណើនត្រូវបានរំពឹងថានៅតែមានភាពរឹងមាំ ដែលគាំទ្រដោយវិស័យកាត់ដេរសម្លៀកបំពាក់ អចលនទ្រព្យ និងសំណង់ និងកសិកម្ម ដោយសារការរំពឹងទុកពីការបន្តងើបឡើងនៃសេដ្ឋកិច្ចសកល និងការវិលមករកភាពប្រក្រតីនៃអាកាសធាតុ ។

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅតែមានស្ថិរភាពល្អ ជាមួយនឹងអត្រាអតិផរណាស្ថិតក្នុងកម្រិតទាបប្រមាណ ៣% ហើយអត្រាប្តូរប្រាក់ត្រូវបានរក្សាឱ្យមានស្ថិរភាពនៅកម្រិត ៤.០៤៤រៀលក្នុងមួយដុល្លារអាមេរិក ដែលស្របតាមមូលដ្ឋាននៃសេដ្ឋកិច្ច ។ ធនាគារជាតិនៃកម្ពុជាបានតាមដានយ៉ាងយកចិត្តទុកដាក់លើបម្រែបម្រួលនៃអត្រាប្តូរប្រាក់នៅលើទីផ្សារ ខណៈដែលប្រាក់ដុល្លារអាមេរិកកំពុងប្រែប្រួលដោយសារភាពមិនច្បាស់លាស់នៃគោលនយោបាយធនាគារកណ្តាលអាមេរិកនិងការធ្លាក់ថ្លៃទំនិញពាណិជ្ជកម្មសកល ។ ធនាគារជាតិនៃកម្ពុជាបានគ្រប់គ្រងបរិមាណផ្គត់ផ្គង់រូបិយវត្ថុយ៉ាងប្រុងប្រយ័ត្ននិងមានភាពបត់បែន ស្របតាមបម្រែបម្រួលតម្រូវការរូបិយវត្ថុក្នុងស្រុក និងស្ថានភាពទីផ្សារអន្តរជាតិ ។

ចំពោះវិស័យធនាគារវិញនៅតែមានភាពរឹងមាំល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតល្អប្រសើរនៃសូចនាករស្ថិរភាពហិរញ្ញវត្ថុ ។ ធនាគារជាតិនៃកម្ពុជាបានត្រួតពិនិត្យលើឯកសារ និងចុះត្រួតពិនិត្យដល់ទីកន្លែងជាទៀងទាត់លើគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ដើម្បីធានាឱ្យបាននូវប្រតិបត្តិការប្រកបដោយភាពរលូន និងអនុលោមតាមបទប្បញ្ញត្តិបានខ្ជាប់ខ្ជួន ។ ក្នុងពេលជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ឱ្យអនុវត្តវិធានការម៉ាក្រូប្រុងប្រយ័ត្ន ដើម្បីបង្កើនភាពរឹងមាំក្នុងប្រព័ន្ធធនាគារទាំងមូល ស្របតាមស្តង់ដាអន្តរជាតិ ។

សមិទ្ធផលដែលសម្រេចបានក្នុងវិស័យធនាគារកន្លងមក គឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្ម និងមោះមុតរបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ និងភាគីពាក់ព័ន្ធនានា ។ ដូច្នេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា និងភាគីពាក់ព័ន្ធទាំងអស់ក្នុងការបន្តខិតខំប្រឹងប្រែងរួមចំណែកអភិវឌ្ឍវិស័យធនាគារ សំដៅរួមចំណែកដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន ។

ជាចុងក្រោយ ខ្ញុំសង្ឃឹមថាព្រឹត្តិបត្រនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រិយមិត្តអ្នកអានទាំងអស់ឱ្យទទួលបាននូវព័ត៌មានអំពីបច្ចុប្បន្នភាពនៃការអភិវឌ្ឍវិស័យធនាគារ និងការរួមចំណែករបស់ធនាគារជាតិនៃកម្ពុជាក្នុងការគាំទ្រ និងជំរុញកំណើនសេដ្ឋកិច្ចឱ្យបន្តរីកចម្រើន ប្រកបដោយចីរភាព បរិយាប័ន្ន និងសមភាព ។

**សូមអរគុណ!**

# មាតិកា

ទំព័រ


➢ អារម្ភកថា ........................................................................................................ i-ii

➢ សុន្ទរកថា ឯកឧត្តម ទេសាភិបាល និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក្នុងពិធីបើកកិច្ចប្រជុំក្រុមការងារវាយតម្លៃអញ្ញមញ្ញរបស់ APG (ជាភាសាខ្មែរ និងអង់គ្លេស)........................................................ ១

➢ សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងពិធីសម្ពោធធនាគារស្ថាបនា ភីអិលស៊ី (ជាភាសាខ្មែរ)........................................................................ ៥

➢ សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងពិធីបើកវគ្គបណ្តុះ បណ្តាលស្តីពីប្រព័ន្ធទូទាត់និងធនាគារ (ជាភាសាអង់គ្លេស)............................... ៨

➢ សុន្ទរកថា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាថ្លែងក្នុងពិធីបើកសន្និសីទជាតិស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ នៅកម្ពុជា (ជាភាសាខ្មែរ).................................................................................................... ១១

➢ សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុង ឱកាសប្រារព្ធពិធីបើកនិងបិទសន្និសីទជាតិ ស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា (ជាភាសាខ្មែរ). ១៦

➢ សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងជាប្រធាន គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ថ្លែងក្នុងឱកាសបើកកិច្ចប្រជុំក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥ (ជាភាសាខ្មែរ)........................................................................................ ២៥

➢ សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ប្រធានក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្នុងពិធីសិក្ខាសាលាស្តីពីការត្រៀមទទួលការវាយតម្លៃអញ្ញមញ្ញ និងការវាយតម្លៃហានិភ័យការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មថ្នាក់ជាតិ (ជាភាសាខ្មែរ និងអង់គ្លេស)................ ២៧

- សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជាថ្លែងក្នុងឱកាស បើកសិក្ខាសាលា NBC-IMF ស្តីពីសមាហរណកម្មស្ថិតិម៉ាក្រូសេដ្ឋកិច្ចនិងវិធីសាស្ត្រ តារាងតុល្យការសម្រាប់ធ្វើការសម្រេចចិត្តសេដ្ឋកិច្ចល្អប្រសើរ(ជាភាសាអង់គ្លេស)...................... ២៩
- អត្ថបទស្រាវជ្រាវ ស្តីពីកម្រិតសមស្របក្នុងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ របស់ធនាគារជាតិនៃកម្ពុជា (ភាសាខ្មែរ)........................................................................................ ៣១
- តារាងអត្រាប្តូរប្រាក់ប្រចាំខែ (ភាសាខ្មែរនិងអង់គ្លេស) .................................................. ៥២
- តារាងអត្រាការប្រាក់លើប្រាក់បញ្ញើ (ភាសាខ្មែរនិងអង់គ្លេស) ........................................ ៥៤
- តារាងអត្រាការប្រាក់លើប្រាក់កម្ចី (ភាសាខ្មែរនិងអង់គ្លេស)............................................ ៥៦
- បញ្ជីឈ្មោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (ជាភាសាខ្មែរនិងអង់គ្លេស) ............................ ៥៨
- បញ្ជីឈ្មោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង NGO (ជាភាសាខ្មែរនិងអង់គ្លេស) ........................ ៦៤
- ប្រព័ន្ធធនាគារកម្ពុជា (ភាសាខ្មែរនិងអង់គ្លេស) .......................................................... ៧៥
- រូបថតសកម្មភាពថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា...................................................... ៧៧-៩២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.................................................

## សុន្ទរកថា
## ឯកឧត្តម ទេសាភិបាលនិងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
## ក្នុងពិធីបើកកិច្ចប្រជុំជាមួយក្រុមការងារវាយតម្លៃអញ្ញមញ្ញរបស់ APG

នៅថ្ងៃទី២៣-២៥ ខែសីហា ឆ្នាំ២០១៦

**ខ្ញុំសូមគោរព**!

- **លោក Eliot Kennedy ឧបការីលេខាធិការដ្ឋាន APG ជាទីគោរព!**
- **លោកស្រី Mitali Tyagi នាយកផ្នែកជំនួយបច្ចេកទេសនិងការបណ្តុះបណ្តាលនៃ APG!**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិកនៃអង្គប្រជុំជាទីមេត្រី!**

ថ្ងៃនេះ មានសេចក្តីសោមនស្សរីករាយដែលបានចូលរួមក្នុងពិធីបើកកិច្ចប្រជុំដំបូងរវាងក្រុមការងារចម្រុះវាយតម្លៃអញ្ញមញ្ញស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មជាមួយក្រុមការងារវាយតម្លៃរបស់ APG ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលេខាធិការដ្ឋាន APG ដែលបានផ្តល់ការគាំទ្រយ៉ាងច្រើនមកដល់កម្ពុជានាពេលកន្លងមក និងសូមអរគុណចំពោះអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលបានខិតខំពុះពារជំរុញការងារ និងក្រុមការងារចម្រុះអន្តរក្រសួង ដែលបានសហការគ្នាយ៉ាងល្អក្នុងការបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី**!

មុននឹងចាប់ផ្តើមពិធីបើកកិច្ចប្រជុំរបស់យើង ខ្ញុំសូមបញ្ជាក់ជូន ឯកឧត្តម លោកជំទាវ លោក លោកស្រីថា រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ និងប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញតាមឧត្តមានុវត្តប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រហូតសម្រេចបានសមិទ្ធផលការងារជាច្រើនគួរឲ្យកត់សម្គាល់ ហើយខ្ញុំសូមការអនុញ្ញាតពីអង្គប្រជុំជម្រាបជូនអំពីសាវតា និងសមិទ្ធផលការងារទាំងនេះ ។

ប្រទេសកម្ពុជាយើងធ្លាប់ទទួលរងការវាយតម្លៃអញ្ញមញ្ញពី APG ម្តងរួចមកហើយកាលពីដើមឆ្នាំ២០០៧ ហើយនៅពេលនោះ គឺយើងពុំទទួលបានលទ្ធផលល្អទេ ដោយសារខ្វះខាតមូលដ្ឋានច្បាប់ និងយន្តការអនុវត្តច្បាប់គ្រប់គ្រាន់សម្រាប់ប្រឆាំងនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មស្រប តាមស្តង់ដាររបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ។

ចាប់តាំងពីពេលនោះមក រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេច

អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការរៀបចំឲ្យមានយុទ្ធសាស្ត្រជាតិ ក៏ដូចជាពង្រឹងក្របខ័ណ្ឌគតិយុត្ត ដោយបានដាក់ឲ្យប្រើប្រាស់និងធ្វើវិសោធនកម្មច្បាប់គោលសំខាន់ៗ និងដាក់ចេញលិខិតបទដ្ឋានគតិយុត្តព្រមទាំងបានប្រគល់ភារកិច្ចជូនគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឲ្យតាមដានការអនុវត្តច្បាប់និងបទប្បញ្ញត្តិទាំងនេះ និងកិច្ចសហប្រតិបត្តិការក្នុងស្រុកនិងអន្តរជាតិឲ្យមានប្រសិទ្ធភាពខ្ពស់ ។ សមិទ្ធផលការងារខាងលើនេះបានឆ្លើយតបនឹងតម្រូវការជាមូលដ្ឋានរបស់ FATF រហូតធ្វើឲ្យអង្គការអន្តរជាតិនេះដកប្រទេសកម្ពុជាចេញពីបញ្ជីប្រផេះ និងបានធ្វើឲ្យប្រទេសកម្ពុជាយើងក្លាយជាសមាជិករបស់ក្រុម Egmont ថែមទៀត ។ ទោះបីជាសម្រេចបានសមិទ្ធផលការងារជាទីមោទនៈទាំងនេះក៏ដោយ ក៏រាជរដ្ឋាភិបាលនៅតែបន្តការយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងបន្តទៀត ជាពិសេសលើការងារកិច្ចសហការជាមួយសហគមន៍អន្តរជាតិក្នុងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មទាំងទ្វេភាគី និងពហុភាគី ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ជាការកត់សម្គាល់ ការវាយតម្លៃលើកនេះនឹងផ្តោតលើការអនុវត្តតាមបច្ចេកទេស (Technical Compliance) ផង និងប្រសិទ្ធភាពនៃការអនុវត្ត (Effectiveness) ផង ដែលមានការលំបាក និងប្រទាក់ក្រឡាជាងការវាយតម្លៃលើកមុន ដែលតម្រូវឲ្យយើងត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់ ។ ដូច្នេះ កិច្ចប្រជុំរយៈពេល ៣ថ្ងៃ នេះ ក្រុមវាយតម្លៃនឹងប្រមូលព័ត៌មាន និងពិភាក្សាបន្ថែមលើចម្លើយដែលយើងបានផ្តល់ឲ្យនាពេលកន្លងមក ។

ដូច្នេះខ្ញុំសូមស្នើឲ្យ ឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាបន្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីសម្រេចតាមយុទ្ធសាស្ត្រ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការរួមចំណែកទប់ស្កាត់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងផ្តល់កិច្ចសហការល្អដល់ក្រុមវាយតម្លៃរបស់ APG ដើម្បីឲ្យដំណើរការវាយតម្លៃនេះទទួលបានជោគជ័យ ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរចំពោះគណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់សូមជួបនូវពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបើកកិច្ចប្រជុំជាមួយក្រុមវាយតម្លៃអញ្ញមញ្ញចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number.............................................................................

## Remarks by
## His Excellency Chea Chanto, Governor of National Bank of Cambodia and Chairman of the National Coordination Committee on Anti-Money Laundering and Combating the Financing of Terrorism on the Opening of APG Pre-Mutual Evaluation Meeting

23-25 August, 2016

- Mr. Eliot Kennedy, Assistant Executive Secretary, APG Secretariat
- Mrs. Mitali Tyagi, Director of Technical Assistance and Training APG Secretariat,
- Excellencies, Distinguished Guests, Ladies and Gentlemen

Today, I have a great pleasure to attend the opening of the Pre-Mutual Evaluation Meeting on Anti-Money Laundering and Combating the Financing of Terrorism (AML/CFT) with Cambodia's inter-ministries Working Group and APG Assessment team. I would like to express my sincere thank to APG Secretariat for having been providing support to Cambodia thus far. I also thank CAFIU for their hard work to keep pushing for continuous progress of these work, and our inter-ministries Working Group for the good cooperation to fulfill their obligations in a very responsible manner.

**Excellencies, Distinguished Guests, Ladies and Gentlemen!**

Before announcing the opening of the meeting, I would like to inform Excellencies, Distinguished Guests, Ladies and Gentlemen that the Royal Government of Cambodia has paid high attention and made strong commitment to follow the best practices on AML/CFT, which result in many remarkable achievements to date. I would like to take this opportunity to brief you on the background of these achievements.

Cambodia underwent the Mutual Evaluation by APG at the beginning of 2007 and, at that time, the evaluation result was not good due to lacks of legal basis and

enforcement mechanism in AML/CFT to be compliant with Financial Action Task Force (FATF) standards.

Since then, the Royal Government of Cambodia under the wise leadership of Samdech Akka Moha Sena Padei Techo **Hun Sen**, the Prime Minister of the Kingdom of Cambodia, has put great effort through the adoption and amendments in issuing the National Strategy as well as strengthening the legal framework, key laws and issuing on legislative regulations, by entrusting the National Coordination Committee on AML/CFT with the responsibility to effectively review the implementation of the laws and regulations and coordinate domestic and international cooperation.

The achievements met the FATF basic requirements of so that the international organizations decided to remove Cambodia from the Grey list and that also made Cambodia become a member of Egmont Group. In spite of having accomplished these achievements, the Royal Government of Cambodia still continuously pays great attention and efforts to foster bilateral and multilateral cooperation with international communities.

**Excellencies, Distinguished Guests, Ladies and Gentlemen!**

It was noted that this evaluation will focus on both Technical Compliance and Effectiveness, which will be more complicated and require further attention. During this 3-day meeting, the Assessment team will collect extra information and discuss on the responses that we have provided earlier.

Therefore, I would like to ask for your continuous efforts to implement the national strategy and fulfill the commitment of the Royal Government of Cambodia to prevent Money Laundering and Terrorism Financing activities and to proactively cooperate with the APG assessment team for a successful evaluation process.

Last but not least, I wish Excellencies, Distinguished guests, Ladies and Gentlemen with the four gems of Buddhist blessings of longevity, nobility, health and strength.

I hereby declare the Opening of the Pre-Mutual Evaluation meeting.

Thank you!

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ......................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីសម្ពោធ ធនាគារ ស្ថាបនា ភីអិលស៊ី
រាជធានីភ្នំពេញ , ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦

**សូមគោរព៖**

- **ឯកឧត្តម Kumamaru Yuji ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
- **បណ្ឌិត ហាន់ ចាងវូ ប្រធានក្រុមប្រឹក្សាភិបាល ធនាគារ ស្ថាបនា ភីអិលស៊ី**
- **លោកឧកញ៉ាបណ្ឌិត ប៊ុន មុនី ប្រធាននាយកប្រតិបត្តិ ធនាគារ ស្ថាបនា ភីអិលស៊ី**
- **ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសជាទីមេត្រី!**

ក្នុងឱកាសដ៏ឱឡារិកនេះ ខ្ញុំមានសេចក្ដីសោមនស្សរីករាយជាអនេក ដោយបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ក្នុងពិធីសម្ពោធ ធនាគារ ស្ថាបនា ភីអិលស៊ី ដែលជាគ្រឹះស្ថានធនាគារពាណិជ្ជថ្មីមួយ តាមរយៈការបញ្ចូលគ្នា រវាងគ្រឹះស្ថាន ម៉ារ៉ូហាន់ ធនាគារ ជប៉ុន ភីអិលស៊ី និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនា លីមីតធីត ។ ការរួមបញ្ចូលគ្នា រវាងគ្រឹះស្ថានទាំងពីរនឹងធ្វើឲ្យគ្រឹះស្ថានថ្មីមានភាពកាន់តែសកម្ម និងរឹងមាំ ទន្ទឹមនឹង ការរីកចម្រើនទាំងទំហំនិងវិសាលភាពប្រតិបត្តិការ ហើយនឹងធ្វើឲ្យវិស័យធនាគារនៅកម្ពុជា កាន់តែមានភាពរឹងមាំបន្ថែមមួយកម្រិតទៀត ។ គ្រឹះស្ថាន ម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអិលស៊ី បានចាប់ផ្ដើមវិនិយោគក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត ដោយទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា នៅឆ្នាំ២០១២ ។

ការសម្ពោធដាក់ឲ្យដំណើរការធនាគារថ្មីនេះក៏បានបង្ហាញពីឆន្ទៈនិងការខិតខំប្រឹងប្រែងពីសំណាក់ភាគទុនិក គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ របស់ធនាគារក្នុងការពង្រឹងនិងពង្រីកប្រតិបត្តិការ របស់ខ្លួនឲ្យកាន់តែសម្បូរបែប និងទូលំទូលាយ ដើម្បីចូលរួមចំណែកគាំទ្រដល់គោលនយោបាយ របស់រាជរដ្ឋាភិបាលលើការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា ។ ធនាគារ ស្ថាបនា ភីអិលស៊ី នឹងចាប់ផ្ដើម ធ្វើប្រតិបត្តិការដោយមានដើមទុនចុះបញ្ជីក្នុងកម្រិតខ្ពស់ជាងការកំណត់នៃបទប្បញ្ញត្តិ និងជួយឲ្យធនាគារមានលទ្ធភាពច្រើន ក្នុងការផ្ដល់សេវាធនាគារឲ្យកាន់តែមានភាពងាយស្រួល ឆាប់រហ័ស

ផលិតផលហិរញ្ញវត្ថុសម្បូរបែប ភាពប្រកួតប្រជែង និងចូលរួមចំណែកក្នុងការបង្កើនប្រសិទ្ធភាព សុវត្ថិភាព និងបង្កើនជំនឿទុកចិត្ត របស់សាធារណជនមកលើវិស័យធនាគារ ។

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសជាទីមេត្រី!**

សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៦ ត្រូវបានប៉ាន់ស្មានថានឹងបន្តមានកំណើនរឹងមាំក្នុងរង្វង់ ៧% ដែលគាំទ្រដោយកំណើននៃការនាំចេញផលិតផលវាយនភ័ណ្ឌ ការធ្លាក់ចុះនៃថ្លៃប្រេង និងកំណើនតម្រូវការក្នុងស្រុក ជាពិសេស វិស័យសំណង់ អចលនទ្រព្យ និងការប្រើប្រាស់ ។ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចបន្តមានស្ថិរភាពល្អប្រសើរដោយអតិផរណាបន្តមានកម្រិតទាបក្រោម ៣% និងអត្រាប្តូរប្រាក់មានស្ថិរភាព ។ ទំហំទ្រព្យសកម្មក្នុងប្រព័ន្ធធនាគារគិតត្រឹម ចុងឆ្នាំ២០១៥ បានកើនឡើងដល់ប្រមាណ ២០ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ១០៧% នៃផលិតផលក្នុងស្រុកសរុប ខណៈដែលប្រាក់បញ្ញើរបស់អតិថិជន និងឥណទានទៅវិស័យឯកជនបានកើនឡើងដល់ ១១,៤៤ និង ១១,៦២ ប៊ីលានដុល្លារអាមេរិក រៀងគ្នា ។ ទន្ទឹមនេះ វិស័យធនាគារ ក៏កំពុងចូលរួមចំណែកយ៉ាងខ្លាំងក្លាក្នុងការជម្រុញបរិយាប័ន្នហិរញ្ញវត្ថុដើម្បីបង្កើនប្រសិទ្ធភាពអាជីវកម្ម បង្កើតឱកាសការងារដល់ប្រជាពលរដ្ឋនៅតាមជនបទ និងកាត់បន្ថយគម្លាតចំណូលនិងភាពក្រីក្រ ។ របាយការណ៍ថ្មីៗនេះបានបង្ហាញថា ប្រជាជនកម្ពុជាដែលមានអាយុពេញវ័យប្រមាណ ៥១% បានទទួលសេវាហិរញ្ញវត្ថុផ្លូវការធៀបនឹង ៨,៧% កាលពី ១០ឆ្នាំមុន ។

សមិទ្ធផលដ៏ថ្លៃថ្លាដែលមានអត្ថន័យជាប្រវត្តិសាស្ត្រនេះ កើតឡើងពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការធានាបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ និងភាពជោគជ័យនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាបន្តបន្ទាប់ ។

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសជាទីមេត្រី!**

កាលពីថ្ងៃទី១៤-១៥ ខែមីនា ឆ្នាំ២០១៦ កន្លងមក ដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និសីទជាតិស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដើម្បីវាយតម្លៃពីតួនាទីនិងទិសដៅអនាគតរបស់វិស័យមីក្រូហិរញ្ញវត្ថុ ។ ជាលទ្ធផល អង្គសន្និសីទបានវាយតម្លៃខ្ពស់ជាវិជ្ជមាន ចំពោះតួនាទីរបស់វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ ដែលជាយុទ្ធសាស្ត្រអាទិភាពរបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនេះ ដើម្បីអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុឲ្យកាន់តែរីកចម្រើនបន្ថែមទៀត សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានផ្តល់អនុសាសន៍ចំនួនប្រាំដែលមានខ្លឹមសារសំខាន់ៗសម្រាប់ធនាគារជាតិនៃកម្ពុជាអនុវត្តបន្ត រួមមាន ៖

១- ដាក់ចេញនូវក្របខ័ណ្ឌបទប្បញ្ញត្តិ និងការត្រួតពិនិត្យព្រមទាំងការពង្រឹងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍន៍ធនធានមនុស្សឲ្យប្រកបដោយវិជ្ជាជីវៈ

២- ជម្រុញសេវាមីក្រូហិរញ្ញវត្ថុចូលរួមចំណែកផ្តល់ឥណទានដល់សហគមន៍កសិកម្ម និងសហគ្រាសធុនតូចនិងមធ្យម

៣- រៀបចំនូវគោលនយោបាយ ឬ យុទ្ធសាស្ត្រលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងកិច្ចគាំពារអតិថិជន

៤- សហការជាមួយក្រសួងពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និង

៥- រៀបចំកម្មវិធីសិក្ខាសាលា និងវេទិកាថ្នាក់តំបន់ និងថ្នាក់ជាតិ ដើម្បីផ្សព្វផ្សាយជូនសាធារណជនឲ្យជ្រួតជ្រាបបន្ថែមទៀតអំពីប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ និងហានិភ័យផ្សេងៗដែលអាចកើតឡើងពីការប្រើប្រាស់សេវាហិរញ្ញវត្ថុនេះ ។

សរុបមក ការរីកចម្រើននេះ នឹងធ្វើឲ្យវិស័យមីក្រូហិរញ្ញវត្ថុទទួលបាននូវការចាប់អារម្មណ៍ខ្ពស់ របស់វិនិយោគិននានា ដូចជា ម៉ារ៉ូហាន់ ធនាគារជប៉ុន ជាដើម ។ ខ្ញុំសង្ឃឹមដ៏មុតមាំថា ធនាគារស្ថាបនា ភីអិលស៊ី នឹងចូលរួមអនុវត្តតាមអនុសាសន៍ក្នុងការពង្រឹងការផ្តល់សេវាហិរញ្ញវត្ថុដល់សហគមន៍ កសិកម្ម និង សហគ្រាសធនតូចនិងមធ្យម ក៏ដូចជា ពង្រឹងកិច្ចការពារអតិថិជន និងការផ្តល់សេវា ហិរញ្ញវត្ថុកាន់តែមានការរីកចម្រើន និង ទំនើប និងចូលរួមចំណែកលើកកម្ពស់ភាពប្រកួតប្រជែងដោយ ស្មើភាព និងតម្លាភាពរវាងគ្រឹះស្ថានដែលផ្តល់សេវា និងផលិតផលធនាគារ ក្នុងនោះមានសេវាមីក្រូ ហិរញ្ញវត្ថុជាដើម ។ ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជាបានបង្កើនការយកចិត្តទុកដាក់ពង្រឹងក្របខ័ណ្ឌ បទប្បញ្ញត្តិ និងត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបន្ថែមទៀត ដើម្បីធានាបានថាគ្រឹះស្ថាន ធនាគារ និងហិរញ្ញវត្ថុនីមួយៗ និងប្រព័ន្ធធនាគារទាំងមូលមានភាពរឹងមាំ តម្លាភាព ការប្រកួតប្រជែង និងទិន្នផលខ្ពស់សំដៅបន្តគាំទ្រឥតឈប់ឈរដល់ការអភិវឌ្ឍនៃសកម្មភាពសេដ្ឋកិច្ចជាតិនិងកាត់បន្ថយ ភាពក្រីក្របន្ថែមទៀត ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរចំពោះដល់ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ សូមជួបតែពុទ្ធពរ ទាំង៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។ ខ្ញុំក៏សូមជូនពរដល់ថ្នាក់ដឹកនាំ និង បុគ្គលិកទាំងអស់របស់ធនាគារ ស្ថាបនា ភីអិលស៊ី សូមទទួលបានជោគជ័យក្នុងប្រតិបត្តិការ អាជីវកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាពជារៀងរហូត ។

**សូមអរគុណ!**

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number.................................................................

**Opening Remarks**

**by**

**His Excellency Chea Chanto, Governor of the National Bank of Cambodia, ASEAN Financial Integration Framework (AFIF) Capacity Building Course on Bank and Payment System**

**Siem Reap, 22-26 August 2016**

- **Ms. Shanty Noviantie, Senior Analyst of the SEACEN Centre**
- **Ms. Farida Peranginangin, Director of Payment System Oversight Department, Bank Indonesia**
- **Resource Speakers, Delegates, Ladies and Gentlemen,**

A Very Good Morning!

Today, on behalf of the National Bank of Cambodia, I have the great pleasure to host the ASEAN Financial Integration Framework Capacity Building Course on Bank and Payment System here in Siem Reap Province, in collaboration with the SEACEN Center, ADB, ASEC, and AADCP. I would like to warmly welcome the honorable speakers and delegates from the BCLMV central banks and monetary authorities to Cambodia, and especially to our Ancient Capital City of Angkor in Siem Reap.

Taking this opportunity, I would also like to express my sincere thanks to the SEACEN Centre and other funding partners for making this course possible. This fundamental course, I would say, is an excellent platform for participants to enhance their technical skills, learn from the resource speakers and from each other through exchange of knowledge and experiences in their respective activities. It also provides a great opportunity to socialize with each other and build a network among our BCLMV central bank family. Please enjoy the benefit of these opportunities.

- **Resource Speakers, Delegates, Ladies and Gentlemen,**

Let me briefly recall how important are payment systems and say some words about the role that every central bank commonly has in this area. We at central banks know very well that payment and settlement systems have been playing an important role in the financial system as well as in the economy. The importance of efficient payment and settlement systems can be seen through their interconnected links with monetary stability, financial stability, and economic efficiency. In the context of *monetary stability*, the links are through the transmission channels of monetary policy where money and credit are flowed in and out from the central bank to financial institutions, among financial institutions themselves in the interbank markets, and from financial institutions to their customers. Given this, we can see that a smooth functioning of payment infrastructures will help speed up the flow of funds, reduce transaction costs, and improve the liquidity management of all agents. In opposite, if the payment system is underdeveloped, financial institutions will have to hold large buffer of central bank money to help manage their liquidity and therefore lead to a weaker transmission of the monetary policy. With this, efficient payment systems positively relate to an effective conduct of monetary policy.

From the *financial stability* perspective, we know that any disruption in the financial system is likely to be first reflected in the payment system in the form of liquidity issues. In payment systems, one bank's payment is another bank's liquidity. A failure in payments by one bank can lead to a similar failure in other banks. In this case, the payment system becomes a channel through which financial risks can be transmitted across financial markets and institutions and also can create significant liquidity troubles. In other words, any disruption in payment systems could affect financial stability and lead to financial disasters.

The importance of payment systems has been increasing over time, due the rapid evolution of technology. Specifically, new technologies have brought about new innovative financial services and a growing usage of non-cash means of payment such as credit cards, debit cards, electronic money, and so on. These instruments, which are being developed not only by banks but also by non-bank institutions, have transformed the payment landscape and have now a significant implication on the conduct of monetary policy and the state of financial stability.

As central bankers, our tasks have become more complicated in oversight and development of payment systems, as the expansion in this area goes well beyond the traditional expertise of central banks. We need to be more and more pro-active to catch up with the fast innovation of technology.

Looking at the payment systems in Cambodia, we as the authority in charge of them have taken a number of initiatives in terms of operational framework, guiding principles, policies, regulation, supervision, and cooperative work with development partners, with the objective to develop a safe and efficient payment system. To achieve this objective, of course, it has been and remains a long journey which requires a continuing commitment, hard work and, in particular, ongoing capacity building and skill development as a priority. If only for this reason, I would like to stress the importance of this course on payment systems.

During this one full week course, I strongly believe that all participants will acquire very important knowledge from our resource speakers and engage in fruitful discussions and experience sharing. I have no doubt that, by the end of the course, all of you will obtain a better understanding in this essential area of central banking and will have the capacity to contribute to developing a sound and efficient payment system in your respective countries. For these reasons, once again, I would like to sincerely thank the SEACEN Centre and other development partners for their effective support and cooperation to make this course possible.

Last but not least, I was told that there will be a tour program on Tuesday in the afternoon. I hope that you will have the possibility to enjoy touring around the temple complex including Angkor Wat, which is ranked among the World's Wonders and registered as a UNESCO's world heritage site. I know you have a tight schedule in Siem Reap, but I hope you will find time to visit other interesting places, do some shopping and get to know more about our people, history and culture.

Finally, I wish you all good luck and a pleasant stay in Siem Reap. Now, let me wish you again an active and productive course!

Thank you!

សុន្ទរកថា

# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធី បើកសន្និសីទស្តីពី ការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា នៅវិមានសន្តិភាពថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០១៦

- *សម្តេច ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អង្គពិធីទាំងមូលជាទីមេត្រី !*

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយ ដោយបានមកចូលរួមក្នុងពិធីបើក ***«សន្និសីទជាតិស្តីពីការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា»*** ដែលបានប្រារព្ធឡើងនាពេលនេះ ។ គិតមកដល់ពេលនេះ គឺមានរយៈ-ពេល១០ឆ្នាំគត់ បន្ទាប់ពីសន្និសីទជាតិ ស្តីពីមីក្រូហិរញ្ញវត្ថុនៅកម្ពុជាត្រូវបានប្រារព្ធឡើងកាលពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៦ ដែលយើងបានប្រកាសថា ឆ្នាំ២០០៦ជាឆ្នាំមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ហើយពេលនេះយើងបានមកជួបជុំគ្នាជាថ្មីម្តងទៀត ដើម្បីអបអរសាទរសមិទ្ធផលដែលសម្រេចបានព្រមទាំងត្រៀមខ្លួនដោះស្រាយបញ្ហាប្រឈម ចំពោះមុខថ្មីៗទៀតក្នុងបុព្វហេតុបន្តជំរុញការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាឲ្យកាន់តែរីកចម្រើន ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងការកោតសរសើរចំពោះធនាគារជាតិនៃកម្ពុជា ដែលបានផ្តួចផ្តើមរៀបចំសន្និសីទនេះឡើង ក្នុងគោលបំណងជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិអំពីវឌ្ឍនភាពក្នុងការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក ក៏ដូចជាការបន្តពង្រឹងនូវជំនឿទុកចិត្តរបស់សាធារណជន ទូទៅមកលើប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ។ ខ្ញុំក៏សូមកោតសរសើរចំពោះធនាគារជាតិនៃកម្ពុជា និងដៃគូពាក់ព័ន្ធទាំងអស់ដែលបានរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាឲ្យមានការរីកចម្រើនយ៉ាងឆាប់រហ័ស ទាំងទំហំមូលធន និងវិសាលភាពគ្របដណ្តប់ ។

ជាក់ស្តែង វិស័យធនាគារនៅកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកៀរគរប្រាក់សន្សំរបស់សាធារណជន និងប្រភពទុនផ្សេងៗទៀតនៅក្នុងទីផ្សារអន្តរជាតិមកចាក់បញ្ចូលក្នុងសេដ្ឋកិច្ចជាតិតាមរយៈការផ្តល់ហិរញ្ញប្បទាននិងឥណទានដល់ការវិនិយោគនានា ពិសេស ដល់វិស័យផលិតកម្មនៃសហគ្រាសធុនតូច និងមធ្យម ដែលជាការជួយបង្កើនសមត្ថភាពផលិតកម្ម ការធ្វើទំនើបកម្មផលិតកម្ម ការធ្វើពិពិធកម្មផលិតកម្ម និងការលើកកម្ពស់ស្តង់ដារផលិតផលកម្ពុជា ដែលជាការរួមចំណែកបង្កើននូវប្រសិទ្ធភាពសេដ្ឋកិច្ចបន្ថែមទៀត ប្រសិនបើប្រជាជនទូទាំងប្រទេសបានចូលរួមប្រើប្រាស់សេវានេះកាន់តែច្រើនដូចដែលអង្គការសហប្រជាជាតិបានទទួលស្គាល់ថា ***«លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុក្នុងតម្លៃ សមរម្យ ដោយប្រជាជនដែលមានចំណូលទាប និងនៅតំបន់ជនបទ គឺមានសារសំខាន់ណាស់ដើម្បីកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍសេដ្ឋកិច្ចឲ្យប្រកបដោយចិរភាព»*** ។

កន្លងមកវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបានចូលរួមចំណែកយ៉ាងខ្លាំងដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ការលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ពួកគាត់ ខណៈដែលសេវាហិរញ្ញវត្ថុបានរីករាលដាលយ៉ាងខ្លាំងនៅតាមទីជនបទ ដែលមានតម្រូវការទុនដើម្បីវិនិយោគ ។ បច្ចុប្បន្ននេះ ប្រជាជន

ពេញវ័យដែលកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការមានប្រមាណ ៥១% នៃប្រជាជនពេញវ័យសរុប ។ តួលេខនេះ បានបន្តកើនឡើងគួរឲ្យកត់សម្គាល់បើប្រៀបធៀបនឹងរយៈពេល១០ឆ្នាំមុន ។

ជាលទ្ធផល វិស័យនេះបានរួមចំណែកយ៉ាងខ្លាំងដល់ការកាត់បន្ថយអត្រាភាពក្រីក្ររបស់ប្រជាជនគម្លាតរវាងអ្នកមាននិងអ្នកក្រ និងរវាងទីក្រុងនិងជនបទ។ ក្នុងនោះ អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយជាង ១% ក្នុងមួយឆ្នាំក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដែលធ្វើឲ្យអត្រានេះ បានធ្លាក់ចុះយ៉ាងលឿនពីជាង ៥៣% ក្នុងឆ្នាំ២០០៤ មកត្រឹម ១៦% នៅឆ្នាំ២០១៣ ហើយផលិតផលក្នុងស្រុកសរុបគិតជាមធ្យមសម្រាប់មនុស្សម្នាក់បានកើនពី ៧៦០ ដុល្លារនៅឆ្នាំ២០០៨ ដល់ប្រមាណ ១.២២៥ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៥ ដែលធ្វើឲ្យកម្ពុជាកំពុងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប ។

**- *ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូល***

ក្នុងអំឡុងពេលនៃពិធីបើកសន្និសីទជាតិ ស្តីពីមីក្រូហិរញ្ញវត្ថុកម្ពុជា កាលពីឆ្នាំ២០០៦ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុសាសន៍មួយចំនួន ដើម្បីពង្រឹងប្រតិបត្តិការមីក្រូហិរញ្ញវត្ថុនៅកម្ពុជាឲ្យមានប្រសិទ្ធភាព និងសុខភាពល្អ សំដៅរួមចំណែកអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ក្នុងរយៈពេល ១០ឆ្នាំកន្លងមកនេះ ខ្ញុំសង្កេតឃើញថា វិស័យមីក្រូហិរញ្ញវត្ថុបានរីកចម្រើនគួរឲ្យកត់សម្គាល់ទាំងទំហំ និងវិសាលភាព ។ ពិតណាស់ថាការរីកចម្រើននេះក៏មិនអាចសម្រេចបានដែរ ប្រសិនបើមិនមានបរិយាកាសអំណោយផលពីកត្តាសុខសន្តិភាព ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេស ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានធ្វើឲ្យកាន់តែប្រសើរក្នុងការគ្រប់គ្រង និងអនុវត្តនូវគោលនយោបាយសារពើពន្ធរបស់រាជរដ្ឋាភិបាល ។

ជាមួយនេះ ធនាគារជាតិនៃកម្ពុជាតែងបានបន្តកែសម្រួលបទបញ្ញាប្រុងប្រយ័ត្នសម្រាប់ត្រួតពិនិត្យឲ្យស្របតាមការអភិវឌ្ឍទីផ្សារ និងបទដ្ឋានអន្តរជាតិ និងដាក់ឲ្យអនុវត្តប្រកបដោយប្រសិទ្ធភាព ។ ប្រការទាំងនេះ បាននាំឲ្យវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបន្តរីកចម្រើនគួរឲ្យកត់សម្គាល់ និងត្រូវបានទទួលស្គាល់លើឆាកអន្តរជាតិ អំពីភាពរឹងមាំ ទាំងលើផ្នែកក្របខ័ណ្ឌបទប្បញ្ញត្តិ ភាពឆ្នៃប្រឌិត និងភាពទន់ភ្លន់នៃប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាតែងបានចូលរួមក្នុងកម្មវិធីចែករំលែកបទពិសោធន៍ ស្តីពីការរៀបចំបទប្បញ្ញត្តិ និងការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ព្រមទាំងកត្តាជោគជ័យនានាដែលទទួលបានកន្លងមកដល់អាជ្ញាធរត្រួតពិនិត្យមួយចំនួនដូចជាធនាគារកណ្តាលនីហ្សេរីយ៉ា ធនាគារកណ្តាលឡាវ ធនាគារកណ្តាលវៀតណាម អាជ្ញាធរត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមីយ៉ាន់ម៉ា។ល។នេះជាមោទនភាពមួយរបស់កម្ពុជាយើងដោយឈរលើកិច្ចខិតខំប្រឹងប្រែងដោយផ្ទាល់របស់យើង ។

ទន្ទឹមនេះ ខ្ញុំសូមជំរុញលើកទឹកចិត្តឲ្យបង្កើតផលិតផលហិរញ្ញវត្ថុថ្មីៗសមស្របជាមួយតម្រូវការរបស់ប្រជាជនក្រីក្រ ។ ក្រៅពីសេវាឥណទានក្នុងនោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏ផ្តល់នូវសេវាផ្សេងៗទៀត ដូចជាសេវាប្រាក់សន្សំ សេវាផ្ទេរប្រាក់ សេវាម៉ាស៊ីនដកប្រាក់ និងដាក់ប្រាក់ស្វ័យប្រវត្តិ សេវាធានារ៉ាប់រងខ្នាតតូច និងសេវាធនាគារចល័តជាដើម ។ សេវាទាំងអស់នេះ ត្រូវបានផ្តល់ឲ្យអតិថិជនក្នុងគោលបំណងជួយសម្រួលនិងលើកកម្ពស់ស្ថានភាពហិរញ្ញវត្ថុគ្រួសារ ក៏ដូចជាអាជីវកម្មឲ្យកាន់តែប្រសើរឡើង ហើយ

ត្រូវបន្តពង្រីកបណ្តាញប្រតិបត្តិការឲ្យគ្របដណ្តប់រហូតដល់មូលដ្ឋាននៅទូទាំង ២៥ រាជធានីខេត្ត ។

ដោយឡែក ពាក់ព័ន្ធនឹងការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពធនាគារដោយពុំទាន់មានច្បាប់អនុញ្ញាត នាពេលកន្លងមកមានអង្គការមិនមែនរដ្ឋាភិបាល សមាគមនិងឈ្មួញឲ្យខ្ចីចងការប្រាក់ក្រៅប្រព័ន្ធបានចាត់ទុកខ្លួនឯងថាជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្របច្បាប់ ដោយយកអត្រាការប្រាក់កម្ចីខ្ពស់ប្រើវិធីសាស្រ្តគណនាសងប្រាក់កម្ចីមានលក្ខណៈកេងបន្លំ និងកេងប្រវ័ញ្ចនីតិវិធីនៃការខ្ចីប្រាក់មានការធូររលុង និងឆាប់រហ័សដែលកត្តាទាំងនេះបានជំរុញឲ្យប្រជាជនទទួលបានប្រាក់កម្ចីពីប្រភពទាំងនោះភាគច្រើនត្រូវជាប់បន្ទុកបំណុលវ័ន្តក និងគ្មានលទ្ធភាពសងបំណុលវិញ។ ជាលទ្ធផល ទ្រព្យបញ្ចាំដែលរួមមាន ដីធ្លី ផ្ទះសម្បែង ដីស្រែ ត្រូវបានអង្គការ សមាគម ឬឈ្មួញទាំងនោះរឹបអូស។ លើសពីនេះក៏មានគណបក្សនយោបាយ និងបុគ្គលមួយចំនួនបាន និងកំពុងកេងយកផលចំណេញផ្នែកនយោបាយដោយឃោសនាឲ្យប្រជាជនយល់ច្រឡំថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាគ្រឹះស្ថានរបស់រដ្ឋ ដូច្នេះប្រាក់ដែលខ្ចីជារបស់រដ្ឋ ហើយជំរុញឲ្យប្រជាជនខ្ចីប្រាក់មិនចាំបាច់សងប្រាក់កម្ចីនោះត្រឡប់វិញទេ ហើយថែមទាំងបានសន្យាថា បើពួកគេឈ្នះឆ្នោតនៅអាណត្តិក្រោយនោះ ពួកគេនឹងលុបចោលប្រាក់កម្ចីទាំងនោះ ។ នេះជាការបំភ្លៃការពិតជាសកម្មភាពកេងប្រវ័ញ្ចនិងបោកប្រាស់ហើយត្រូវបានបំភ្លឺព្រមទាំងថ្កោលទោសចំពោះអង្គការ សមាគម និងឈ្មួញឲ្យខ្ចីចងការប្រាក់ទាំងនោះ ឲ្យបញ្ឈប់ជាបន្ទាន់នូវសកម្មភាពបែបនេះតាមរយៈសេចក្តីថ្លែងការណ៍រួមមួយរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជាកាលពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ។

ព្រមជាមួយនេះ ធនាគារជាតិនៃកម្ពុជាកំពុងពិនិត្យលើគុណវុឌ្ឍិ ភាពត្រឹមត្រូវច្បាស់លាស់ព្រមទាំងចុះត្រួតពិនិត្យដល់ទីកន្លែងជាមុន ដើម្បីជាមូលដ្ឋានក្នុងការសម្រេចផ្តល់ ឬមិនផ្តល់អាជ្ញាប័ណ្ណ ឬចុះបញ្ជីមីក្រូហិរញ្ញវត្ថុ។ ចំពោះមុខនេះយើងឃើញថា ធនាគារជាតិនៃកម្ពុជាបានរួមចំណែកបង្កើនចំណេះដឹងលើការប្រើប្រាស់សេវាហិរញ្ញវត្ថុដល់ថ្នាក់មូលដ្ឋាន ដែលធ្វើឲ្យប្រជាជនមានការយល់ដឹងកាន់តែច្រើនក្នុងការស្វែងរកហិរញ្ញប្បទានពីធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពិសេសធ្វើឲ្យពួកគេយល់ច្បាស់ថា មីក្រូហិរញ្ញវត្ថុពុំមែនជាសកម្មភាពសប្បុរសធម៌ទេ។ ជាលទ្ធផលគួឲ្យកត់សម្គាល់មួយទៀតគឺ អត្រាការប្រាក់ឥណទានប្រចាំឆ្នាំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមាននិន្នាការ ថយចុះជាបន្តបន្ទាប់ក្នុងរយៈពេលកន្លងមកដោយបានថយចុះពី ៣៦%ក្នុងឆ្នាំ២០០៦ មក ៣២%ក្នុងឆ្នាំ២០០៩ បានថយចុះ២៧,៥% ក្នុងឆ្នាំ២០១២ និងរហូតដល់ ២៣,៧% ក្នុងឆ្នាំ២០១៥ ហើយរំពឹងថានឹងថយចុះបន្តបន្ទាប់ទៀត ។ ការថយចុះនេះ គឺបណ្តាលមកពីការអនុវត្តន៍យន្តការទីផ្សារដែលលើកទឹកចិត្តឲ្យមានការប្រកួតប្រជែងដោយតម្លាភាព សំដៅពង្រឹងគុណភាពនៃសេវានិងផលិតផលហិរញ្ញវត្ថុ ។

សរុបមក ខ្ញុំកត់សម្គាល់ឃើញថា មានកត្តាសំខាន់ចំនួន ៤ ដែលជាកត្តាពន្លឿនកំណើនវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាក្នុងនោះមាន*(១)*.គោលនយោបាយគាំពារនិងលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ***(២)***.ក្របខណ្ឌបទប្បញ្ញត្តិនិងការត្រួតពិនិត្យដោយប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា ***(៣)***. ភាពរស់រវើកនិងការឆ្នៃប្រឌិត របស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និង ***(៤)***.តម្រូវការនិងការគាំទ្ររបស់អតិថិជនដោយយល់ឃើញពីសារៈសំខាន់ នៃវិស័យមីក្រូហិរញ្ញវត្ថុក្នុងការជំរុញបរិយាប័ន្នហិរញ្ញវត្ថុ ។

- *ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គពិធីទាំងមូល*

ខ្ញុំសូមបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងបន្តខិតខំប្រឹងប្រែងយ៉ាងពេញទំហឹង ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុទន្ទឹមគ្នានិងការជំរុញអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុនិយាយជារួម និងវិស័យមីក្រូហិរញ្ញវត្ថុ និយាយដោយឡែកដើម្បីចូលរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិតាមរយៈការដាក់ចេញនូវវិធានការគោលនយោបាយនិងការបង្កនូវបរិស្ថានអំណោយផលដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិជាពិសេស ការបន្តប្រកាន់ខ្ជាប់នូវគោលការណ៍គ្រឹះនៃសេដ្ឋកិច្ចទីផ្សារនិងការប្រកួតប្រជែងដោយស្មើភាព។ ជាក់ស្តែងកម្ពុជាបានអនុម័តជាបន្តបន្ទាប់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ក្នុងនោះ ***«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០»*** បានផ្តោតសំខាន់លើការអភិវឌ្ឍន៍ និងការបង្កើតក្របខ័ណ្ឌច្បាប់ចំពោះវិស័យមីក្រូហិរញ្ញវត្ថុក្នុងការកេណ្ឌប្រមូល និងបែងចែកធនធានដើម្បីលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុសំដៅទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។

ដោយឡែកសម្រាប់អង្គសន្និសីទថ្ងៃនេះ យើងមិនត្រឹមតែលើកឡើងពីភាពជឿនលឿននៃវិស័យមីក្រូហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកយកបញ្ហាប្រឈម តួនាទី និងការធ្វើអន្តរការីយកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុព្រម ទាំងតួនាទីរបស់រាជរដ្ឋាភិបាល ពិសេសអាជ្ញាធរពាក់ព័ន្ធនានាក្នុងការគាំទ្រប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ដើម្បីរិះរកដំណោះស្រាយសំដៅធ្វើឲ្យប្រតិបត្តិការមីក្រូហិរញ្ញវត្ថុប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព មានសុវត្ថិភាពនិងបន្តរួមចំណែកលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមលើកឡើងនូវមតិមួយចំនួនដែលជាអនុសាសន៍បន្ថែមទៀតសម្រាប់ជាជំនួយស្មារតីក្នុងការរួមចំណែកអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាឲ្យមានវិសាលភាពកាន់តែទូលាយ កាន់តែមានពិពិធភាព មានតួនាទីកាន់តែស៊ីជម្រៅ ហើយរឹងមាំនិងមានប្រសិទ្ធភាព ដើម្បីបន្តទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនដែលក្នុងនោះមាន៖

**ទី១**.ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរបញ្ញត្តិកម្មនិងត្រួតពិនិត្យចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបន្តដាក់ចេញនូវក្របខ័ណ្ឌបទប្បញ្ញត្តិ និងការត្រួតពិនិត្យដោយធ្វើការថ្លឹងថ្លែងប្រកបដោយសមភាព បំពេញបន្ថែមនិងធ្វើសុខដុមនីយកម្មក្របខ័ណ្ឌគតិយុត្ត ព្រមទាំងការពង្រឹងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍន៍ធនធានមនុស្សឲ្យប្រកបដោយវិជ្ជាជីវៈក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ។

**ទី២**.ធនាគារជាតិនៃកម្ពុជាត្រូវបន្តតាមដាន និងចាត់វិធានការលើអ្នកឲ្យខ្ចីចងការក្រៅប្រព័ន្ធឲ្យបានម៉ឺងម៉ាត់ ។ ក្នុងនោះដែរ ត្រូវបន្តខិតខំជំរុញសេវាមីក្រូហិរញ្ញវត្ថុតាមថ្លៃ និងលក្ខខណ្ឌកាន់តែមានលក្ខណៈអនុគ្រោះសម្រាប់ប្រជាជនក្រីក្រក៏ដូចជាសហគមន៍កសិកម្ម សំដៅលើកស្ទួយសេដ្ឋកិច្ចជនបទទន្ទឹមនឹងការបន្តពង្រីកការផ្តល់ឥណទានដល់សហគ្រាសធុនតូចនិងមធ្យមគាំទ្រដល់***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា២០១៥-២០២៥»***ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មីរបស់កម្ពុជា។

**ទី៣**.ធនាគារជាតិនៃកម្ពុជាត្រូវរៀបចំនូវគោលនយោបាយ ឬ យុទ្ធសាស្ត្រលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនិងកិច្ចគាំពារអតិថិជនសំដៅធ្វើយ៉ាងណាបង្កភាពងាយស្រួលនិងលើកទឹកចិត្តប្រជាជនឲ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានសេវាហិរញ្ញវត្ថុក្នុងប្រព័ន្ធនិងធានាថាផលប្រយោជន៍របស់ពួកគាត់

ត្រូវបានការពារប្រកបដោយតម្លាភាព ។

**ទី៤**.ធនាគារជាតិនៃកម្ពុជាត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ជាពិសេស ក្រសួងអប់រំយុវជន និងកីឡា ក្នុងការរៀបចំដាក់បញ្ចូលនូវចំណេះដឹងហិរញ្ញវត្ថុនៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ តាំងពីថ្នាក់បឋមសិក្សា ឬ មធ្យមសិក្សា ។

**ទី៥**.ធនាគារជាតិនៃកម្ពុជាត្រូវបន្តរៀបចំកម្មវិធីសិក្ខាសាលា និងវេទិកាថ្នាក់តំបន់និងថ្នាក់ជាតិ ដើម្បីផ្សព្វផ្សាយជូនសាធារណជនឲ្យជ្រួតជ្រាបបន្ថែមទៀតអំពីប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ និងហានិភ័យផ្សេងៗដែលអាចកើតឡើងពីការប្រើប្រាស់សេវាហិរញ្ញវត្ថុនេះ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាដែលបានខិតខំប្រឹងប្រែងរួមចំណែកធ្វើឲ្យវិស័យនេះ មានការអភិវឌ្ឍន៍គួរជាទីមោទនៈនិងសូមជូនពរដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាទាំងអស់ និងដៃគូពាក់ព័ន្ធទាំងអស់នៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាឲ្យទទួលបាននូវវឌ្ឍនភាព និងជោគជ័យថ្មីៗទៀតក្នុងពេលខាងមុខ។

ដើម្បីជាការបូកសរុប ខ្ញុំសូមដកស្រង់ពីច្បាប់អរិយសត្ថាសម្រាប់ជាគតិដែលចាស់ទុំបុរមបុរាណលោកបានអប់រំកូនខ្មែររាប់សតវត្សរ៍មកហើយថា៖

| | | |
|---|---|---|
| **វាយលេខទាត់ក្បាច់** | **សឹងផ្សំសម្រេច** | **ឲ្យបានដឹងដាន** |
| **ដឹងដើមដឹងចុង** | **ដឹងបង់ដឹងបាន** | **ដឹងគិតប្រមាណ** |
| | **កត់ត្រាបញ្ជី ។** | |
| **ឲ្យបានប្រយោជន៍** | **ប្រយ័ត្នអសោច** | **ជាអ្នករកស៊ី** |
| **សម្រាប់លោកិយ** | **ប្រក្រតីជាទី** | **សម្គាល់បញ្ជី** |
| | **ស្មៀនត្រាសៀវភៅ ។** | |
| **គន់គិតប្រយ័ត្ន** | **អស់ទ្រព្យសម្បត្តិ** | **ឲ្យស្ទាត់ដោយនូវ** |
| **វាយលេខទាត់ក្បាច់** | **ឲ្យស្រេចឃើញផ្លូវ** | **សឹមថយចេញទៅ** |
| | **តាមផ្លូវលោកិយ ។** | |

ជាទីបញ្ចប់ ជាមួយនិងការប្រកាសបើក ***«សន្និសីទជាតិ ស្តីពីការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា»*** នៅពេលនេះ ខ្ញុំសូមជូនពរចំពោះ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ដែលបានចូលរួមក្នុងសន្និសីទនេះ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ** !

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

## សុន្ទរកថាស្វាគមន៍
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសប្រារព្ធពិធីបើកសន្និសីទជាតិស្តីពី
## ការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

វិមានសន្តិភាព ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦

**សូមគោរព ៖**

- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សម្តេច ឯកឧត្តម លោកជំទាវ ជាគណៈអធិបតី ជាទីគោរព!
- អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ ជាទីស្នេហា!

ថ្ងៃនេះ ជាទិវាមួយដ៏មហោឡារិកដែលរាជរដ្ឋាភិបាល បានអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជារៀបចំសន្និសីទជាតិស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ។ ជាមួយគ្នានេះ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់កិត្តិយសអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកសន្និសីទជាតិនាថ្ងៃនេះ ។ ខ្ញុំក៏សូមសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានគណៈអធិបតី សម្តេច ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ ដែលបានចំណាយពេលដ៏មានតម្លៃចូលរួមក្នុងសន្និសីទជាតិនាពេលនេះ ។ វត្តមានដ៏វិសេសវិសាលរបស់ សម្តេច ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា ញ៉ាំងឱ្យពិធីនេះដំណើរការកាន់តែមានភាពអធិកអធម មានអត្ថន័យយ៉ាងជ្រាលជ្រៅនិងបានបង្ហាញពីកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធថែមទៀត ។

**សម្តេច ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់!**

សន្និសីទជាតិស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយពីសារៈសំខាន់ អត្ថប្រយោជន៍និងតួនាទីរបស់វិស័យមីក្រូហិរញ្ញវត្ថុ ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងកាត់បន្ថយភាពក្រីក្រដែលជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល រាយការណ៍ពីសមិទ្ធផល

សម្រេចបានក្នុងរយៈពេល ១០ឆ្នាំ បន្ទាប់ពីសម្តេចតេជោនាយករដ្ឋមន្ត្រីបានប្រកាសយកឆ្នាំ២០០៦ ជាឆ្នាំមីក្រូហិរញ្ញវត្ថុនៅកម្ពុជាក្នុងឱកាសនៃសន្និសីទជាតិស្តីពីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ១១-១៣ ខែមករា ឆ្នាំ២០០៦ ស្វែងយល់អំពីបញ្ហាប្រឈម និងកំណត់ទិសដៅសម្រាប់ការអភិវឌ្ឍនាពេលអនាគត ។

ខ្ញុំបាទសូមជម្រាបជូនថា បន្ទាប់ពីទទួលអនុសាសន៍ដ៏ថ្លៃថ្លារបស់សម្តេចតេជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា ក្រសួងពាក់ព័ន្ធ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានសហការយ៉ាងជិតស្និទ្ធដើម្បីអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុប្រកបដោយចីរភាព រួមចំណែកជំរុញបរិយាប័ន្នហិរញ្ញវត្ថុ លើកកម្ពស់ជីវភាពប្រជាជនតាមជនបទ និងជំរុញកំណើនសេដ្ឋកិច្ចពេញមួយទសវត្សរ៍កន្លងមក ។ ការរីកចម្រើននៃវិស័យនេះ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈកំណើននៃអត្រាបរិយាប័ន្នហិរញ្ញវត្ថុ ដែលត្រូវបានទទួលស្គាល់ថា ជាកម្លាំងចលករួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ ជាក់ស្តែង ប្រជាជនពេញវ័យដែលកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុក្នុងប្រព័ន្ធកើនពីប្រមាណ ៨,៧% នៅឆ្នាំ២០០៦ ដល់ប្រមាណ ៥១% ក្នុងឆ្នាំ២០១៥ ។ ឥណទានក្នុងវិស័យមីក្រូហិរញ្ញវត្ថុមានចំនួនប្រមាណ ១២ ទ្រីលានរៀល (សមមូលនឹង ៣ ប៊ីលានដុល្លារអាមេរិក)កើនឡើងលើសពី ៣០ដង ធៀបនឹងឆ្នាំ២០០៦ និងប្រាក់បញ្ញើសរុបមានចំនួនប្រមាណ ៥ ទ្រីលានរៀល (សមមូលនឹង ១,៣ ប៊ីលានដុល្លារអាមេរិក)។ គួរកត់សម្គាល់ដែរថានៅឆ្នាំ២០០៩ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ឱ្យទទួលប្រាក់បញ្ញើពីសាធារណជន ក្នុងគោលបំណងជំរុញពិពិធកម្មសេវាហិរញ្ញវត្ថុ និងអន្តរការិយកម្មហិរញ្ញវត្ថុនៅតាមទីជនបទ ។ ជាមួយនឹងដែនសេវាទូទាំងប្រទេស វិស័យមីក្រូហិរញ្ញវត្ថុបាននិងកំពុងបង្កើនការផ្តល់សេវាហិរញ្ញវត្ថុជូនប្រជាពលរដ្ឋនៅទីជនបទ ដែលទទួលបានការអប់រំតិចឱ្យទទួលបានលទ្ធភាពប្រើប្រាស់សេវាកម្មមានលក្ខណៈស្របច្បាប់ ការគាំពារកាន់តែប្រសើរ ការកាត់បន្ថយហានិភ័យ និងសមធម៌ក្នុងសង្គម ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរបញ្ញត្តិកម្ម និងត្រួតពិនិត្យប្រព័ន្ធធនាគារ បានដាក់ចេញបទបញ្ញត្តិមួយចំនួនដើម្បីធានាថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់ហិរញ្ញប្បទានជូនអតិថិជនប្រកបដោយការទទួលខុសត្រូវ រួមមាន ការផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយទាក់ទិននឹងការប្រាក់ កម្រៃនានា មានលក្ខណៈស្តង់ដារ និងប្រកបដោយតម្លាភាពជាដើម ។ ទន្ទឹមនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនបាននិងកំពុងចូលរួមយ៉ាងសកម្ម ដោយបញ្ជ្រាបនូវគោលការណ៍ការពារអតិថិជនសំខាន់ៗ ជំរុញកម្មវិធីអប់រំផ្នែកហិរញ្ញវត្ថុ ជំនាញផ្សេងៗ និងការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពជូនដល់អតិថិជនរបស់ខ្លួន ។

កន្លងមក ទន្ទឹមនឹងការអភិវឌ្ឍរីកចម្រើនវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា មានអង្គការ សមាគម និងអ្នកឱ្យខ្ចីចងការក្រៅផ្លូវការមួយចំនួន បានឆ្លៀតឱកាសបង្កបញ្ហាដល់សង្គម ដូចជា ការផ្តល់កម្ចីដោយយកការប្រាក់ខ្ពស់ ធ្វើឱ្យកូនបំណុលរបស់ខ្លួនធ្លាក់ក្នុងគ្រោះអាសន្ន រើពីបំណុលមិនរួច ហិនហោចទ្រព្យសម្បត្តិនិងធ្លាក់ក្នុងភាពក្រីក្រ ។ ក្រៅពីនេះ ក៏មានអង្គការ និងសមាគមមួយចំនួនទៀតប្រើប្រាស់ឈ្មោះ នាមករណ៍ ដូចជា **"ទីភ្នាក់ងារ"** ឬ **"អង្គការមនុស្សធម៌មិនានា"** ដែលអាចធ្វើឱ្យប្រជាពលរដ្ឋយល់ច្រឡំថាជារបស់រដ្ឋ ជាគ្រឹះស្ថានផ្តល់អំណោយមនុស្សធម៌ ឬមិនស្វែងរកប្រាក់ចំណេញ ។

ដូចនេះ ក្រោមការណែនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ បានសហការខ្ពស់រកដំណោះស្រាយចំពោះអង្គការ សមាគម និងអ្នកឱ្យខ្ចីចងការទាំងនោះ ។ ជាក់ស្តែង កាលពីដើមឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីថ្លែងការណ៍រួមមួយឱ្យផ្អាកសកម្មភាពអកុសលនេះភ្លាម ដើម្បីឆ្លើយតបទៅនឹងភាពមិនប្រក្រតីមួយចំនួនទាក់ទងនឹងប្រតិបត្តិករឥណទានក្រៅប្រព័ន្ធខ្លះ ដែលឆ្លៀតឱកាសប្រើឈ្មោះវិស័យមីក្រូហិរញ្ញវត្ថុធ្វើប្រតិបត្តិការកេងប្រវ័ញ្ច និងបង្កបញ្ហាដល់សង្គមដោយជំរុញអង្គការ និងសមាគមឱ្យធ្វើសកម្មភាពក្នុងក្របខ័ណ្ឌច្បាប់ ។ ធនាគារជាតិនៃកម្ពុជាក៏បានសហការផងដែរជាមួយអាជ្ញាធរមូលដ្ឋាននានាតាមបណ្តាខេត្ត-រាជធានីចំនួន ១៤ ដើម្បីចុះផ្សព្វផ្សាយដល់អាជ្ញាធរមានសមត្ថកិច្ច និងប្រជាពលរដ្ឋឱ្យមានការយល់ដឹងកាន់តែច្បាស់លាស់ថែមទៀតពីប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ដែលមានអ្នកចូលរួមសរុបចំនួន ៩.៧៦០ នាក់ ។ ជាមួយគ្នានេះ ចំពោះយុទ្ធនាការលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាក៏កំពុងរៀបចំជាបន្តបន្ទាប់សម្រាប់ផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ ដូចជា សិស្ស និស្សិត ប្រជាជនតាមជនបទ និងអាជីវករនានាផងដែរ ។

សរុបមក ក្នុងរយៈពេល ១០ឆ្នាំ ចុងក្រោយនេះ ជាមួយនឹងការអនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី វិស័យហិរញ្ញវត្ថុនៅកម្ពុជាមានការអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ជាខ្លាំង ទាំងផ្នែកវិសាលភាព ទំហំប្រតិបត្តិការ ផលិតផល និងបណ្តាញសេវា ប្រជាជនយល់ដឹងពីសារៈសំខាន់នៃវប្បធម៌ឥណទាន និងបានលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ហើយវិស័យនេះក៏ត្រូវបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ។

មិនតែប៉ុណ្ណោះ វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាក៏ត្រូវបានទទួលស្គាល់ថា ជាវិស័យមីក្រូហិរញ្ញវត្ថុមួយដ៏រីកចម្រើនក្នុងពិភពលោក និងជាគំរូដ៏ល្អសម្រាប់បណ្តាប្រទេសដទៃទៀត ។ សមិទ្ធផលទាំងនេះកើតឡើងដោយការខិតខំប្រឹងប្រែងរួមគ្នា និងកិច្ចសហការរវាងធនាគារជាតិនៃកម្ពុជា ជាមួយអាជ្ញាធរពាក់ព័ន្ធ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងដៃគូអភិវឌ្ឍន៍ ជាតិ និងអន្តរជាតិ ជាពិសេស រាជរដ្ឋាភិបាលដែលតែងតែបន្តគាំទ្រដល់ការអភិវឌ្ឍវិស័យនេះទាំងមូល ។

**សម្តេច ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់!**

ជាកិច្ចបន្ត ខ្ញុំសូមអនុញ្ញាតគោរពអញ្ជើញ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ ដើម្បីឱ្យយើងខ្ញុំ និងភាគីពាក់ព័ន្ធទាំងអស់សហការអនុវត្តជាបន្តទៅទៀតប្រកបដោយជោគជ័យ ។

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីបិទសន្និសីទជាតិ ស្តីពី ការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

*City Hall កោះពេជ្រ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦*

**សូមគោរព ៖**

- **ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ទាំងអស់ ជាទីមេត្រី**

នៅពេលនេះ សន្និសីទជាតិ ស្តីពី ការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជារបស់យើងបានឈានដល់ទីបញ្ចប់ហើយ ។ សន្និសីទរបស់យើង បានប្រព្រឹត្តទៅប្រកបដោយកិត្តិយសក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ ជារួម ខ្ញុំសូមវាយតម្លៃខ្ពស់ថា សន្និសីទរបស់យើងបានប្រព្រឹត្តទៅតាមរយៈការពិភាក្សាយ៉ាងផុសផុល និងប្រកបដោយជោគជ័យ ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អ្នកឧទ្ទេសនាម អ្នកសម្របសម្រួល និងវាគ្មិនទាំងអស់ ដែលបានចូលរួមពិភាក្សា និងចែករំលែកបទពិសោធន៍ និងគំនិតយោបល់ថ្មីៗ ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះការចូលរួមយ៉ាងសកម្មដោយយកចិត្តទុកដាក់របស់ ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ក្នុងអង្គសន្និសីទនេះ ។

ខ្ញុំសូមវាយតម្លៃខ្ពស់ និងសរសើរចំពោះប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និងភាគពាក់ព័ន្ធទាំងអស់ ក្នុងការខិតខំប្រឹងប្រែងសម្រេចបានសមិទ្ធផលដ៏ល្អកន្លងមក ដែលធ្វើឲ្យវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាមានកេរ្តិ៍ឈ្មោះល្បីល្បាញនៅក្នុងឆាកអន្តរជាតិ ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមជម្រាបជូនអង្គសន្និសីទអំពីប្រវត្តិត្រួសៗនៃការខ្ចីនិងការផ្តល់ឥណទានរបស់ខ្មែរយើង និងការអភិវឌ្ឍរីកចម្រើននៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ។ ការខ្ចីបុលគឺជាសកម្មភាពមួយដែលកើតមានតាំងពីបុរាណកាលតាំងពីយូរយារណាស់មកហើយ ។ ការខ្ចីបុលមានមុខសកម្មផង និងអសកម្មផង ។ ប្រព័ន្ធខ្ចីបុល

ដែលមានតាំងពីបុរាណមកដែលគ្មានការគ្រប់គ្រង និងដែលកើតឡើងឯកឯងដែលយើងហៅថា **"ការខ្ចីបុលពីឈ្មួញ ឬខ្ចីបុលក្រៅផ្លូវការ"** ត្រូវបានគេស្គាល់ថាជាមូលហេតុធ្វើឲ្យមានការកេងប្រវ័ញ្ច ។ នៅក្នុងសង្គមខ្មែរយើងពីបុរាណធ្លាប់មានពាក្យគេនិយាយថា **"ការរដូវវស្សា ១កន្ដាំង ដល់រដូវប្រាំង ១តៅ"** ។ ប្រទេសខ្មែរក៏ដូចជាប្រទេសជាច្រើនលើសកលលោក រដ្ឋាភិបាលគ្រប់របបតែងតែព្យាយាមចង់គ្រប់គ្រងប្រព័ន្ធខ្ចីបុលនេះ ដើម្បីចៀសវាងកុំឲ្យមានការកេងប្រវ័ញ្ចហួសហេតុ ហើយផ្ដល់ជាផលវិជ្ជមានឲ្យបានច្រើនដល់អ្នកខ្ចីបុលឲ្យបានកាន់តែច្រើន ។ កាលនៅសម័យសង្គមរាស្ត្រនិយម រដ្ឋាភិបាលព្យាយាមបង្កើតប្រព័ន្ធឥណទានជនបទតាមរយៈការបង្កើត **"រាជមន្ទីរសហករណ៍យើង"** ការបង្កើតសហករណ៍ផ្ដល់ទុន និងបង្កើតសហករណ៍ឧបភោគបរិភោគជាដើម ។ល។ នេះជាប្រព័ន្ធគ្រប់គ្រងដោយរដ្ឋ ។ រដ្ឋបានលូកដៃចូលជ្រៅទៅធ្វើអន្តរាគមន៍ទៅក្នុងការគ្រប់គ្រង ។ ក្រោយដំណើរការមួយរយៈប្រព័ន្ធនេះដើរទៅមុខមិនរួច ហើយទីបំផុតក៏បរាជ័យ មិនអាចដំណើរការធ្វើហិរញ្ញប្បទានជនបទបានទេ ។

នៅឆ្នាំ១៩៨០ ប្រព័ន្ធធនាគារថ្មីមួយត្រូវបង្កើតឡើង ជាប្រព័ន្ធធនាគារមួយថ្នាក់ ។ ប្រព័ន្ធធនាគារទាំងមូលត្រូវបានគ្រប់គ្រងដោយរដ្ឋ ។ បរិមាណទុន និងអត្រាការប្រាក់ត្រូវបានកំណត់ដោយរដ្ឋ ដើម្បីចៀសវាងការកេងប្រវ័ញ្ចពីអ្នកខ្ចី ។ នៅទីបំផុត ប្រព័ន្ធនេះក៏ដំណើរការដោយមិនមានប្រសិទ្ធភាព តម្លាភាព និងសមធម៌ ។ អ្នកខ្ចីបានចេះតែបាន អ្នកមិនបានខ្ចីនៅតែមិនបានខ្ចី ហើយទីបំផុតអ្នកខ្ចីកេងប្រវ័ញ្ចពីរដ្ឋទៅវិញ ។ បំណុលជាច្រើនក្លាយជាបំណុលអាក្រក់ ទារវិញមិនបាន ដែលធ្វើឲ្យរដ្ឋបាត់បង់ទុនយ៉ានច្រើន ។

នៅទសវត្សរ៍ឆ្នាំ១៩៩០ ប្រព័ន្ធឥណទានជនបទថ្មីមួយបានកើតឡើងក្នុងរូបភាពជាអង្គការមិនមែនរដ្ឋាភិបាលទទួលបានទុនពីក្រៅប្រទេសយកមកដំណើរការ ជាដំបូងក្រោមរូបភាពមនុស្សធម៌ ។ ក្រោយមកបន្តិចម្ដងៗ បានដំណើរការជាប្រព័ន្ធរកស៊ីមានចំណេញខាតទាំងស្រុង ។ ជាមួយគ្នានេះដែរ **"គណៈកម្មាធិការឥណទាន សម្រាប់អភិវឌ្ឍជនបទ"** រួមជាមួយធនាគារជាតិនៃកម្ពុជាបានព្យាយាមគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាលទាំងនោះដោយតម្រូវឲ្យចុះបញ្ជី និងទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដោយត្រូវគោរពតាមវិធានធ្វើប្រតិបត្តិការ និងវិធានការប្រុងប្រយ័ត្ន ហើយខ្លះអាចទទួលប្រាក់បញ្ញើពីអតិថិជនថែមទៀត ។ ប្រព័ន្ធនេះឈរលើគោលការណ៍ទីផ្សារ និងការប្រកួតប្រជែង ប៉ុន្តែមានការគ្រប់គ្រងដោយរដ្ឋ ដែលដើរតួនាទីជាបញ្ញត្តិករ ដែលជាកត្តាគន្លឹះជោគជ័យនៃការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ។

**ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់ ជាទីមេត្រី**

ខ្ញុំជឿជាក់ថា ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា ពិតជាបានជ្រាប និងភ្លាប់បានពីសមិទ្ធផលរួមនៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាសម្រេចបានក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក និងស្វែងយល់ពីបទពិសោធន៍នានាដែលវាគ្មិនយើងបានចែករំលែកជូនអង្គសន្និសីទ ។ តាមរយៈការពិភាក្សាលើប្រធានបទទាំង ៥ អង្គសន្និសីទបានលើកអនុសាសន៍ល្អៗមួយចំនួនដូចខាងក្រោម៖

អង្គសន្និសីទរយៈពេល ២ ថ្ងៃនេះ ក៏បានពិភាក្សា ផ្លាស់ប្ដូរយោបល់ និងចែករំលែក បទពិសោធន៍ពាក់ព័ន្ធនឹងប្រធានបទចំនួន ៥ រួមមានដូចជា ៖

១. ភាគីទាំងអស់បន្តជំរុញសេវាហិរញ្ញវត្ថុផ្សេងទៀតបន្ថែមលើសេវាឥណទាន ជាពិសេស ការផ្តល់សេវាហិរញ្ញវត្ថុជូនប្រជាពលរដ្ឋក្នុងតម្លៃសមស្រប ។

២. ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងភាគីពាក់ព័ន្ធទាំងអស់បន្តចាត់វិធានការណ៍ម៉ឺងម៉ាត់ចំពោះអង្គការមិនមែនរដ្ឋាភិបាល សមាគម និងអ្នកឲ្យខ្ចីចងការក្រៅផ្លូវការដែលធ្វើប្រតិបត្តិការធនាគារដោយពុំមានច្បាប់អនុញ្ញាតត្រឹមត្រូវ ។

៣. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវផ្តល់ឥណទានផ្អែកលើសមត្ថភាពនៃការសងត្រលប់ និងផលិតភាពនៃមុខរបរឬអាជីវកម្មរបស់អតិថិជន និងត្រូវចៀសវាងការផ្តល់ឥណទានដែលមានភាពធូររលុងនិងពឹងផ្អែកតែទៅលើទ្រព្យធានាតែម៉្យាងប៉ុណ្ណោះ ។

៤. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវពង្រឹងយន្តការនៃកិច្ចការពារអតិថិជន ដោយផ្តោតលើការអនុវត្តក្រមប្រតិបត្តិតម្លាភាព ការបង្ហាញព័ត៌មាន ភាពសមស្របនៃផលិតផល និងគោលការណ៍និងយន្តការដោះស្រាយបណ្តឹងដែលសាមញ្ញនិងងាយស្រួល ។ ឧទាហរណ៍ ការផ្សាយពាណិជ្ជកម្មប្រាក់កម្ចី តាមអត្រាការប្រាក់ ២% អាចមានន័យថា ២% ក្នុងមួយថ្ងៃ ឬក្នុងមួយសប្តាហ៍ ឬក្នុងមួយខែ ។ ដូច្នេះ ចាំបាច់ទាមទារនូវកិច្ចសហការរវាងគ្រប់ភាគីពាក់ព័ន្ធដើម្បីកែលម្អ និងអប់រំប្រជាពលរដ្ឋ សំដៅការពារផលប្រយោជន៍របស់អតិថិជន ។

៥. ធនាគារជាតិនៃកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា សមាគមមីក្រូហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍនានាបន្តសហការលើកកម្ពស់កម្មវិធីអប់រំផ្នែកហិរញ្ញវត្ថុដល់ប្រជាជន ។

៦. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវបន្តបេសកកម្មផ្នែកសង្គមនិងបរិស្ថាន ក្នុងគោលបំណងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ។

**ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់ ជាទីមេត្រី**

ដូចអង្គសន្និសីទជ្រាបហើយ សម្តេចតេជោនាយករដ្ឋមន្ត្រីបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរបញ្ញត្តិកម្មនិងត្រួតពិនិត្យ ក្នុងការរួមចំណែកដល់ការអភិវឌ្ឍវិស័យមីក្រូ-ហិរញ្ញវត្ថុនៅកម្ពុជា ជាពិសេស ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ពោលគឺចាប់ពីការប្រកាសជាផ្លូវការរបស់រាជរដ្ឋាភិបាលយកឆ្នាំ២០១៦ ជាឆ្នាំមីក្រូហិរញ្ញវត្ថុកម្ពុជា ។ ទោះយ៉ាងណា សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានលើកឡើងពីភាពអសកម្មមួយចំនួន ដែលគ្រប់ភាគីពាក់ព័ន្ធ រួមទាំងអាជ្ញាធរមូលដ្ឋានផង ត្រូវសហការដោះស្រាយ៖

១. សកម្មភាពក្រៅផ្លូវការ ឬខុសច្បាប់មួយចំនួន ដែលត្រូវបានប្រើប្រាស់ជាលេស ក្នុងគោលដៅកេងប្រវ័ញ្ចនិងទុច្ចរិត បណ្តាលឲ្យប្រជាជនធ្លាក់ក្នុងភាពក្រីក្រ និងរឹបអូសផ្ទះសម្បែងនិងទ្រព្យសម្បត្តិ ។ សកម្មភាពទាំងនេះបង្ហាញឲ្យឃើញតាមរយៈការផ្តល់ឥណទានដោយមានលក្ខខណ្ឌធូររលុង ដោយមិនគិតពីគោលបំណងកម្ចី ថាតើយកទៅបង្កើត ឬពង្រីកមុខរបរ អាជីវកម្ម ឬយកទៅប្រើប្រាស់ជាការកម្សាន្ត ឬលេងល្បែងស៊ីសង ។

២. សកម្មភាពតាំងខ្លួនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្របច្បាប់ ដោយគិតអត្រាការប្រាក់ខ្ពស់ ឬការទាក់ទាញប្រាក់បញ្ញើដោយសន្យាផ្តល់ការប្រាក់ខ្ពស់ហួសហេតុ ឧទាហរណ៍ ១២% ក្នុងមួយខែ ឬ ១៤៤% ក្នុងមួយឆ្នាំ ដែលបានកើតឡើងរួចមកហើយក្នុងខេត្តបាត់ដំបងនាពេលកន្លងមក ។ សកម្មភាពនេះជាការបោកប្រាស់ ។

៣. រដូវកាលឃោសនាបោះឆ្នោតជិតមកដល់ មានគណបក្សនយោបាយ និងបុគ្គលមួយចំនួនបាននិងកំពុងកេងយកចំណេញផ្នែកនយោបាយថែមទៀត តាមរយៈការឃោសនាឲ្យប្រជាជនយល់ច្រឡំថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាគ្រឹះស្ថានរបស់រដ្ឋ ដូច្នេះប្រាក់ដែលខ្ចីជារបស់រដ្ឋ ហើយប្រជាជនខ្ចីប្រាក់មិនចាំបាច់សងប្រាក់កម្ចីនោះត្រឡប់វិញទេ ហើយថែមទាំងបានសន្យាថា បើពួកគេឈ្នះឆ្នោតនោះ ពួកគេនឹងលុបចោលប្រាក់ចម្ងីទាំងនោះ ។

សម្តេចតេជោនាយករដ្ឋមន្ត្រីបានណែនាំបន្ថែមថា អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់មិនត្រូវជួយដល់សកម្មភាពខុសច្បាប់របស់អង្គការ ឬសមាគមក្នុងការធ្វើបាបប្រជាពលរដ្ឋ ប៉ុន្តែត្រូវតាមដានសកម្មភាពឃោសនានយោបាយបែបប្រជាភិថុតរបស់គណបក្សនយោបាយ និងអ្នកនយោបាយមួយចំនួនដែលផ្ទុយនឹងបទប្បញ្ញត្តិហិរញ្ញវត្ថុ ។ ក្នុងករណីយនេះ អាជ្ញាធរមូលដ្ឋានត្រូវចាប់ខ្លួនជនទាំងនោះដើម្បីផ្តន្ទាទោស ដោយផ្អែកពីបទល្មើសជាក់ស្តែង ។

**ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់ ជាទីមេត្រី**

ខ្ញុំសូមជម្រាបជូនអង្គសន្និសីទទាំងមូលជាថ្មីម្តងទៀត នូវប្រសាសន៍របស់សម្តេចតេជោនាយករដ្ឋមន្ត្រីថ្លែងក្នុងពិធីបើកសន្និសីទនេះថា រាជរដ្ឋាភិបាលកម្ពុជាបាននិងបន្តគាំទ្រយ៉ាងពេញទំហឹងក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ ក៏ដូចជាការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ និយាយជារួម និងវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា និយាយដោយឡែក ដើម្បីចូលរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយស្ថិរភាពនិងបរិយាប័ន្ន តាមរយៈការធ្វើកំណែទម្រង់ និងការដាក់ចេញនូវគោលនយោបាយ និងការបង្កនូវបរិស្ថានអំណោយផលដល់ការអភិវឌ្ឍសេដ្ឋកិច្ចទាំងមូល និងជាពិសេស ការប្រកាន់នូវយន្តការសេដ្ឋកិច្ចទីផ្សារនិងតម្លាភាព និងការប្រកួតប្រជែងដូចដែលធ្លាប់បានអនុវត្តកន្លងមក ។ ដូចដែលសម្តេចតេជោបានមានប្រសាសន៍បញ្ជាក់យ៉ាងច្បាស់ក្នុងឱកាសបើកសន្និសីទកាលពីម្សិលមិញថា ចំពោះមុខនេះយើងឃើញថា ធនាគារជាតិនៃកម្ពុជាបានរួមចំណែកបង្កើនចំណេះដឹងលើការប្រើប្រាស់សេវាហិរញ្ញវត្ថុដល់ថ្នាក់មូលដ្ឋាន ដែលធ្វើឲ្យប្រជាជនមានការយល់ដឹងកាន់តែច្រើនក្នុងការ ស្វែងរកប្រភពហិរញ្ញប្បទានពីធនាគារពាណិជ្ជនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពិសេស ធ្វើឲ្យពួកគេយល់ច្បាស់ថា មីក្រូហិរញ្ញវត្ថុពុំមែនជាសកម្មភាពសប្បុរសធម៌ទេ ។

ជាមួយគ្នាដែរ អង្គសន្និសីទទាំងមូល ក៏បានជ្រាបនូវអនុសាសន៍ថ្មីៗបន្ថែមទៀត របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដែលរួមមាន ៖

**ទី១.** ធនាគារជាតិនៃកម្ពុជា ក្នុនាមជាអាជ្ញាធរបញ្ញត្តិកម្ម និងត្រួតពិនិត្យចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបន្តដាក់ចេញនូវក្របខ័ណ្ឌបទប្បញ្ញត្តិនិងការត្រួតពិនិត្យ ដោយធ្វើការថ្លឹងថ្លែងប្រកបដោយសមភាពបំពេញបន្ថែមនិងធ្វើសុខដុមនីយកម្មក្របខណ្ឌគតិយុត្ត ព្រមទាំងការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍធនធាន

មនុស្សឲ្យប្រកបដោយវិជ្ជាជីវៈក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ។

**ទី២.** ធនាគារជាតិនៃកម្ពុជា ត្រូវបន្តតាមដាននិងចាត់វិធានការលើអ្នកឱ្យខ្ចីចងការក្រៅប្រព័ន្ធឲ្យបានម៉ឺងម៉ាត់ ។ ក្នុងនោះដែរ ត្រូវខិតខំជំរុញសេវាមីក្រូហិរញ្ញវត្ថុតាមថ្លៃនិងលក្ខខណ្ឌកាន់តែមានលក្ខណៈអនុគ្រោះសម្រាប់ប្រជាជនក្រីក្រ ក៏ដូចជាសមាគមកសិកម្មសំដៅលើកស្ទួយសេដ្ឋកិច្ចជនបទ ទន្ទឹមនឹងការពង្រីកការផ្តល់ឥណទានដល់សហគ្រាសធុនតូច និងមធ្យម គាំទរដល់ **"គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥"** ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មីរបស់កម្ពុជា ។

**ទី៣.** ធនាគារជាតិនៃកម្ពុជា ត្រូវរៀបចំនូវគោលនយោបាយ ឬយុទ្ធសាស្ត្រលើកកម្ពស់ហិរិយាប័ន្នហិរញ្ញវត្ថុ និងកិច្ចគាំពារអតិថិជនសំដៅធ្វើយ៉ាងណាបង្កភាពងាយស្រួល និងលើកទឹកកចិត្តប្រជាជនឲ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានសេវាហិរញ្ញវត្ថុក្នុងប្រព័ន្ធនិងធានាថា ផលប្រយោជន៍របស់ពួកគាត់ត្រូវបានការពារប្រកបដោយតម្លាភាព។

**ទី៤.** ធនាគារជាតិនៃកម្ពុជា ត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ជាពិសេស ក្រសួងអប់រំយុវជន និងកីឡា ក្នុងការរៀបចំដាក់បញ្ចូលនូវចំណេះដឹងហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ តាំងពីថ្នាក់បឋមសិក្សា ឬមធ្យមសិក្សា ។

**ទី៥** ធនាគារជាតិនៃកម្ពុជា ត្រូវបន្តរៀបចំកម្មវិធីសិក្ខាសាលា និងវេទិកាថ្នាក់តំបន់និងថ្នាក់ជាតិ ដើម្បីផ្សព្វផ្សាយជូនសាធារណមតិឱ្យជ្រួតជ្រាបបន្ថែមទៀតអំពីប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ និងហានិភ័យផ្សេងៗដែលអាចកើតឡើងពីការប្រើប្រាស់សេវាហិរញ្ញវត្ថុនេះ ។

ក្នុងនាមជាអាជ្ញាធរអាណាព្យាបាល និងត្រួតពិនិត្យទៅលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាប្តេជ្ញាអនុវត្តតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ព្រមទាំងទទួលយកនូវយោបល់នានា បន្ថែមទៀតដែលបានលើកឡើង និងពិភាក្សានៅក្នុងអង្គសន្និសីទនេះ ដើម្បីរៀបចំជាទិសដៅនិងផែនការសកម្មភាពបន្ថែមទៀត សម្រាប់បន្តគាំទ្រដល់ការរីកចម្រើននៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ។

**ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា**

សរុបមក អង្គសន្និសីទបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផល ការរីកចម្រើននៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាដែលសម្រេចបានកន្លងមក ហើយសមិទ្ធផលទាំងនេះក៏នឹងមិនអាចសម្រេចបាននោះទេ ប្រសិនបើគ្មានការចូលរួមនិងកិច្ចសហការល្អរវាងគ្រប់ភាគីពាក់ព័ន្ធនោះ ។ ដូច្នេះហើយ ខ្ញុំសូមលើកទឹកចិត្តឲ្យរក្សានូវស្មារតីនៃកិច្ចសហការល្អនេះបន្តទៀត នោះយើងប្រាកដជានឹងអាចជំនះបញ្ហាទាំងឡាយប្រកបដោយជោគជ័យ ដូចពាក្យចាស់ពោលថា *សាមគ្គីគឺជាកំលាំងដ៏រឹងមាំ* ។ ធនាគារជាតិនៃកម្ពុជានឹងបន្តសហការជាមួយគ្រប់ភាគីពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍នានាក្នុងការបន្តពង្រឹងអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាឲ្យកាន់តែបន្តរីកចម្រើននិងប្រកបដោយនិរន្តរភាព។

ខ្ញុំសូមអនុញ្ញាតរំលឹកឡើងវិញនូវប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដកស្រង់ពីច្បាប់អរិយសត្ថាមក សម្រាប់ជាគតិដល់បងប្អូនប្រជាពលរដ្ឋ មុនពេលសម្រេចប្រើប្រាស់សេវាហិរញ្ញវត្ថុ ។

**វាយលេខទាត់ក្បាច់ សឹងផ្សំសម្រេច ឲ្យបានដឹងដាន**
**ដឹងដើមដឹងចុង ដឹងបង់ដឹងបាន ដឹងគិតប្រមាណ**
**កត់ត្រាបញ្ជី ។**
**ឲ្យបានប្រយោជន៍ ប្រយ័ត្នអសោចិ៍ ជាអ្នករកស៊ី**
**សម្រាប់លោកិយ ប្រក្រតីជាទី សម្គាល់បញ្ជី**
**ស្មៀនត្រាសៀវភៅ ។**
**គន់គិតប្រយ័ត្ន អស់ទ្រព្យសម្បត្តិ ឲ្យស្ទាត់ដោយនូវ**
**វាតលេខទាត់ក្បាច់ ឲ្យស្រេចឃើញផ្លូវ សឹមថយចេញទៅ**
**តាមផ្លូវលោកិយ ។**

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិនិងអន្តរជាតិ ទាំងអស់ ដែលបាន អញ្ជើញចូលរួមក្នុងអង្គសន្និសីទនេះ តាំងពីដើមរហូតដល់ចប់ និងសូមជូនពរឲ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបិទសន្និសីទជាតិ ស្តីពី ការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា របស់យើងជាស្ថាពរ ។

**សូមអរគុណ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.........................................................

# សុន្ទរកថាស្វាគមន៍
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# និងជាប្រធានគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
# ថ្លែងក្នុងឱកាសបើកកិច្ចប្រជុំក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦

**សូមគោរព ៖**

- **លោក Peter Knoll ប្រធានក្រុមបេសកកម្មធនាគារអភិវឌ្ឍន៍អាស៊ី (ADB)**
- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីមេត្រី**

ជាបឋម ក្នុងនាមធនាគារជាតិនៃកម្ពុជា និងជាប្រធានគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ខ្ញុំមានកិត្តិយសសូមស្វាគមន៍ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានវត្តមានក្នុងកិច្ចប្រជុំនាពេលនេះ ។ ខ្ញុំក៏សូមអរគុណផងដែរ ចំពោះក្រុមបេសកកម្មធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងនោះរួមមាន លោក Peter Knoll ប្រធានក្រុមបេសកកម្ម លោក Shaan Stevens លោក Bill Foster លោក Des Crane លោក Russel Leith lok Chee Sung Lee ព្រមទាំង ធនាគារអភិវឌ្ឍន៍អាស៊ីជារួម ដែលបានគាំទ្រការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជារហូតមកដល់បច្ចុប្បន្ន ជាពិសេសបានចូលរួមយ៉ាងសកម្មនិងដ៏មានប្រសិទ្ធភាពក្នុងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិញ្ញវត្ថុរយៈពេលវែងរបស់រដ្ឋាភិបាល ។

ដូចអង្គប្រជុំបានជ្រាបរួចហើយថា ក្នុងឆ្នាំ២០០១ ដោយមានជំនួយឧបត្ថម្ភរបស់ធនាគារអភិវឌ្ឍន៍អាស៊ី រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ និងអនុម័តនូវ "ចក្ខុវិស័យនិងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ" លើកទីមួយសម្រាប់ ២០០១-២០១០ ដែលជាយុទ្ធសាស្ត្ររយៈពេលវែង ក្នុងគោលដៅសម្រេចបាននូវការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមួយដ៏រឹងមាំផ្អែកលើមូលដ្ឋានទីផ្សារ ដើម្បីគាំទ្រការកៀងគរធនធាននិងគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងផ្អែកលើមូលដ្ឋានដ៏ទូលំទូលាយ ។ ផែនការយុទ្ធសាស្ត្រនេះត្រូវបានធ្វើបច្ចុប្បន្នកម្មចំនួន ២ លើករួចមកហើយ ទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥" នៅឆ្នាំ២០០៦ និង "យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០" នៅឆ្នាំ២០១២ ដើម្បីឆ្លើយតបឲ្យបានសមស្របនឹងការអភិវឌ្ឍថ្មីៗនៃបរិស្ថានសេដ្ឋកិច្ចនិងទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា ។ ក្នុងស្ថានភាពបច្ចុប្បន្ន យោងតាមការអភិវឌ្ឍក្នុងសន្ទុះដ៏លឿននៃវិស័យហិរញ្ញវត្ថុ ព្រមទាំងផ្អែកលើ

បទពិសោធន៍បញ្ហាប្រឈម និងមេរៀនថ្មីៗនៅក្នុងតំបន់និងសកលលោក រាជរដ្ឋាភិបាលយល់ឃើញថា ចាំបាច់ត្រូវធ្វើបច្ចុប្បន្នកម្ម "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ" ជាថ្មីម្តងទៀត ។ ដោយមើលឃើញតម្រូវការនេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានឆ្លើយតបជាវិជ្ជមានជាថ្មីចំពោះសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំធ្វើបច្ចុប្បន្នកម្ម "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០" ទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥" ។

ការរៀបចំ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥" បានចាប់ផ្តើមឡើងនាត្រីមាសទី៤ ឆ្នាំ២០១៥កន្លងទៅ ។ ចាប់ពីពេលនោះមក ការពិគ្រោះយោបល់យ៉ាងសកម្ម ត្រូវបានធ្វើឡើងរវាងអ្នកបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនិងបណ្តាក្រសួងស្ថាប័នរបស់រដ្ឋដែលពាក់ព័ន្ធដៃគូអភិវឌ្ឍន៍និងវិស័យឯកជន ព្រមទាំងមានការរៀបចំកម្មវិធីសិក្ខាសាលាតាមវិស័យចំនួន ៥ ក្នុងគោល-បំណងទទួលបានមតិ និងធាតុចូលបន្ថែមពីវិស័យមិនមែនរដ្ឋាភិបាល ដើម្បីឲ្យយុទ្ធសាស្ត្រនេះ មានលក្ខណៈគ្រប់ជ្រុងជ្រោយនិងឆ្លុះបញ្ចាំងពីតម្រូវការនិងការវិវត្តជាក់ស្តែងនៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា ។

ថ្ងៃនេះ ការជួបប្រជុំគ្នាក្នុងក្រុមការងារបច្ចេកទេស គឺជាដំណាក់កាលមួយយ៉ាងសំខាន់ ដែលយើងនឹងពិភាក្សាលើដំណើរការនៃការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ក្នុងនោះក៏មានរបាយ-ការណ៍វាយតម្លៃវិស័យហិរញ្ញវត្ថុ (Diagnostic Assessment Report) ។ ខ្ញុំសូមជម្រាបថា របាយ-ការណ៍នេះ គឺជារបាយការណ៍ដែលក្រុមបេសកកម្មធនាគារអភិវឌ្ឍន៍អាស៊ីបានរៀបចំឡើងបន្ទាប់ពីពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ហើយក៏ជាឯកសារមូលដ្ឋានសម្រាប់រៀបចំឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ ។ ការពិនិត្យនិងការពិភាក្សាក្នុងកិច្ចប្រជុំថ្ងៃនេះ គឺក្នុងគោលដៅធានាឲ្យខ្លឹមសារត្រឹមត្រូវនិងគ្រប់គ្រាន់ និងជាមូលដ្ឋានសមស្របក្នុងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុប្រកបដោយភាពរឹងមាំ ចីរភាព និងបរិយាប័ន្ន ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីមេត្រី**

តាងនាមធនាគារជាតិនៃកម្ពុជា និងគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាក្រុមការងារបច្ចេកទេស ដែលបានចំណាយពេលដ៏មានតម្លៃចូលរួមក្នុងកិច្ចប្រជុំនេះ និងចូលរួមចំណែកក្នុងដំណើរការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥ របស់រាជរដ្ឋាភិបាល ។ ជាថ្មីម្តងទៀត ខ្ញុំសូមសម្តែងការអរគុណចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ជាពិសេស ក្រុមបេសកកម្មដែលជួយគាំទ្រដល់ការរៀបចំធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនៅកម្ពុជាជាបន្តបន្ទាប់ ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមមានសុខភាពល្អ កម្លាំងមាំមួន និងទទួលបានជោគជ័យគ្រប់ភារកិច្ច ។

ជាកិច្ចបន្ត ខ្ញុំសូមឲ្យ លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរងធនាគារជាតិនៃកម្ពុជានិងជាអនុប្រធានប្រចាំការនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុដើម្បីដឹកនាំអង្គប្រជុំនាថ្ងៃនេះ។

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

## សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ប្រធានក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
## សិក្ខាសាលាស្តីពីការត្រៀមទទួលការវាយតម្លៃអញ្ញមញ្ញ និងការវាយតម្លៃហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មថ្នាក់ជាតិ

នៅថ្ងៃទី១៨-២២ ខែមករា ឆ្នាំ២០១៦

ৎৎৎৎৎৎৎ

**ជាបឋម ខ្ញុំសូមគោរព!**

- **ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ជាទីគោរពដ៏ខ្ពង់ខ្ពស់!**
- **លោក** Alassane Sow **តំណាងធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា ជាទីគោរព!**
- **គណៈអធិបតី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដោយបានចូលរួមសិក្ខាសាលាជាមួយ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលបានឆ្លៀតឱកាសដ៏មមាញឹក ចូលរួមជាគណៈអធិបតីក្នុងសិក្ខាសាលានេះ ។ ខ្ញុំសូមសម្តែងអំណរគុណផងដែរចំពោះធនាគារពិភពលោក ដែលបានផ្តល់ការគាំទ្រសិក្ខាសាលានេះ ឲ្យប្រព្រឹត្តទៅបាន ក្នុងកាលៈទេសៈ ដែលប្រទេសកម្ពុជាត្រូវទទួលការវាយតម្លៃអញ្ញមញ្ញពីសំណាក់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG) ជាលើកទី២ ។

ឆ្លៀតឱកាសដ៏មានតម្លៃនេះ តាងនាមក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) ខ្ញុំសូមការអនុញ្ញាតជម្រាបដោយសង្ខេបអំពីកិច្ចដំណើរការរបស់ ស.ហ.ក ដែលត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើងកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ ។ ស.ហ.ក មានការវិវត្តន៍ជាលំដាប់ទាំងទំហំប្រតិបត្តិការនិងជំនាញ ។ បច្ចុប្បន្ន អង្គភាពនេះបានដាក់ឲ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យារាយការណ៍ប្រតិបត្តិការតាមអេឡិចត្រូនិក ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីបង្កើនប្រសិទ្ធភាពនៃការទប់ស្កាត់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ទន្ទឹមនេះ ស.ហ.ក កំពុងយកចិត្តទុកដាក់ពង្រីកវិសាលភាពនៃការរាយការណ៍ដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ ដែលចាំបាច់ត្រូវមាន

ការជួយគាំទ្រនិងសហការពីសំណាក់ក្រសួង-ស្ថាប័ន ជាអាជ្ញាធរអាណាព្យាបាលពាក់ព័ន្ធ ដើម្បីឲ្យការងារនេះសម្រេចបានជោគជ័យ និងអាចឈានទៅជាប្រទេសមួយដែលមានប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរឹងមាំ ខណៈដែលកម្ពុជាកំពុងធ្វើសមាហរណកម្មក្នុងតំបន់និងពិភពលោក ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីគោរព!**

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា ដែលជាថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស ដែលបានផ្តល់កិច្ចសហការយ៉ាងសកម្ម លើការងារត្រៀមទទួលការវាយតម្លៃអញ្ញមញ្ញ និងការវាយតម្លៃហានិភ័យថ្នាក់ជាតិ ដើម្បីសម្រេចបានលទ្ធផលជាវិជ្ជមាន ស្របតាមយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៣-២០១៧ របស់រាជរដ្ឋាភិបាល ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខ ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀត ចំពោះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលបានចូលរួមក្នុងសិក្ខាសាលានេះ ។ ខ្ញុំសូមថ្លែងអំណរគុណផងដែរ ចំពោះគ្រូឧទ្ទេសនាមមកពីធនាគារពិភពលោក ដែលបានចំណាយពេលវេលាមកបង្ហាត់បង្រៀននិងចែករំលែកបទពិសោធន៍ជាមួយសិក្ខាកាមយើង និងសូមអរគុណចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាសិក្ខាកាមទាំងអស់ដែលបានចូលរួមសិក្ខាសាលា នាពេលនេះ ។ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា សូមមានសុខភាពល្អ និងទទួលបានជ័យជម្នះគ្រប់ភារកិច្ច ។

**សូមអរគុណ!**

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

**Opening Remarks**
**By**
**H.E Chea Chanto, Governor of the National Bank of Cambodia,**
**On the Occation of the IMF-NBC Seminar on Integrated Macroeconomic Statistics**
**and Balance Sheet Approach for Better Economic Dicision-Making**
Siem Reap Provice, 21-22 January 2016

- **Mr. Odd per Brekk, Director of the IMF Regional Office for Asia and the Pacific**
- **Ms. Yong Sarah Zhou, IMF Resident Representative to Cambodia**
- **Distinguished Resource Speakers, Ladies and Gentlemen,**

**A Very Good Morning, អរុណសួស្តី!**

Today, I have the great pleasure that the National Bank of Cambodia, in cooperation with the IMF's Regional Office for Asia and the Pacific, jointly organize this capacity-building seminar on "Intergrated Macroeconomic Statistics and the Balance Sheet Approach for Better Economic Decision-Making" from 21st to 22nd January 2016, in Siem Reap Province.

On behalf of the National Bank of Cambodia and on my own behalf, I would like to extend my warmest welcome to IMF delegates, distinguished resource speakers, and participants from Central Bank, Ministries of Finance, Ministries of Planning and Institutes of Statistics in the Asia and the Pacific Region to Cambodia, especialy to our ancient capital city of Angkor.

Let me take this opportunity to express our gratitude to the IMF's Regional Office for Asia and Pacific, in particular Mr. Odd per Brekk, for having the National Bank of Cambodia as the host of this important seminar. My special thanks and appreciation goes to our distinguished resource speakers who have come from different parts of the world to share their knowledge and experience on this subjects.

Today's seminar is held within the context of the current global economy and rapidly growing and more integrated financial system each of our country faces. Our country must address and adapt to the complex economic environment and an ever-changing world. I believe that today's seminar will be one of the most important and fundamental trainings that will have us to improve data quality, consistency and collaboration among data-producing authorities to help us address these challenges. In addition, it will enhance the knowledge on linkages between various domains of macroeconomic and financial statistics. These are vital inputs for formulating comprehensive and appropriate

policies in order to sustain the pace of the region's economic development.

In Cambodia, for example, our economy grew at the rate of 7.7 percent in the last two decades and GDP increased by more than four times from a very low base. The banking sector has developed even faster than the economy as its assets increased by over 50 times and is now playing an important role in promotintg economic activities. Though we have well-preserved macroeconomic and financial stability, the rapid growth of the economy and financial sector-amid the more integrated and still-uncertain global economy-require authorities to be more vigilant and to glosely monitor risks. These risks may not only emerge from domestic factors, but can also increasingly come from external factors. Thus, it is vital to implement adequate policies to maintain the momentum of the courtry's development. Furthermore, the ability to respon efficiently and effectively to any shock relies on accurate and timely data, excellent knowledge on the complexity and likages of the sector, especially the analytical capacity to analyze potential challenges.

It is within this context that I strongly believe that the results of today's seminar would contribute to further building capacity and skills of our staff to improve the quality of macroeconomic and financial statistics and the quality of analysis. This will turn help us fine better approeches and improve the decision-making process to improve our economy.

**Distinguished Delegates, Resource Speakers, Ladies and Gentlemen,**
I do hope tha you will find some time in your tight seminar schedule to explore and enjoy what this city fas to offer, and get toknow more about our people, history, culture and cuisine. In this regard, the National Bank of Cambodia is delighted to organize a tour for you to visit our Angkor Wat Temple, which is a UNESCO world Heritage Site, and other historical temples in the complex.
Let me conclude my remarks by wishing that our seminar will have active participation and will be a productive one. I also wish you all good luck and a very pleasant stay in our ancient capital city of Siem Reap Angkor.

**Thank you very much.**

# អត្ថបទស្រាវជ្រាវ
# ស្តីពីកម្រិតសមស្របក្នុងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ របស់ធនាគារជាតិនៃកម្ពុជា

ដោយនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិនៃធនាគារជាតិនៃកម្ពុជា

## សេចក្តីផ្តើម

កំណើនសកម្មភាពសេដ្ឋកិច្ច ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងការអភិវឌ្ឍប្រព័ន្ធធនាគារក្នុងរយៈពេលជិត ២ ទសវត្សរ៍ចុងក្រោយនេះ បានបង្កើនតម្រូវការនិងជំនឿទុកចិត្តលើប្រាក់រៀលជាលំដាប់ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនរូបិយវត្ថុក្នុងចរាចរណ៍ជាមធ្យមប្រមាណ ១៧% ក្នុងមួយឆ្នាំ (ពី ១៣៥,៣ លានដុល្លារអាមេរិក ដល់ ១.៤៧៣ លានដុល្លារអាមេរិក) ។

ទោះជាយ៉ាងណាក៏ដោយ សេដ្ឋកិច្ចកម្ពុជានៅតែបន្តមានកម្រិតដុល្លារូបនីយកម្មខ្ពស់ក្នុងអត្រា ៨៤% (FCD/M2) គិតត្រឹមត្រីមាសទី២ ឆ្នាំ២០១៥នេះ បន្ទាប់ពីមាននិន្នាការកើនឡើងចាប់តាំងពីដើមទសវត្សរ៍ ១៩៩០ មក ។ កម្រិតដុល្លារូបនីយកម្មខ្ពស់នេះ កើតឡើងស្របពេលដែលកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រមាណ ៧,៧% ក្នុងរយៈពេល ២ ទសវត្សរ៍ចុងក្រោយនេះ ក្នុងបរិការណ៍ដែលស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចត្រូវរក្សាបានយ៉ាងល្អប្រសើរ អតិផរណាមានកម្រិតជាមធ្យម ៤% និងអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារមានស្ថិរភាពក្នុងរង្វង់ ៤០០០ រៀល/ដុល្លារអាមេរិក ។

កន្លងមក ការផ្គត់ផ្គង់ប្រាក់រៀលត្រូវបានធ្វើឡើងក្នុងទំហំសមស្របដែលបានរក្សាអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកឱ្យមានស្ថិរភាពយ៉ាងល្អប្រសើរ ។ ថ្មីៗនេះអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិក៏បានវាយតម្លៃខ្ពស់ពីការអនុវត្តគោលនយោបាយអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជាថា អត្រាប្តូរប្រាក់បានស្ថិតនៅក្នុងកម្រិតដែលកំណត់ដោយមូលដ្ឋានសេដ្ឋកិច្ច ។ ការផ្គត់ផ្គង់ប្រាក់រៀលទៅក្នុងសេដ្ឋកិច្ចត្រូវបានធ្វើឡើងជាចម្បងតាមរយៈការធ្វើអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជានៅក្នុងទីផ្សារប្តូរប្រាក់ ដោយការលក់ប្រាក់រៀលទល់នឹងដុល្លារអាមេរិកជាមួយអាជីវករប្តូរប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ នៅពេលដែលទំហំសេដ្ឋកិច្ចវិស័យហិរញ្ញវត្ថុ ជាពិសេសទីផ្សារប្តូរប្រាក់កាន់តែធំ ការបន្តអនុវត្តរបៀបធ្វើអន្តរាគមន៍បច្ចុប្បន្នអាចបង្កើតនូវអតុល្យភាពក្នុងទីផ្សារប្តូរប្រាក់ក៏ដូចជាផ្គត់ផ្គង់ប្រាក់រៀលមិនស្របតាមមូលដ្ឋានសេដ្ឋកិច្ច ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានខិតខំប្រឹងប្រែងបង្កើនឧបករណ៍គោលនយោបាយរូបិយវត្ថុ តាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរបាននៅឆ្នាំ២០១៣ ប៉ុន្តែឧបករណ៍ថ្មីនេះមិនទាន់រីកចម្រើនខ្លាំងនៅឡើយទេ ។

បច្ចុប្បន្ន ការធ្វើអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជាមិនទាន់មានលក្ខណៈសកម្មនៅឡើយទេ ដោយធនាគារជាតិនៃកម្ពុជាលក់ប្រាក់រៀលឆ្លើយតបនឹងការស្នើសុំទិញរបស់អាជីវករប្តូរប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ដើម្បីឈានទៅធ្វើអន្តរាគមន៍កាន់តែមានប្រសិទ្ធភាពនៅក្នុងកម្រិតសមស្រប ការធ្វើអន្តរាគមន៍គួរគិតគូរឱ្យបានហ្មត់ចត់លើកត្តាសំខាន់ៗ ដូចជា ១/-កំណើនបរិមាណផ្គត់ផ្គង់ទូទៅ (គិតទាំងការផ្គត់ផ្គង់ប្រាក់ដុល្លារអាមេរិក) ២/-កំណើនសកម្មភាពសេដ្ឋកិច្ច ៣/-ការស្រូបយកប្រាក់រៀលរបស់មូលបត្រអាចជួញដូរបាននិងសំណល់ប្រាក់រៀល និង៤/-ទំនាក់ទំនងការធ្វើអន្តរាគមន៍ជាមួយនឹងអត្រាប្តូរប្រាក់និងអញ្ញត្តិផ្សេងៗ ។ ជារួមការធ្វើអន្តរាគមន៍ដែលធ្វើឡើងស្របទៅ តាមតម្រូវការពិតប្រាកដរបស់សេដ្ឋកិច្ចនឹងបន្ថយបច្ច័យអវិជ្ជមាន ដែលបណ្តាលឱ្យបាត់បង់លំនឹងអត្រាប្តូរប្រាក់ និងស្ថិរភាពថ្លៃដែលជាធាតុចម្បងក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។

ឯកសារស្រាវជ្រាវនេះមានគោលបំណងវិភាគលើយន្តការបច្ចុប្បន្ន ក្នុងការចាក់បញ្ចូលប្រាក់រៀលទៅក្នុងសេដ្ឋកិច្ច និងពិនិត្យមើលទៅលើទំនាក់ទំនងរវាងការធ្វើអន្តរាគមន៍ទៅលើអត្រាប្តូរប្រាក់កំណើនរូបិយវត្ថុក្នុងចរាចរណ៍ និងសន្ទនីយភាពលើសក្នុងគោលដៅប៉ាន់ស្មានកម្រិតសមស្របក្នុងការធ្វើអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា ។

## លំហូរនៃការចាក់បញ្ចូលប្រាក់ទៅក្នុងសេដ្ឋកិច្ច

ការចាក់បញ្ចូលប្រាក់រៀលទៅក្នុងសេដ្ឋកិច្ចអាចត្រូវបានធ្វើឡើងក្រោមរូបភាពដូចជា៖ ១). អន្តរាគមន៍លក់ប្រាក់រៀលសុទ្ធ ២).ការលក់ប្រាក់រៀលសុទ្ធជូនរាជរដ្ឋាភិបាល ឬ ៣).ការបើកប្រាក់បៀវត្សជូនមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ។ ការធ្វើអន្តរាគមន៍លក់ប្រាក់រៀលសុទ្ធអាចត្រូវបានធ្វើឡើងជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់ ។ តាមរយៈការធ្វើអន្តរាគមន៍នេះ ប្រាក់រៀលត្រូវបានចាក់បញ្ចូលក្នុងចរាចរណ៍ ដែលមួយផ្នែកកាន់ដោយភ្នាក់ងារសេដ្ឋកិច្ចមិនមែនស្ថាប័នហិរញ្ញវត្ថុ និងមួយផ្នែកទៀតរក្សាទុកនៅក្នុងប្រព័ន្ធធនាគារក្នុងរូបភាពជាសន្ទនីយភាពលើសរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុជា៖ ទុនបម្រុងលើស មូលបត្រអាចជួញដូរបាន ប្រាក់បញ្ញើមានកាលកំណត់ និងគណនីទូទាត់ ។ ប្រាក់រៀលអាចត្រូវបានស្រូបយកដោយភ្នាក់ងារផ្សេងៗទៀត ដើម្បីឆក់ឱកាសកេងចំណេញពីការប្រែប្រួលអត្រាប្តូរប្រាក់ ។ ចំណែកការលក់ប្រាក់រៀលសុទ្ធជូនរាជរដ្ឋាភិបាលត្រូវបានប្រើប្រាស់លើចំណាយសាធារណៈផ្សេងៗ ហើយសមតុល្យដែលនៅសល់អាចត្រូវបានរក្សាក្នុងគណនីប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល ។ ដោយឡែកសាច់ប្រាក់ដែលត្រូវបានបញ្ចេញទៅលើទីផ្សារក្រោមរូបភាពជាប្រាក់បៀវត្សអាចត្រូវបានកាន់ជាសាច់ប្រាក់សុទ្ធដោយអង្គភាពគ្រួសារ ដើម្បីទុកប្រើប្រាស់ប្រចាំថ្ងៃ ឬដាក់ក្នុងគណនីប្រាក់បញ្ញើនៅគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។

### រូបភាពខាងក្រោមបង្ហាញពីទំនាក់ទំនងនៃលំហូរសាច់ប្រាក់ខាងលើដោយសង្ខេប៖




## I. ការផ្គត់ផ្គង់រូបិយវត្ថុទូទៅនៅកម្ពុជា

### ១. កំណើនរូបិយវត្ថុទូទៅ [1]

រូបិយវត្ថុទូទៅបានកើនឡើងពី ១៩,៥ ពាន់ពាន់លានរៀល (៤១% នៃផ.ស.ស) នៅឆ្នាំ២០១០ ដល់ ៤២,៦ ពាន់ពាន់លានរៀល (៦២% នៃផ.ស.ស) គឺបានកើនជាមធ្យម ២៣% ។ ក្នុងនោះប្រាក់បញ្ញើជារៀលបានកើនឡើងជាមធ្យមក្នុងកម្រិតខ្ពស់ប្រមាណ ៣៥% ក្នុងមួយឆ្នាំ ។ ប្រាក់បញ្ញើជារូបិយប័ណ្ណ ដែលមានសមាមាត្ររហូតដល់

| | M2 | COB | KHRD | FCD | CPI% |
|---|---|---|---|---|---|
| 2004 | 28.7% | 20.8% | 12.8% | 33.0% | 3.9% |
| 2005 | 20.0% | 15.7% | 13.5% | 22.0% | 6.3% |
| 2006 | 31.6% | 25.8% | -0.9% | 35.1% | 6.2% |
| 2007 | 47.1% | 17.9% | 10.3% | 57.7% | 7.6% |
| 2008 | 38.3% | 31.8% | 42.4% | 40.3% | 25.1% |
| 2009 | 13.7% | 14.9% | 59.2% | 12.4% | -0.4% |
| 2010 | 31.5% | 14.6% | 44.6% | 35.1% | 4.0% |
| 2011 | 19.4% | 14.9% | 20.9% | 20.3% | 5.5% |
| 2012 | 21.0% | 8.7% | 56.8% | 22.2% | 3.0% |
| 2013 | 16.5% | 15.5% | 23.5% | 16.6% | 2.9% |
| 2014 | 24.7% | 16.2% | 29.4% | 26.0% | 3.9% |
| 2015-S1 | 24.8% | 23.1% | 25.2% | 25.1% | 2.0% |
| **Average2010-2014** | **22.6%** | **14.0%** | **35.0%** | **24.0%** | **3.9%** |

[1] (M2 = រូបិយវត្ថុទូទៅ) (COB = រូបិយវត្ថុក្រៅប្រព័ន្ធធនាគារ) (KHRD = ប្រាក់បញ្ញើជារៀល)
(FCD = ប្រាក់បញ្ញើជារូបិយប័ណ្ណ) និង (CPI% = អតិផរណា) ។

៨២% នៃរូបិយវត្ថុទូទៅសរុបក៏មានកំណើនខ្ពស់ផងដែរប្រមាណ ២៤%។ ចំណែករូបិយវត្ថុនៅក្រៅប្រព័ន្ធធនាគារមានកំណើនប្រមាណតែ ១៤% ប៉ុណ្ណោះក្នុងមួយឆ្នាំ ។

**២. បញ្ហាដុល្លាររូបនីយកម្ម**

យោងតាមជញ្ជីងទូទាត់របស់កម្ពុជា ២០១០-២០១៤ ប្រភពចំណូលផ្លូវការជាមធ្យមប្រចាំឆ្នាំជាដុល្លារអាមេរិកដែលហូរចូលមកកម្ពុជាជាចម្បងរួមមានៈ ចំណូលពីការនាំចេញ (៥.៧០៤ លានដុល្លារ) ចំណូលពីវិស័យសេវាកម្ម (៣.០៥០លានដុល្លារ) ជាពិសេសវិស័យទេសចរណ៍ ចំណូលសុទ្ធពីការបង្វែរចរន្ត (រដ្ឋាភិបាល និងឯកជន) (៥២១លានដុល្លារ) ។ កម្ពុជាក៏ទទួលបានលំហូរមូលធនជាច្រើនក្នុងមួយឆ្នាំៗផងដែរ គឺពីការវិនិយោគផ្ទាល់បរទេស និងលំហូរចូលសុទ្ធតាមរយៈការបង្វែរមូលធនរបស់រដ្ឋាភិបាលនិងវិស័យឯកជនជាមធ្យមប្រមាណ ១.៦៦៦ លានដុល្លារ។ លំហូរចូលនៃប្រាក់ដុល្លារទាំងនេះ គឺមិនបានរាប់បញ្ចូលលំហូរក្រៅផ្លូវការដែលពិបាកក្នុងការប៉ាន់ស្មាន និងដែលអាចមានទំហំធំ ។




ទន្ទឹមនេះ កម្ពុជាក៏ត្រូវចំណាយជារូបិយប័ណ្ណទៅក្រៅប្រទេសវិញផងដែរដូចជាការចំណាយលើការនាំចូលមធ្យមប្រចាំឆ្នាំ (២០១០-២០១៤) ៨.២៨៨ លានដុល្លារ ចំណាយលើសេវាកម្ម ១.៤៩៨ លានដុល្លារ និងការបង្វែររូបិយប័ណ្ណចេញតាមរយៈប្រព័ន្ធធនាគារ និងក្រៅផ្លូវការ ។

ចាប់ពីឆ្នាំ ២០១០-២០១៤ កម្ពុជាទទួលបានលំហូរចូលសុទ្ធនៃរូបិយប័ណ្ណដែលឆ្លុះបញ្ចាំងដោយឧត្តមភាពសមតុល្យរួមជញ្ជីងទូទាត់ជាមធ្យមក្នុងមួយឆ្នាំៗប្រមាណ ៣៨៧ លានដុល្លារអាមេរិក ។ ក្នុងករណីគ្មានដុល្លារូបនីយកម្មលំហូរចូលនៃរូបិយប័ណ្ណនេះភាគច្រើន ឬទាំងអស់នឹងត្រូវប្តូរជារូបិយវត្ថុប្រើប្រាស់ក្នុងសេដ្ឋកិច្ច ។ ក៏ប៉ុន្តែដោយកម្ពុជាមានកម្រិតដុល្លាររូបនីយកម្មខ្ពស់មួយភាគធំនៃលំហូររូបិយប័ណ្ណ (ដុល្លារអាមេរិក) ទាំងនេះ ត្រូវប្រើប្រាស់ដោយផ្ទាល់នៅក្នុងសេដ្ឋកិច្ច ហើយមានតែមួយផ្នែកតូចប៉ុណ្ណោះត្រូវបានប្តូរជារូបិយវត្ថុដែលកត្តានេះ បានបង្កើតជាតម្រូវការប្រាក់រៀល អាស្រ័យទៅលើការប្រើប្រាស់ចាំបាច់ ជាពិសេស ការបង់ពន្ធ ការទូទាត់ទំនិញ និងសេវាមួយចំនួន ដែលបានតម្រូវឱ្យធ្វើឡើងជារៀល (ដូចជាការបង់ទឹក-ភ្លើង) និងការទូទាត់ប្រតិបត្តិការតូចៗមួយចំនួន ។

**II. តម្រូវការ និងការផ្គត់ផ្គង់ប្រាក់រៀល**

**១. កត្តាតម្រូវការប្រាក់រៀល**

**ក. កត្តាជំរុញកំណើនតម្រូវការប្រាក់រៀល**

ការរក្សាបានបរិស្ថានម៉ាក្រូសេដ្ឋកិច្ចល្អប្រសើរជាមួយនឹងកំណើនប្រមាណ ៧% ក្នុងមួយឆ្នាំក្នុងរយៈពេលជាង ១ ទសវត្សរ៍ចុងក្រោយនេះ បានធ្វើឱ្យតម្រូវការប្រាក់រៀលមានការកើនឡើងជាលំដាប់ ក្នុងការដោះដូរ និងប្រើប្រាស់ប្រចាំថ្ងៃ ។ ជាក់ស្តែង រូបិយវត្ថុក្នុងចរាចរណ៍ដែលជាសូចនាករបង្ហាញពីតម្រូវការនិងការប្រើប្រាស់ប្រាក់រៀលក្នុងសេដ្ឋកិច្ចបានកើនឡើងជាមធ្យមប្រមាណ ១៥% ក្នុងមួយឆ្នាំ (២០១០-២០១៤) ។ ប្រាក់រៀលត្រូវបានប្រើប្រាស់

សម្រាប់ប្រតិបត្តិការចម្បងៗមួយចំនួន ដូចជា ការបង់ពន្ធ ការប្រមូលទិញកសិផលពីប្រជាកសិករការបង់ថ្លៃអគ្គិសនី និងទឹកស្អាតសម្រាប់ប្រើប្រាស់ ។




- **ចំណូលពន្ធ៖** គឺជាកត្តាស្នូលដែលបង្កើតតម្រូវការប្រាក់រៀលរបស់សាធារណជន ។ ចំណូលពន្ធរបស់រាជរដ្ឋាភិបាលបានកើនឡើងពី ៤.៦៩៣ ពាន់លានរៀលក្នុងឆ្នាំ២០១០ ដល់ ៩.០៩៦ ពាន់លានរៀល ក្នុងឆ្នាំ២០១៤ ដែលជាមធ្យមកើនឡើងប្រមាណ ១៥% ប្រចាំឆ្នាំ (២០១០-២០១៣) និងបានកើនឡើងខ្ពស់គួរឱ្យកត់សម្គាល់ដល់ ២៥% ក្នុងឆ្នាំ២០១៤ ។ គួរបញ្ជាក់ថា ប្រាក់រៀលគឺជារូបិយវត្ថុតែមួយគត់ដែលត្រូវបានប្រើប្រាស់សម្រាប់បង់ពន្ធ ដូចនេះកំណើននៃចំណូលពន្ធបានឆ្លុះបញ្ចាំងពីកំណើនតម្រូវការប្រាក់រៀលប្រមាណ១៥%ក្នុងមួយឆ្នាំ។




- **ទិន្នផលកសិកម្ម៖** វិស័យកសិកម្មត្រូវបានទទួលស្គាល់ថាជាវិស័យប្រើប្រាស់ប្រាក់រៀលស្ទើរតែទាំងស្រុង ជាពិសេស ការដោះដូររាយ ។ កសិផលចម្បងរបស់កម្ពុជាគឺ ការផលិតស្រូវ ដូច្នេះបម្រែបម្រួលទិន្នផលស្រូវអាចប្រើប្រាស់ជាសូចនាករមួយបង្ហាញពីបម្រែបម្រួលតម្រូវការប្រាក់រៀលនៅក្នុងវិស័យកសិកម្ម ។ ទិន្នផលស្រូវប្រចាំឆ្នាំទទួលបាន ២,៩៧ តោនក្នុងមួយហិកតានៅឆ្នាំ២០១០ និងបានកើនដល់ ៣,០៨ តោនក្នុងមួយហិកតានៅឆ្នាំ២០១៣ ។ រីឯបរិមាណផលសរុបក្នុងឆ្នាំ២០១០ សម្រេចបាន ៨,២៥ លានតោន និងបានកើនដល់ ៩,៣២ លានតានក្នុងឆ្នាំ២០១៤ ។ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ បរិមាណផលសរុបបានកើនឡើងជាមធ្យមប្រមាណ ៤% ក្នុងមួយឆ្នាំ ។ កំណើនទិន្នផលស្រូវក្នុងរយៈពេលនេះ បានឆ្លុះបញ្ចាំងពីកំណើនតម្រូវការប្រាក់រៀលដើម្បីប្រមូលទិញកសិផលពីប្រមាណ ២,៧[2] ពាន់ពាន់លានរៀលនៅឆ្នាំ២០១០ ដល់ ៤,១ ពាន់ពាន់លានរៀលនៅឆ្នាំ២០១៤ ពោលគឺ បាន

---

[2]តម្រូវការប្រាក់រៀលដើម្បីទិញកសិផលត្រូវបានគណនាដោយប្រើប្រាស់តម្លៃស្រូវលើទីផ្សារគុណនឹងបរិមាណស្រូវដែលប្រមូលផលបានដកនឹងបរិមាណស្រូវដែលប្រើប្រាស់និងស្រូវនៅសល់ ។
តម្រូវការប្រាក់រៀល = ថ្លៃស្រូវ * (បរិមាណស្រូវសរុប - បរិមាណស្រូវប្រើប្រាស់ - បរិមាណស្រូវនៅសល់)

កើនជាមធ្យមប្រមាណ ១៤% ។ ទោះជាយ៉ាងនេះក្តី កំណើនបរិមាណផលស្រូវមាននិន្នាការថយចុះជាលំដាប់ក្នុងរយៈពេល ៥ឆ្នាំ ចុងក្រោយនេះ ជាពិសេស នៅឆ្នាំ២០១៤ ដោយសារអាកាសធាតុមិនអំណោយផល (រាំងស្ងួតនៅដើមរដូវ និងទឹកជំនន់ពាក់កណ្តាលរដូវ) ដែលបានជះឥទ្ធិពលអវិជ្ជមានដល់ការបង្កបង្កើនផល ។ ស្ថានភាពនេះបានធ្វើឱ្យតម្រូវការប្រាក់រៀលសម្រាប់ទិញកសិផលពីប្រជាកសិករក៏ថយចុះ ៨% នៅឆ្នាំ២០១៤ ។ គួរកត់សម្គាល់ថាក្នុងរយៈពេល ៥ឆ្នាំ ចុងក្រោយនេះវិស័យកសិកម្មមានកំណើនជាមធ្យម ២,៦% ដែលក្នុងនោះការដាំដុះ ការចិញ្ចឹមសត្វ និងការនេសាទដែលតំណាងឱ្យប្រមាណ ៩០% នៃទិន្នផលវិស័យកសិកម្មទាំងមូល អាចជាផ្នែកដែលប្រើប្រាស់ប្រាក់រៀលភាគច្រើន។




- **ការប្រើប្រាស់ថាមពលអគ្គិសនីនិងទឹកស្អាត៖** ថ្លៃប្រើប្រាស់ថាមពលអគ្គិសនីនិងទឹកស្អាតត្រូវបានកំណត់ឱ្យទូទាត់ជាប្រាក់រៀលតែមួយប៉ុណ្ណោះ ។ ស្របពេលដែលសកម្មភាពសេដ្ឋកិច្ចមានការរីកចម្រើនឥតឈប់ឈរជារៀងរាល់ថ្ងៃ តម្រូវការប្រើប្រាស់ថាមពលអគ្គិសនី និងទឹកស្អាតក៏មានការកើនឡើងជាលំដាប់ ។ ជាក់ស្តែងចំណូលសរុបដែលអគ្គិសនីកម្ពុជាទទួលបាននៅក្នុងឆ្នាំ២០១៣ មានប្រមាណ ២.៦៧៤ ពាន់លានរៀល កើនពីប្រមាណ ១.៥៩៩ ពាន់លានរៀល នៅឆ្នាំ២០១០ ពោលគឺបានកើនជាមធ្យមប្រមាណ ២២% ក្នុងមួយឆ្នាំ ។ រីឯចំណូលសរុបរបស់រដ្ឋាករទឹកស្វយ័តភ្នំពេញបានកើនពីប្រមាណ ១០៦,៣ ពាន់លានរៀល នៅឆ្នាំ២០១០ ដល់១៥១,៦ ពាន់លានរៀល នៅឆ្នាំ២០១៤ គឺបានកើនឡើងជាមធ្យមប្រមាណ ៨% ក្នុងមួយឆ្នាំ ។ ស្ថានភាពនេះបង្ហាញថា តម្រូវការប្រាក់រៀលសម្រាប់បង់ថ្លៃថាមពលអគ្គិសនី និងទឹកស្អាតមានការកើនឡើងជាមធ្យម ២២% និង ៨% ក្នុងមួយឆ្នាំរៀងគ្នា ។






**-កត្តាផ្សេងៗ៖**

**កំណើនសកម្មភាពសេដ្ឋកិច្ច**

ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ កម្ពុជាមានកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំប្រមាណ ៧% (២.៣០៩ ពាន់លានរៀល) ដែលរួមចំណែកដោយវិស័យកសិកម្ម ០,៧% (២៣៤ ពាន់លានរៀល) វិស័យសេវាកម្ម ២,៦% (៨៦៥ពាន់លានរៀល) និងវិស័យឧស្សាហកម្ម ៣,២% (១.០៥៤ ពាន់លានរៀល) ។ វិស័យកសិកម្មមានកំណើនជាមធ្យម ២,៦% ខណៈដែលវិស័យសេវាកម្ម និងឧស្សាហកម្មមានកំណើន ៦,៨% និង ១១,៦% រៀងគ្នា ។




ក្នុងវិស័យឧស្សាហកម្មដែលមានវិស័យកាត់ដេរជាចម្បង ថ្វីត្បិតតែចំណូល និងប្រាក់ខែរបស់ កម្មករក្នុងវិស័យនេះជាប្រាក់ដុល្លារអាមេរិក ការចំណាយរបស់កម្មករមិនមែនជាប្រាក់ដុល្លារអាមេរិកទាំងអស់នោះទេ ព្រោះការចំណាយទៅលើម្ហូបអាហារ និងទៅលើផ្នែកខ្លះទៀតធ្វើឡើងជាប្រាក់រៀល ។ ម្យ៉ាងវិញទៀត វិស័យសំណង់ដែលជាផ្នែកមួយនៃវិស័យឧស្សាហកម្មដែរនោះ ក៏មានតម្រូវការប្រាក់រៀលច្រើនសម្រាប់បើកប្រាក់ឈ្នួល ដល់កម្មករផងដែរ[3] ។ ដោយឡែក វិស័យសេវាកម្មក៏មានមួយផ្នែកតូចដែលប្រើប្រាស់ប្រាក់រៀល គឺចំណាយសាធារណៈដែលមានប្រមាណ ១៤% នៃវិស័យសេវាកម្មក្នុងនោះ មានដូចជាការបើកប្រាក់បៀវត្សដល់មន្ត្រីរាជការ និងចំណាយលើផលិតកម្មសាធារណៈផ្សេងទៀត ។

**- កំណើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល**

[3] យោងតាមក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ វិស័យសំណង់ទូទាំងប្រទេសប្រើប្រាស់កម្លាំងពលកម្មចំនួន ៦០.០០០ នាក់ក្នុងមួយថ្ងៃ ។ ជាក់ស្តែង អ្នកម៉ៅការក្នុងវិស័យនេះផ្តល់ប្រាក់ឈ្នួលជារៀលដល់កម្មករ ក្នុងនោះ កម្មករមានជំនាញទទួលបានក្នុងចន្លោះ ២៨.០០០ - ៣២.០០០ រៀល និងកម្មករគ្មានជំនាញទទួលបានក្នុងចន្លោះ ២០.០០០ - ៣០.០០០ រៀល ។ ដូចនេះ ជាមធ្យមតម្រូវការប្រាក់រៀលអាចមានប្រមាណ ២,២ ពាន់លានរៀលក្នុងមួយថ្ងៃ (៥៥០ ពាន់ដុល្លារអាមេរិក) ។

ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយគាំទ្រកំណើនរបស់រាជរដ្ឋាភិបាលក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ បានពង្រឹងជំនឿទុកចិត្តសាធារណជនមកលើប្រាក់រៀលជាលំដាប់ ។ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបានបន្តមានស្ថិរភាពល្អប្រសើរ ខណៈដែលអត្រាអតិផរណាត្រូវបានរក្សាឱ្យស្ថិតនៅកម្រិតទាបជាមធ្យមប្រមាណ ៤% ដែលធានាបានស្ថិរភាពថ្លៃនិងអំណាចទិញរបស់ប្រាក់រៀល ។ កំណើនជំនឿទុកចិត្តនេះបានរួមចំណែកយ៉ាងចម្បងដល់ការបង្កើនការប្រើប្រាស់ប្រាក់រៀលរយៈពេលកន្លងមក ។ ជាក់ស្តែង រូបិយវត្ថុក្នុងចរាចរណ៍បានកើនឡើងជាបន្តបន្ទាប់គឺពី ១៨៤ ពាន់លានរៀលនៅចុងឆ្នាំ១៩៩៤ ទៅប្រមាណ ៥.៩៨៥ ពាន់លានរៀលនៅឆ្នាំ២០១៤ (កំណើនមធ្យម ១៨,៣%) ស្របពេលដែលប្រាក់បញ្ញើជារៀលបានកើនឡើងពី ១៣៥ ពាន់លានរៀល ទៅ ១.៨០៥ ពាន់លានរៀល (កំណើនមធ្យម ២៥,៦%) ក្នុងអំឡុងពេលដូចគ្នានេះ ។




**- កត្តារដូវកាលនៃតម្រូវការប្រាក់រៀល**

ជាទូទៅ តម្រូវការប្រាក់រៀលតែងតែប្រែប្រួលទៅតាមកត្តារដូវកាលដែលក្នុងនោះមាន i/.ការបង់ពន្ធ ii/.ការប្រមូលផល និង iii/.ពិធីបុណ្យប្រពៃណី និងបុណ្យជាតិផ្សេងៗ ។




• ការបង់ពន្ធ៖ រយៈពេលនៃការបង់ពន្ធធ្វើឡើងអាស្រ័យទៅតាមប្រភេទពន្ធដែលមានដូចជា៖ ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក ពន្ធប៉ាតង់ ពន្ធលើប្រាក់ចំណេញ ពន្ធលើមធ្យោបាយដឹកជញ្ជូនជាដើម ។ ការណ៍នេះបានធ្វើឱ្យតម្រូវការប្រាក់រៀលសម្រាប់បង់ពន្ធប្រែប្រួលទៅតាមពេលវេលាដែលបុគ្គល និងក្រុមហ៊ុន សហគ្រាសត្រូវបង់ពន្ធ ។ ជាក់ស្តែង តម្រូវការប្រាក់រៀលសម្រាប់បង់ពន្ធកើនឡើងគួរឱ្យកត់សម្គាល់នៅរៀងរាល់ខែមេសា និងខែធ្នូ ហើយក៏ជារយៈពេលដែលតម្លៃប្រាក់រៀលនៅលើទីផ្សារមានការកើនឡើង ។

• ការប្រមូលផល៖ ការប្រមូលកសិផលរបស់ប្រជាកសិករចាប់ពីខែវិច្ឆិកាដល់ខែកុម្ភៈបានធ្វើឱ្យតម្រូវការ

ប្រាក់រៀលកើនឡើងជារៀងរាល់ឆ្នាំព្រោះការទិញលក់កសិផលធ្វើឡើងភាគច្រើនជាប្រាក់រៀល ។ ការទិញលក់កសិផលនឹងផ្អាកនៅពេលដែលបញ្ចប់រដូវប្រមូលផល ដែលនាំឱ្យកំណើនតម្រូវការប្រាក់រៀលមានការថយចុះវិញ ។

• ពិធីបុណ្យជាតិៈ ពិធីបុណ្យប្រពៃណីនិងបុណ្យជាតិធំៗដែលធ្វើឱ្យតម្រូវការប្រាក់រៀលកើនឡើង រួមមាន ចូលឆ្នាំចិន-វៀតណាម (មករា-កុម្ភៈ) បុណ្យចូលឆ្នាំប្រពៃណីខ្មែរ (មេសា) បុណ្យភ្ជុំបិណ្ឌ (កញ្ញា-តុលា) បុណ្យអុំទូក (វិច្ឆិកា) ។ ក្នុងឱកាសទាំងនេះ ប្រជាជនខ្មែរ និងបង្កើនចំណាយទៅលើការធ្វើដំណើរ ម្ហូបអាហារ និងការធ្វើបុណ្យទានផ្សេងៗជាប្រាក់រៀល ។

## ខ. អនុគមន៍តម្រូវការប្រាក់រៀល

ក្នុងការសិក្សានេះ តម្រូវការប្រាក់រៀលត្រូវបានប៉ាន់ស្មានដោយរូបិយវត្ថុក្នុងចរាចរ និងជាអនុគមន៍នឹង ផ.ស.ស ចំណូលពន្ធប្រាក់បៀវត្សមន្ត្រីធនាគារជាតិនៃកម្ពុជា អត្រាការប្រាក់កម្ចីជារៀលរយៈពេល ៣ខែអតិផរណា និងអត្រាប្តូរប្រាក់ ។ សូចនាករទាំងនេះត្រូវបានជ្រើសរើសសម្រាប់ការវិភាគ ដោយសារកំណើនសេដ្ឋកិច្ច និងចំណូលពន្ធ ជំរុញតម្រូវការប្រាក់រៀលដើម្បីប្រើប្រាស់នៅក្នុងសកម្មភាពសេដ្ឋកិច្ច ជាពិសេស សម្រាប់ការបង់ពន្ធ និងបើកប្រាក់បៀវត្សដល់មន្ត្រីធនាគារជាតិនៃកម្ពុជា ។ ចំណែកឯ កំណើនអត្រាការប្រាក់ អត្រាអតិផរណា និងអត្រាប្តូរប្រាក់អាចកាត់បន្ថយតម្រូវការប្រាក់រៀល ដោយសារការកើនឡើងនៃអត្រាទាំងបី បណ្តាលឱ្យមានការកើនឡើងថ្លៃដើមសម្រាប់អ្នកវិនិយោគ ។

| សូចនាករ | ការគណនាសូចនាករ | ពិពណ៌នា |
|---|---|---|
| LCIC | Log(CIC) | តម្រូវការប្រាក់រៀល |
| LGDP | Log(GDP) | ផ.ស.ស |
| LTAX | Log(Tax Revenue) | ចំនូលពន្ធ |
| LNBCSALARY | Log(NBC Salary) | ប្រាក់ខែបុគ្គលិកធនាគារជាតិ |
| Inflation | Dlog(CPI) | អតិផរណា |
| LEXC | Log(Exchange rate) | អត្រាប្តូរប្រាក់ |
| LOANKHR3M | | អត្រាកម្ចី៣ខែជារៀល |

LCIC= f(LGDP, LTAX, LNBCSALARY , Inflation , LEXC, LOANKHR3M) (ម៉ូឌែល១)

ការសិក្សានេះ ធ្វើឡើងដោយពិនិត្យទៅលើទំនាក់ទំនង (Correlation) រវាងតម្រូវការប្រាក់រៀលជាមួយនឹងសូចនាករផ្សេងៗ ទិសដៅដែលអថេរអាចមានឥទ្ធិពលលើគ្នា (Granger Causality) ទំនាក់ទំនងរយៈពេលវែង រវាងតម្រូវការប្រាក់រៀលជាមួយនឹងសូចនាករផ្សេងៗ (Cointegration) និងកម្រិតនៃទំនាក់ទំនងរវាងតម្រូវការប្រាក់រៀលជាមួយនឹងសូចនាករនិមួយៗ (VECM) ។

| Correlation: | LCIC | LGDP | LTAX | LNBCSALARY | INF | LEXC | LOANKHR3M |
|---|---|---|---|---|---|---|---|
| LCIC | 1 | | | | | | |
| LGDP | 0.99 | 1 | | | | | |
| LTAX | 0.89 | 0.88 | 1 | | | | |
| LNBCSALARY | 0.97 | 0.98 | 0.90 | 1 | | | |
| INF | -0.19 | -0.25 | -0.12 | -0.21 | 1 | | |
| LEXC | -0.25 | -0.25 | -0.38 | -0.37 | -0.11 | 1 | |
| LOANKHR3M | -0.58 | -0.62 | -0.57 | -0.65 | 0.12 | 0.51 | 1 |

យោងតាមការសិក្សារកទំនាក់ទំនង (Correlation) រវាងតម្រូវការប្រាក់រៀលជាមួយសូចនាករផ្សេងៗ បានបង្ហាញថា ផ.ស.ស ប្រាក់ខែបុគ្គលិកធនាគារនិងចំនូលពន្ធមានទំនាក់ទំនងវិជ្ជមានជាមួយតម្រូវការប្រាក់រៀល ចំណែកឯ អត្រាកម្ចី ៣ខែ ជារៀល អតិផរណា និងអត្រាប្តូរប្រាក់មានទំនាក់ទំនងអវិជ្ជមាន ។

យោងតាមតារាងទី១ ក្នុងឧបសម្ព័ន្ធការវិភាគរកទិសដៅដែលអថេរអាចមានទំនាក់ទំនងលើគ្នា (Granger

Causality) បង្ហាញថា ផ.ស.ស និងអត្រាប្តូរប្រាក់មានទំនាក់ទំនងអាចព្យាករណ៍កម្រិតនៃតម្រូវការប្រាក់រៀលបាន ។ ចំណែកឯប្រាក់ខែបុគ្គលិកធនាគារជាតិ ចំណូលពន្ធ អតិផរណា និងអត្រាកម្ចី ៣ខែ ជារៀលមិនមានភស្តុតាងច្បាស់សម្រាប់បង្ហាញថាមានទំនាក់ទំនងអាចព្យាករណ៍កម្រិតនៃតម្រូវការប្រាក់រៀលទេ ។

ការធ្វើតេស្តរកទំនាក់ទំនងរយៈពេលវែង រវាងតម្រូវការប្រាក់រៀលជាមួយសូចនាករផ្សេងៗ (Cointegration test) បង្ហាញថាតម្រូវការប្រាក់រៀលនិងសូចនាករផ្សេងៗមានឥទ្ធិពលលើគ្នា ។ ដោយសារតែសូចនាករទាំងអស់នេះមានឥទ្ធិពលលើគ្នាក្នុងរយៈពេលវែង Vector auto regressive error correction model (VECM) ត្រូវបានប្រើដើម្បីរកកម្រិតនៃទំនាក់ទំនងរបស់សូចនាករនីមួយៗមកលើតម្រូវការប្រាក់រៀល (សូមមើលតារាងទី២ក្នុងឧបសម្ព័ន្ធ)។

| Error Correction Model: Dependent variable: $\Delta CIC$ | | | | | | | |
|---|---|---|---|---|---|---|---|
| CointEq | $\Delta CIC(-1)$ | $\Delta GDP(-1)$ | $\Delta TAX(-1)$ | $\Delta NBCSalary(-1)$ | $\Delta Exch(-1)$ | $\Delta LoanKHR3m(-1)$ | INF |
| -0.01*** | 0.11 | 2.09*** | 0.04* | -0.23 | -0.55 | 0.103 | 0.2 |
| [0.01] | [0.29] | [0.01] | [0.08] | [0.71] | [0.3] | [0.75] | [0.38] |

Note: p-value is in the [ ] *** 1% significant

ការធ្វើតេស្តរកកម្រិតនៃឥទ្ធិពលរបស់សូចនាករនិមួយៗមកលើតម្រូវការប្រាក់រៀល ដែលបានបង្ហាញក្នុងតារាងខាងលើឃើញថា ផ.ស.ស និងចំនូលពន្ធជាកត្តាសំខាន់ដែលអាចមានទំនាក់ទំនង និងឥទ្ធិពលលើតម្រូវការប្រាក់រៀលបាន ខណៈដែលប្រាក់ខែបុគ្គលិកធនាគារ អតិផរណា អត្រាប្តូរប្រាក់ និងអត្រាកម្ចី៣ខែជារៀលមិនមានទំនាក់ទំនងសំខាន់និងឥទ្ធិពលលើតម្រូវការប្រាក់រៀលទេ ។ យោងតាមតារាងវិភាគខាងលើប្រសិនបើរក្សាសូចនាករផ្សេងៗឲ្យនៅដដែល ផ.ស.ស មានកំណើន ១% តម្រូវការប្រាក់រៀលនឹងអាចមានកំណើនប្រមាណ ២,០៩%។ ដូចគ្នានេះដែរប្រសិនបើចំនូលពន្ធមានកំណើន ១% តម្រូវការប្រាក់រៀលអាចមានកំណើន ០,០៤% ។ ជារៀងរាល់ខែប្រសិនបើសូចនាករផ្សេងៗមិនមានការប្រែប្រួលនិងមិនមានការចាក់សាច់ប្រាក់បន្ថែមនៅក្នុងទីផ្សារទេ រូបិយវត្ថុក្នុងចរាចរនឹងថយចុះប្រមាណ ០,០១% ។ ការណ៍នេះអាចបណ្តាលមកពីសាច់ប្រាក់វិលត្រលប់ចូលក្នុងប្រព័ន្ធវិញ ឬការខូចខាតនៃក្រដាសប្រាក់ ។

ដោយឡែក ប្រាក់ខែបុគ្គលិកធនាគារជាតិ អតិផរណា អត្រាប្តូរប្រាក់ និងអត្រាកម្ចី ៣ខែជារៀលមិនមានទំនាក់ទំនងសំខាន់និងមិនមានឥទ្ធិពលលើតម្រូវការប្រាក់រៀលអាចបណ្តាលមកពី ១-/ប្រាក់ខែបុគ្គលិកធនាគារជាតិមានទំហំតូចធៀបជាមួយរូបិយវត្ថុក្នុងចរាចរ ដែលជាមធ្យមប្រចាំឆ្នាំមានប្រមាណ ០,៩៣% ប៉ុណ្ណោះ ២-/អតិផរណាត្រូវបានទទួលឥទ្ធិពលច្រើនពីដៃគូពាណិជ្ជកម្មនិងការប្រែប្រួលប្រាក់ដុល្លារ ៣-/អត្រាប្តូរប្រាក់មិនមែនជាសូចនាករកំណត់តម្រូវការប្រាក់រៀលទេនិង ៤-/អត្រាកម្ចី ៣ខែ ជារៀលមិនបានឆ្លុះបញ្ចាំងពីតម្រូវការប្រាក់រៀល ដោយសារកម្ចីប្រាក់រៀលមានតិចតួចជាមធ្យមប្រចាំឆ្នាំ ត្រឹមតែ ១,២១% នៃកម្ចីសរុប ។ ការខ្វះខាតទិន្នន័យដូចជាទិន្នន័យមានរយៈពេលខ្លី និងមិនមានទិន្នន័យប្រចាំខែឬត្រីមាសក៏ជាកត្តាចំបងដែលធ្វើឲ្យសូចនាករមិនមានទំនាក់ទំនងជាមួយតម្រូវការប្រាក់រៀលដែរ។

## ២. ភត្តាផ្គត់ផ្គង់ប្រាក់រៀល

ជាទូទៅ ការផ្គត់ផ្គង់ប្រាក់រៀលទៅក្នុងទីផ្សារបានធ្វើឡើងដោយមធ្យោបាយបីយ៉ាង៖ ១)-ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ២)-ការបើកប្រាក់បៀវត្សជូនមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា និង៣)-ប្រតិបត្តិការលក់ប្រាក់រៀលជូនរាជរដ្ឋាភិបាល ។ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ បរិមាណផ្គត់ផ្គង់ប្រាក់រៀលសុទ្ធបានកើនឡើងជាមធ្យមប្រមាណ ១២០%ពោលគឺបានកើនឡើងពី ៥៥២ ពាន់លានរៀលដល់ប្រមាណ ១.២២១ ពាន់លានរៀល ដែលក្នុងនោះធ្វើតាមរយៈ៖

-ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដែលមានទំហំទឹកប្រាក់រហូតដល់ ១.៣២៣ ពាន់លានរៀល ឬស្មើនឹង៩៧% (មានកំណើនមធ្យម១៤៥%) នៃបរិមាណទឹកប្រាក់ចាក់ចូលសរុប ។ បើធៀបនឹង ៥ឆ្នាំមុន ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ស្មើនឹងប្រមាណ ២,៥ដង និងស្មើនឹងប្រមាណ១៦ដង ធៀបនឹង១០ឆ្នាំមុន ។ ការកើនឡើងនេះបញ្ជាក់យ៉ាងច្បាស់នៃកំណើនតម្រូវការប្រាក់រៀលក្នុងសេដ្ឋកិច្ចជាតិ ក៏ដូចការកើនឡើងនូវជំនឿទុកចិត្តរបស់សាធារណជនមកលើរូបិយវត្ថុជាតិ ។

- ការបើកប្រាក់បៀវត្សជូនមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាមានទឹកប្រាក់ប្រមាណ ៤១ ពាន់លានរៀល ឬស្មើនឹង ៣% (មានកំណើនមធ្យម៨៤%) នៃបរិមាណទឹកប្រាក់ចាក់ចូលសរុប ដែលការកើនឡើងនេះ ដោយសារកំណើននៃចំនួនមន្ត្រីបុគ្គលិកបម្រើការងារនៅធនាគារជាតិនៃកម្ពុជាស្រប ពេលដែលប្រព័ន្ធធនាគារកម្ពុជាកាន់តែមានការរីកចម្រើនឡើង។

- ចំពោះប្រតិបត្តិការទិញ-លក់ប្រាក់រៀលជាមួយរដ្ឋាភិបាលមាននិន្នាការខុសប្លែកគ្នាធៀបនឹងរយៈពេល ១០ឆ្នាំមុន ដោយចាប់ពីឆ្នាំ ២០១០-២០១៤ ប្រតិបត្តិការនេះបានកាត់បន្ថយបរិមាណប្រាក់រៀលក្នុងសេដ្ឋកិច្ចប្រមាណ ១៤៣ ពាន់លានរៀល ឬស្មើនឹង ១០% នៃបរិមាណដែលបានចាក់បញ្ចូលសរុប ដែលធ្វើឡើងតាមរយៈការលក់ប្រាក់រៀលជូនធនាគារជាតិនៃកម្ពុជា ខណៈដែលចាប់ពីឆ្នាំ ២០០០-២០០៩ ការផ្គត់ផ្គង់បរិមាណប្រាក់រៀលតាមរយៈប្រតិបត្តិការរបស់រាជរដ្ឋាភិបាលបានបង្កើនប្រាក់រៀលក្នុងបរិមាណជាមធ្យម ១៥ ពាន់លានរៀលក្នុងមួយឆ្នាំ ។ គួរកត់សម្គាល់ផងដែរថា ការកើនឡើងនៃការលក់ប្រាក់រៀល ឬទិញប្រាក់ដុល្លារពីធនាគារជាតិនៃកម្ពុជាដោយរាជរដ្ឋាភិបាល ជាពិសេស ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គឺដោយសារកម្ពុជាដល់ពេលត្រូវសងការប្រាក់ជូនម្ចាស់បំណុលបរទេសនានា ។




គួរកត់សម្គាល់ផងដែរថា ក្នុងឆ្នាំ២០១៤ ការធ្វើអន្តរាគមន៍ចាក់ប្រាក់រៀលបានកើនឡើងខ្ពស់ជាងឆ្នាំកន្លងទៅដល់ ៣.២៤១ ពាន់លានរៀល (ស្មើនឹង ៧៩៥ លានដុល្លារអាមេរិក) ពី ១៣០០ ពាន់លានរៀល កើនឡើង ១៥០% ខណៈដែលប្រតិបត្តិការរដ្ឋាភិបាលបានស្រូបយកប្រាក់រៀលពីទីផ្សារកើនឡើងពីប្រមាណ ១៨១ ពាន់លានរៀល ដល់ ៥៨០ ពាន់លានរៀល ធៀបនឹងឆ្នាំ២០១៣ ។




## ៣. លំនឹងនៅលើទីផ្សារប្តូរប្រាក់

នៅលើទីផ្សារប្តូរប្រាក់ក៏ដូចជានៅលើទីផ្សារដទៃដែរ លំនឹងកើតឡើងនៅពេលដែលបរិមាណតម្រូវការស្មើនឹងបរិមាណផ្គត់ផ្គង់ ។ ក្នុងករណីតម្រូវការរូបិយវត្ថុមួយមានកម្រិតខ្ពស់(ទាប)ជាងបរិមាណផ្គត់ផ្គង់តម្លៃរបស់រូបិយវត្ថុនោះនឹងមាននិន្នាការកើនឡើង (ថយចុះ) ។ ប៉ុន្តែអ្វីដែលខុសប្លែកពីទីផ្សារដទៃ គឺតម្រូវការរបស់រូបិយវត្ថុមានការប្រែប្រួលយ៉ាងឆាប់រហ័ស និងពិបាកកំណត់ដោយសារតែមានកត្តាជាច្រើនទាំងក្នុងស្រុក និងអន្តរជាតិរួមចំណែកកំណត់តម្លៃរូបិយវត្ថុ ។ ចំណែកឯការផ្គត់ផ្គង់វិញ គឺអាស្រ័យលើគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាល ។ នៅកម្ពុជា ដុល្លារូបនីយកម្មខ្ពស់ បានធ្វើឱ្យធនាគារជាតិនៃកម្ពុជាអាចគ្រប់គ្រងមានដែនកំណត់ទៅលើប្រាក់ដុល្លារក្នុងចរាចរណ៍ ដែលជាផ្នែកធំនៃការផ្គត់ផ្គង់រូបិយវត្ថុសរុប ។ ការប្រែប្រួលអត្រាប្តូរប្រាក់នៅកម្ពុជាអាចបណ្តាលមកពីកត្តានានា (ក្នុងស្រុក) ដែលនាំឱ្យតម្លៃប្រាក់រៀលប្រែប្រួលនិងកត្តានានា (ទាំងក្នុងស្រុកនិងក្រៅស្រុក) លើប្រាក់ដុល្លារ ។ ដូច្នេះ ដើម្បីរក្សាលំនឹងរបស់ប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ធនាគារជាតិនៃកម្ពុជាជួបការលំបាកទ្វេដងធៀបនឹងករណីគ្មានដុល្លារូបនីយកម្ម ។

ទោះជាយ៉ាងណាក៏ដោយ ទំហំប្រាក់រៀលក្នុងចរាចរណ៍នៅមានកម្រិតទាបនៅឡើយធនាគារជាតិនៃកម្ពុជាបានធ្វើការគ្រប់គ្រងតម្លៃប្រាក់រៀលប្រកបដោយប្រសិទ្ធភាព តាមរយៈអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ ។ ការធ្វើអន្តរាគមន៍នេះគឺជាការឆ្លើយតបនឹងសេចក្តីត្រូវការរបស់ទីផ្សារ ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ។

ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចកើនឡើង ហើយទីផ្សារប្តូរប្រាក់កាន់តែធំ ការឆ្លើយតបក្នុងទម្រង់អកម្មបែបនេះនឹងមិនត្រឹមតែពីអាជីវករប្តូរប្រាក់ ឬគ្រឹះស្ថានធនាគារមួយចំនួនតូចទេ ដូច្នេះ ការស្វែងរកតម្រូវការពិតប្រាកដដើម្បីរក្សាលំនឹងឬកាត់បន្ថយការប្រែប្រួលអត្រាប្តូរប្រាក់ គឺជាបញ្ហាសំខាន់របស់ធនាគារជាតិនៃកម្ពុជានាពេលបច្ចុប្បន្ន។









## III. កត្តាផ្សេងៗដែលអាចមានឥទ្ធិពលមកលើអត្រាប្តូរប្រាក់

### ១. បម្រែបម្រួលតម្លៃប្រាក់ដុល្លារធៀបនឹងរូបិយប័ណ្ណនៃដៃគូពាណិជ្ជកម្មកម្ពុជា






**តារាងទំនាក់ទំនងនៃប្រាក់រៀល ប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម**

| | *រៀលធៀបនឹងដុល្លារ* | *បាតថៃធៀបនឹងដុល្លារ* | *ដុងវៀតណាមធៀបនឹងដុល្លារ* |
|---|---|---|---|
| *រៀលធៀបនឹងដុល្លារ* | *១* | | |
| *បាតថៃធៀបនឹងដុល្លារ* | *០,៣៩១០* | *១* | |
| *ដុងវៀតណាមធៀបនឹងដុល្លារ* | *-០,៣៥២៤* | *-០,៤៧៣៩* | *១* |

យោងតាមការគណនារកមេគុណនៃទំនាក់ទំនងអត្រាប្តូរនៃប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ប្រាក់បាតថៃធៀបនឹងដុល្លារអាមេរិក និងប្រាក់ដុងវៀតណាមធៀបនឹងដុល្លារអាមេរិកខាងលើបង្ហាញថា អត្រាប្តូរនៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក មានទំនាក់ទំនងវិជ្ជមានជាមួយនឹងអត្រាប្តូរនៃប្រាក់បាតថៃធៀបនឹងដុល្លារអាមេរិក ដោយមានមេគុណស្មើនឹង០,៣៩ ។ ទំនាក់ទំនងនេះមានន័យថា អត្រា ប្តូរប្រាក់ទាំង២នឹងមានបម្រែបម្រួលស្របគ្នា ៣៩% ជាចម្បងដោយសារកម្ពុជាមានតម្រូវការប្រាក់បាតថៃនៅក្នុងសេដ្ឋកិច្ចជាពិសេសសម្រាប់ការប្រើប្រាស់នៅតាមព្រំប្រទល់នៃប្រទេសទាំង ២ ។ ដូច្នេះនៅពេលដែលប្រាក់បាតចុះថ្លៃធៀបនឹងប្រាក់ដុល្លារនឹងនាំឲ្យប្រាក់ដុល្លារឡើងថ្លៃជាមួយប្រាក់រៀលផងដែរ ។

ដោយឡែក អត្រាប្តូរនៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានទំនាក់ទំនងអវិជ្ជមានជាមួយនឹងអត្រាប្តូរនៃប្រាក់ដុងវៀតណាមធៀបនឹងដុល្លារអាមេរិក ដោយមានមេគុណស្មើនឹង -០,៣៥ ដែលមានន័យថា ប្រសិនបើអត្រាប្តូរនៃប្រាក់ដុងវៀតណាមធៀបនឹងដុល្លារអាមេរិកកើនឡើង អត្រាប្តូរនៃប្រាក់រៀលធៀបនឹងដុល្លារអាមេរិកនឹងថយចុះ ៣៥% ។ ទំនាក់ទំនងអវិជ្ជមាននេះដោយសារតែប្រាក់ ដុងវៀតណាមមានតម្រូវការតែបន្តិចបន្តួចប៉ុណ្ណោះនៅកម្ពុជា ។

## IV. ការប៉ាន់ស្មានលើកម្រិតនៃការធ្វើអន្តរាគមន៍

### ១. ទំនាក់ទំនងនៃកំណើនសេដ្ឋកិច្ច និងកំណើនរូបិយវត្ថុក្នុងចរាចរណ៍

ស្របពេលដែលសកម្មភាពសេដ្ឋកិច្ចកម្ពុជាកំពុងបន្តមានកំណើនរឹងមាំ រូបិយវត្ថុក្នុងចរាចរណ៍ក៏មានការកើនឡើងផងដែរ ។ ដើម្បីស្វែងយល់ពីទំនាក់ទំនងរវាងអថេរទាំងពីរឲ្យកាន់តែច្បាស់ថែមទៀត យើងចាំបាច់ត្រូវធ្វើតេស្តសាកល្បងតាមរយៈការគណនារកមេគុណទំនាក់ទំនង (Correlation-R) និងការធ្វើតេស្ត Granger Causality ដើម្បីយល់ដឹងពីទិសដៅដែលអថេរទាំងពីរមានឥទ្ធិពលលើគ្នា (Causality Direction) តាមរយៈការប្រើប្រាស់កម្មវិធី Eviews ។ Granger Causality តេស្តធ្វើឡើងក្រោមសមត្ថកម្មពីរ៖ ១)-ការកើនឡើងនៃសេដ្ឋកិច្ច ជំរុញឲ្យមានកំណើននៃរូបិយវត្ថុក្នុងចរាចរណ៍ និង ២)- រូបិយវត្ថុក្នុងចរាចរណ៍ជំរុញឲ្យមានកំណើនសេដ្ឋកិច្ច ។

តាមការវិភាគនេះបង្ហាញថា កំណើនសេដ្ឋកិច្ចនិងរូបិយវត្ថុក្នុងចរាចរណ៍មានទំនាក់ទំនងនឹងគ្នា ប៉ុន្តែក្នុងកម្រិតមួយទាបបានន័យថា ការកើនឡើងនៃសកម្មភាពសេដ្ឋកិច្ចជាតិបានជំរុញឲ្យមានកំណើនតម្រូវការប្រាក់រៀលក្នុងល្បឿនខ្សោយ ។

| | | | |
|---|---|---|---|
| Pairwise Granger Causality Tests | | | |
| Date: 08/17/15 Time: 13:46 | | | |
| Sample: 2001 2014 | | | |
| Lags: 2 | | | |
| Null Hypothesis: | Obs | F-Statistic | Prob. |
| CIC does not Granger Cause GDP_PERCAPITA | 12 | 0.20614 | 0.8185 |
| GDP_PERCAPITA does not Granger Cause CIC | | 3.68025 | 0.0809 |

ជារួម លទ្ធផលនៃការធ្វើតេស្តនេះបានផ្តល់នូវចម្លើយសមស្របនឹងស្ថានភាពជាក់ស្តែងនៅកម្ពុជា ដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ក្នុងសេដ្ឋកិច្ច ។ គួរបញ្ជាក់ផងដែរថាក្នុងឆ្នាំ២០១៤ រូបិយវត្ថុក្នុងចរាចរណ៍មានសមាមាត្រត្រឹម ៨% នៃផ.ស.ស ។ ការខិតខំរបស់ធនាគារជាតិនៃកម្ពុជាក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀល

បានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញឲ្យមានតម្រូវការប្រាក់រៀលកើនឡើងក្នុងសេដ្ឋកិច្ចជាតិ ដែលសមាមាត្របរិមាណរូបិយវត្ថុក្នុងចរាចរណ៍មានកម្រិតត្រឹម ៣% នៃផ.ស.ស ប៉ុណ្ណោះនៅឆ្នាំ២០០០ ។




## ២.ទំនាក់ទំនងរវាងការធ្វើអន្តរាគមន៍លើទីផ្សារ និងសន្ទនីយភាពលើសជាប្រាក់រៀល

តារាងខាងក្រោមនេះបង្ហាញអំពីលទ្ធផលនៃទំនាក់ទំនងជា Correlation Coefficient រវាង អន្តរាគមន៍លើទីផ្សារ និងសន្ទនីយភាពលើសជាប្រាក់រៀលនៅក្នុងប្រព័ន្ធធនាគារ ដោយគណនាផ្អែកលើទិន្នន័យប្រចាំឆ្នាំពី២០០៦ ដល់ ២០១៤ ។

| | ការធ្វើអន្តរាគមន៍សុទ្ធ | សន្ទនីយភាពលើស |
|---|---|---|
| **ការធ្វើអន្តរាគមន៍សុទ្ធ** | ១ | |
| សន្ទនីយភាពលើស | ០,៧៩២៥ | ១ |

យោងតាមលទ្ធផលនៃការវិភាគបានបង្ហាញថា អន្តរាគមន៍លើទីផ្សារប្តូរប្រាក់មានទំនាក់ទំនងខ្លាំងជាមួយនឹងសន្ទនីយភាពលើសជាប្រាក់រៀលក្នុងប្រព័ន្ធធនាគារ ។ មានន័យថា កំណើននៃការធ្វើអន្តរាគមន៍លើទីផ្សារបានរួមចំណែកធ្វើឱ្យមានកំណើនសន្ទនីយភាពលើសជាប្រាក់រៀល ។




ការប្រើប្រាស់ OLS ដើម្បីសិក្សាពីទំនាក់ទំនងរវាងអន្តរាគមន៍ទីផ្សារនិងសន្ទនីយភាពលើសជារៀលដោយប្រើប្រាស់ទិន្នន័យប្រចាំឆ្នាំពី ២០០៦ ដល់ ២០១៤ ត្រូវបានបកស្រាយតាមរយៈសមីការ ខាងក្រោម ៖

សន្ទនីយភាពលើសជារៀល = ០,៣២៤ * ការធ្វើអន្តរាគមន៍លើទីផ្សារ

| *Regression Statistics* | |
|---|---|
| Multiple R | 0.792531515 |
| R Square | 0.628106202 |
| Adjusted R Squ | 0.574978516 |
| Standard Error | 207040.3231 |
| Observations | 9 |

ANOVA

| | *df* | *SS* | *MS* | *F* | *Significance F* |
|---|---|---|---|---|---|
| Regression | 1 | 5.06783E+11 | 5.06783E+11 | 11.82257792 | 0.010860766 |
| Residual | 7 | 3.0006E+11 | 42865695377 | | |
| Total | 8 | 8.06843E+11 | | | |

| | *Coefficients* | *Standard Error* | *t Stat* | *P-value* | *Lower 95%* | *Upper 95%* | *Lower 95.0%* | *Upper 95.0%* |
|---|---|---|---|---|---|---|---|---|
| Intercept | -18772.70375 | 114379.3272 | -0.16412672 | 0.874269935 | -289236.835 | 251691.4272 | -289236.8347 | 251691.4272 |
| Net Intervention | 0.323874715 | 0.094193504 | 3.438397581 | 0.010860766 | 0.101142472 | 0.546606958 | 0.101142472 | 0.546606958 |

លទ្ធផលខាងលើនេះបង្ហាញថា ប្រសិនបើធនាគារជាតិនៃកម្ពុជាធ្វើអន្តរាគមន៍លើទីផ្សារដោយលក់ប្រាក់រៀល ១ លានរៀល ក្នុងមួយឆ្នាំនឹងធ្វើឱ្យសន្ទនីយភាពលើសជារៀលកើនឡើង ៣២៤ ពាន់រៀល ។ ទន្ទឹមនេះ លទ្ធផលក៏បានបង្ហាញផងដែរថា ភាពត្រឹមត្រូវនៃម៉ូឌែលមានកម្រិតលើមធ្យមរហូត ដល់ ០,៦៣% ($R^2$ = ០,៦៣) ។

សន្ទនីយភាពលើសជាប្រាក់រៀលនៅក្នុងប្រព័ន្ធធនាគារមានកំណើនជាមធ្យមប្រមាណ ៥៨%(២០១០-២០១៣) និងបានកើន ៦០% ក្នុងឆ្នាំ២០១៤ ។ សន្ទនីយភាពលើសនេះបង្ហាញពីការស្រូបយកបរិមាណនៃប្រាក់រៀលដែលបានបញ្ចេញប៉ុន្តែមិនបានប្រើប្រាស់ក្នុងសេដ្ឋកិច្ច ។ ក្នុងរយៈពេលដូចគ្នានេះដែរ សន្ទនីយភាពលើសជាប្រាក់រៀលមានសមាមាត្រជាមធ្យម ៨% នៃរូបិយវត្ថុក្នុងចរាចរណ៍(២០១០-២០១៣) និង ១៦% នៅឆ្នាំ២០១៤ ។ គួរកត់សម្គាល់ថា សមាមាត្រនៃសន្ទនីយភាពលើសជាប្រាក់រៀលធៀបនឹងរូបិយវត្ថុក្នុងចរាចរណ៍មានកម្រិតត្រឹមតែ ៤% ប៉ុណ្ណោះ នៅក្នុងឆ្នាំ២០១០ ។

**សមាមាត្រនៃសន្ទនីយភាពលើសជារៀលធៀបនឹងរូបិយវត្ថុក្នុងចរាចរណ៍**(២០១០-២០១៤)




### ៣. ឥទ្ធិពលនៃការធ្វើអន្តរាគមន៍លើរូបិយវត្ថុក្នុងចរាចរណ៍



ក្នុងបរិការណ៍សេដ្ឋកិច្ចដែលមានកម្រិតដុល្លាររូបនីយកម្មខ្ពស់ ធនាគារជាតិនៃកម្ពុជាពុំអាចគ្រប់គ្រងប្រាក់ដុល្លារក្នុងចរាចរណ៍បានទេ ។ នៅពេលមានការធ្វើអន្តរាគមន៍ ដោយបញ្ចេញប្រាក់រៀលទៅលើទីផ្សាររូបិយវត្ថុក្នុងចរាចរណ៍នឹងកើនឡើង ប៉ុន្តែកំណើននេះមិនចូលទៅក្នុងចរាចរណ៍ទាំងអស់នោះទេ។

ទិន្នន័យដែលបានប្រើប្រាស់ក្នុងការសិក្សាពីទំនាក់ទំនងរបស់ការធ្វើអន្តរាគមន៍ និងរូបិយវត្ថុក្នុងចរាចរណ៍គឺជាទិន្នន័យប្រចាំខែ ពីខែមករា ឆ្នាំ២០១១ ដល់ ខែមិថុនា ឆ្នាំ២០១៥ (៥៤ observations) ។ ដើម្បីដឹងពីទំនាក់ទំនងវិជ្ជមាន ឬអវិជ្ជមានរវាងសូចនាករទាំងពីរនេះ ការធ្វើតេស្ត correlation តាមសេដ្ឋមាត្រសាស្ត្រត្រូវបានធ្វើឡើង ហើយបានបង្ហាញថា ការធ្វើអន្តរាគមន៍ និងរូបិយវត្ថុក្នុងចរាចរណ៍មានទំនាក់ទំនងវិជ្ជមាននឹងគ្នា ប៉ុន្តែមានលក្ខណៈពុំខ្លាំងក្លាទេដោយមានកម្រិត ០,៥ ប៉ុណ្ណោះ ។ ក្នុងការយល់ច្បាស់ពីកម្រិតនៃទំនាក់ទំនងនេះ ការធ្វើសមីការតាមសេដ្ឋមាត្រសាស្ត្រ (OLS) ត្រូវបានប្រើប្រាស់ ។ លទ្ធផលនៃ Regression (តារាងទី៣នៃឧបសម្ព័ន្ធ) បានបង្ហាញថា នៅពេលធនាគារជាតិនៃកម្ពុជាទិញប្រាក់ដុល្លារអាមេរិក ដោយបញ្ចេញប្រាក់រៀលស្មើនឹង ១ លានរៀលក្នុងមួយខែ ការណ៍នេះ អាចរួមចំណែកបង្កើនរូបិយវត្ថុក្នុងចរាចរណ៍ ០,៤៤ លានរៀល ចំណែក ០,៥៦ លានរៀលអាចចូលក្នុងប្រព័ន្ធធនាគារវិញ ដែលអាចត្រូវបានបកស្រាយតាមសមីការខាងក្រោម ៖

**រូបិយវត្ថុក្នុងចរាចរណ៍** = ០,៤៤ * **ការទិញដុល្លារ** (សមីការ "ក")

ទោះជាយ៉ាងណា ភាពត្រឹមត្រូវនៃម៉ូឌែល (fitness of the model) នៅមានកម្រិតទាប ($R^2$=០,២៥) ហើយក៏អាចនិយាយបានថា មានកត្តាផ្សេងៗទៀតដែលជះឥទ្ធិពលដល់រូបិយវត្ថុក្នុងចរាចរណ៍ ក្រៅពីការធ្វើអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា ។

## ៤. ឥទ្ធិពលនៃការធ្វើអន្តរាគមន៍លើតម្លៃប្រាក់រៀល




ចាប់ពីឆ្នាំ២០១១មក អត្រាប្តូរប្រាក់ (ទិញទីផ្សារ) មានកម្រិតជាមធ្យម ៤.០៤៦ រៀលក្នុងមួយដុល្លារអាមេរិក ខណៈការទិញប្រាក់ដុល្លារអាមេរិកជាមធ្យមមានចំនួន ១,១៨ លានដុល្លារអាមេរិកក្នុងមួយថ្ងៃ ។ ជាទូទៅអន្តរាគមន៍ភាគច្រើនធ្វើឡើងពេញមួយឆ្នាំទៅតាមតម្រូវការទីផ្សារ ជាពិសេស តាមរដូវកាលចាប់ពីចុងត្រីមាសទី ៣ ដល់ចុងត្រីមាសទី១ ជារយៈពេលដែលតម្រូវការប្រាក់រៀលកើនឡើងខ្ពស់សម្រាប់បង់ពន្ធ ទិញកសិផល និងពិធីបុណ្យជាតិធំៗ ។

យោងតាមទ្រឹស្តីនៃការផ្គត់ផ្គង់រូបិយវត្ថុ ការធ្វើអន្តរាគមន៍ដោយទិញប្រាក់ដុល្លារអាមេរិកតាម រយៈការបញ្ចេញប្រាក់រៀលលើទីផ្សារធ្វើឲ្យប្រាក់រៀលធ្លាក់ថ្លៃ ។ ប៉ុន្តែបើតាមការសិក្សាលើទិន្នន័យប្រចាំថ្ងៃនៃអត្រាប្តូរប្រាក់ទិញទីផ្សារនិងការធ្វើអន្តរាគមន៍ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១១ ដល់ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ដោយដកទិន្នន័យនៃ

ថ្ងៃដែលគ្មានការធ្វើអន្តរាគមន៍ (សរុប ៤៥១ observations) បង្ហាញថា សូចនាករទាំងពីរមានទំនាក់ទំនងអវិជ្ជមានក្នុងកម្រិតតិចតួច (correlation coefficient = -0,១២) ដែលបញ្ជាក់ពីទ្រឹស្តី ។

តាមរយៈការធ្វើសមីការតាមសេដ្ឋមាត្រសាស្ត្រដោយប្រើប្រាស់ម៉ូដែល VAR (តារាងទី៥នៃឧបសម្ព័ន្ធ) លទ្ធផលបានបង្ហាញដូចខាងក្រោម ៖

**អត្រាប្តូរប្រាក់$_t$ = -0,២៣៧៨៧0*អន្តរាគមន៍$_{t-1}$+ 0,២0៩៩៧៧*អន្តរាគមន៍$_{t-2}$**

អត្រាប្តូរប្រាក់សំដៅដល់បម្រែបម្រួលអត្រាប្តូរប្រាក់ = អត្រាប្តូរប្រាក់នៅពេលធ្វើអន្តរាគមន៍លើកនេះ - អត្រាប្តូរប្រាក់នៅពេលធ្វើអន្តរាគមន៍លើកមុន ។

ផ្អែកតាមសមីការខាងលើនេះ ការធ្វើអន្តរាគមន៍ថ្ងៃនេះនឹងធ្វើឱ្យអត្រាប្តូរប្រាក់នៅថ្ងៃស្អែកថយចុះ (ឡើងថ្លៃ) ប៉ុន្តែនឹងធ្វើឱ្យអត្រាប្តូរប្រាក់កើនឡើង (ធ្លាក់ថ្លៃ) នៅពីរថ្ងៃក្រោយ ។ ក្រាហ្វខាងក្រោមនេះ បង្ហាញថា នៅពេលដែលមានការទិញប្រាក់ដុល្លារអាមេរិករបស់ធនាគារជាតិនៃកម្ពុជា ប្រាក់រៀលនឹងឡើងថ្លៃនៅថ្ងៃបន្ទាប់ ប៉ុន្តែធ្លាក់ថ្លៃវិញនៅថ្ងៃបន្ទាប់មកទៀត ហើយក៏ស្ទើរតែគ្មានឥទ្ធិពលបន្តទៀត ។




វិធីសាស្ត្រមួយទៀតដែលធ្វើការប៉ាន់ស្មានពីឥទ្ធិពលនៃការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ គឺការធ្វើសមីការដោយប្រើប្រាស់ម៉ូឌែលADL(តារាងទី៥នៃឧបសម្ព័ន្ធ)ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

**អត្រាប្តូរប្រាក់$_t$ = -0,២៦0៧៤៦*អន្តរាគមន៍$_t$ + 0,២២៩៤0៣*អន្តរាគមន៍$_{t-2}$** (សមីការ"ខ")

អត្រាប្តូរប្រាក់សំដៅដល់បម្រែបម្រួលអត្រាប្តូរប្រាក់ = អត្រាប្តូរប្រាក់នៅពេលធ្វើអន្តរាគមន៍លើកនេះ - អត្រាប្តូរប្រាក់នៅពេលធ្វើអន្តរាគមន៍លើកមុន ផ្អែកតាមសមីការខាងលើនេះ អន្តរាគមន៍នៅថ្ងៃនេះ និងម្សិលម៉្ងៃមានឥទ្ធិពលលើអត្រាប្តូរប្រាក់ ចំណែកឯការធ្វើអន្តរាគមន៍នៅថ្ងៃម្សិលមិញគ្មានឥទ្ធិពលលើអត្រាប្តូរប្រាក់ទេ (not statistically significant) ហេតុដូចនេះ អន្តរាគមន៍នៅថ្ងៃម្សិលមិញពុំត្រូវបានរាយការណ៍នៅក្នុងសមីការខាងលើ ។ ការធ្វើអន្តរាគមន៍នៅ២ថ្ងៃមុនធ្វើឲ្យអត្រាប្តូរប្រាក់កើនឡើង ប៉ុន្តែការធ្វើអន្តរាគមន៍នៅថ្ងៃនេះធ្វើឲ្យអត្រាប្តូរប្រាក់ថយវិញ ។

ការណ៍នេះអាចមានន័យថា ប្រសិនបើមានការធ្វើអន្តរាគមន៍នៅថ្ងៃនេះ ហើយនៅ ២ ថ្ងៃបន្ទាប់ទៀតគ្មានការធ្វើអន្តរាគមន៍ទេនោះ ការធ្វើអន្តរាគមន៍នៅថ្ងៃនេះធ្វើឲ្យប្រាក់រៀលឡើងថ្លៃនៅថ្ងៃនេះ និងធ្លាក់ថ្លៃវិញនៅថ្ងៃខានស្អែក។

ដោយសារ Adjusted $R^2$(0,00៦ និង 0,0២) មានកម្រិតទាប ការណ៍នេះបង្ហាញថា ការធ្វើអន្តរាគមន៍មានឥទ្ធិពលបន្តិចបន្តួចលើទីផ្សារប្តូរប្រាក់ ដោយសារកម្ពុជាគឺជាប្រទេសដុល្លារូបនីយកម្មខ្ពស់ ហេតុដូចនេះ ការប្រើប្រាស់ប្រាក់រៀលនៅមានកម្រិតទាបនៅឡើយ ។ មានកត្តាផ្សេងទៀតដែលជះឥទ្ធិពលដល់អត្រាប្តូរប្រាក់នៅកម្ពុជា ដូចជា ការប្រែប្រួលនៃប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារអន្តរជាតិ តម្រូវការប្រាក់រៀលតាមកត្តារដូវកាល និងការកំណត់អត្រាទិញ-លក់ (dealing rate) របស់ធនាគារជាតិនៃកម្ពុជាជាមួយអាជីវករប្តូរប្រាក់ ។ ទឹកប្រាក់អន្តរាគមន៍ គួបផ្សំនឹងអត្រាប្តូរប្រាក់ដែលធនាគារជាតិនៃកម្ពុជាប្រើប្រាស់ជាមួយអ្នកទិញ (ភាគច្រើនអាជីវករប្តូរប្រាក់)

អាចមានឥទ្ធិពលគួរឱ្យកត់សម្គាល់លើអត្រាទីផ្សារ ។ បានន័យថា ពេលដែលធនាគារជាតិនៃកម្ពុជាទម្លាក់ ឬបង្កើនអត្រា កត្តានេះបានជះឥទ្ធិពលដោយផ្ទាល់លើអត្រាទីផ្សារ ប៉ុន្តែឥទ្ធិពលនេះក៏អាចថយទៅវិញ និងទាមទារឱ្យធនាគារជាតិនៃ កម្ពុជាកំណត់អត្រាឡើងវិញក្នុងការរក្សាឥទ្ធិពលនៃការធ្វើអន្តរាគមន៍ ដើម្បីឱ្យអត្រាប្តូរប្រាក់ស្ថិតនៅកម្រិតណាមួយតាមការចង់បាន ។

## ៥. កម្រិតសមស្របនៃការធ្វើអន្តរាគមន៍

### ក. ប៉ាន់ស្មានតាមរយៈកំណើនជាមធ្យមនៃរូបិយវត្ថុក្នុងចរាចរណ៍

| Year | M2 (mn, KHR) | M2's growth (yoy) | FCD (mn, KHR) | FCD's growth (yoy) | CIC (mn, KHR) | CIC growth (yoy) | GDP (mn, KHR) |
|---|---|---|---|---|---|---|---|
| Dec-09 | 16,228,311.23 | | 12,749,337.43 | | 3,094,678.03 | | 43,056,732 |
| Dec-10 | 19,476,805.89 | 0.20 | 15,847,606.32 | 0.24 | 3,240,994.58 | 0.05 | 47,047,985 |
| Dec-11 | 23,640,320.27 | 0.21 | 19,127,102.12 | 0.21 | 3,953,451.41 | 0.22 | 52,068,693 |
| Dec-12 | 28,591,881.54 | 0.21 | 23,766,366.11 | 0.24 | 3,986,468.82 | 0.01 | 56,681,569 |
| Dec-13 | 32,768,424.06 | 0.15 | 26,944,950.90 | 0.13 | 4,794,549.96 | 0.20 | 61,326,928 |
| Dec-14 | 42,559,507.45 | 0.30 | 35,160,985.32 | 0.30 | 5,984,859.18 | 0.25 | 67,740,450 |
| 2015 | | | | | | | 74,932,237 |
| កំណើនជាមធ្យមរយៈពេល ៥ឆ្នាំ | | 0.21 | | 0.23 | | 0.15 | |

កំណើនរូបិយវត្ថុក្នុងចរាចរណ៍(លានរៀល) = ០,១៥ x ៥.៩៨៤.៨៥៩,១៨=៨៩៧.៧២៩

កំណើនរូបិយវត្ថុចរាចរណ៍ជាមធ្យមរយៈពេល ៥ ឆ្នាំ មានប្រមាណ ១៥% ដោយប្រើប្រាស់កំណើននេះ រូបិយវត្ថុក្នុងចរាចរណ៍អាចត្រូវរំពឹងថានឹងមានកំណើន ៨៩៧,៧ ប៊ីលានរៀល នៅឆ្នាំ២០១៥ នេះ ឬប្រហែលនឹង ២២២លានដុល្លារអាមេរិក ។

### ខ. ប៉ាន់ស្មានដោយប្រើម៉ូដែល ១ (II.១.ខ)

យោងតាមលទ្ធផលពីម៉ូឌែល១ (II.១.ខ)៖ កំណើនរូបិយវត្ថុក្នុងចរាចរណ៍ (%)=២,០៩Xកំណើនផ.ស.ស ។ ដូចនេះ ប្រសិនបើ ផ.ស.ស កើនឡើង ៧% នោះ រូបិយវត្ថុក្នុងចរាចរណ៍អាចកើនឡើងប្រមាណ ២,០៩X៧% =១៤,៦% ឬស្មើនឹង ៨៧៣,៨ ប៊ីលានរៀល (ប្រហែល ២១៥ លានដុល្លារអាមេរិក) ។

### គ. ប៉ាន់ស្មានដោយប្រើម៉ូដែល ២

(Autoregressive-AR(1) AR(1) : CIC = C+CIC(-1) (ម៉ូឌែល២) ការប៉ាន់ស្មានដោយប្រើប្រាស់ម៉ូឌែល AR (1) បានបង្ហាញថា រូបិយវត្ថុក្នុងចរាចរណ៍កើនឡើងប្រមាណ ៥៩៩,៨ ប៊ីលានរៀល (ប្រហែល ១៤៨ លានដុល្លារអាមេរិក) ឬ ១0% បើធៀបនឹងឆ្នាំ ២០១៤ ។ នៅឆ្នាំ ២០១៥ នេះ រូបិយវត្ថុក្នុងចរាចរណ៍សរុបរំពឹងថានឹងមាន ៦,៦ ទ្រីលានរៀលយោងតាមក្រាហ្វខាងក្រោម ដែលបង្ហាញការព្យាករណ៍ពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០១៥ ។



ក្រៅពីម៉ូឌែលខាងលើ រូបិយវត្ថុក្នុងចរាចរណ៍ក៏ត្រូវប៉ាន់ស្មានដោយប្រើម៉ូឌែលផ្សេងទៀតដូចជាម៉ូឌែល ARMA(1, 1) ប៉ុន្តែទទួលបានលទ្ធផលប្រហាក់ប្រហែលគ្នា ។

គួរកត់សម្គាល់ថា ការព្យាករណ៍ថយក្រោយពីឆ្នាំ២០១៣ ដល់ ២០១៥សម្រាប់ប្រៀបធៀបទិន្នន័យជាក់ស្តែងជាមួយទិន្នន័យព្យាករណ៍បានបង្ហាញថា ទិន្នន័យព្យាករណ៍ដោយម៉ូឌែលនេះអាចមានកម្រិតទាបជាងទិន្នន័យជាក់ស្តែង (ក្រាហ្វខាងក្រោម) ។ ដូច្នេះ រូបិយវត្ថុចរាចរណ៍ក្នុងលទ្ធផលប៉ាន់ស្មានខាងលើនេះ អាចមានកម្រិតទាបជាងកម្រិតជាក់ស្តែង ។




ជារួម រូបិយវត្ថុក្នុងចរាចរណ៍គួរកើនឡើងជាអប្បបរមាប្រមាណ ៥៩៩,៨ ប៊ីលាន និងជាអតិបរមាប្រមាណ ៨៨៥,៨ ប៊ីលានរៀល (មធ្យម ៨៩៧,៧ និង ៨៧៣,៨ ប៊ីលានរៀល) ។ ដូចនេះ រូបិយវត្ថុក្នុងចរាចរណ៍គួរកើនឡើងក្នុងចន្លោះប្រមាណ ៥៩៩,៨ - ៨៨៥,៨ ប៊ីលានរៀល ឬប្រហែល ១៤៨-២១៩ លានដុល្លារអាមេរិកនៅឆ្នាំ២០១៥ នេះ ។

យោងតាមលទ្ធផលនៃការគណនាតាមសេដ្ឋមាត្រសាស្ត្រ (ចំនុចIV.៣)

**រូបិយវត្ថុក្នុងចរាចរណ៍ = 0,៤៤ x ការធ្វើអន្តរាគមន៍**

ដូចនេះ ដើម្បីទទួលបានរូបិយវត្ថុក្នុងចរាចរណ៍ក្នុងចន្លោះពី ៥៩៩,៨-៨៨៥,៨ ប៊ីលានរៀលការចាក់សាច់ប្រាក់ ឬការធ្វើអន្តរាគមន៍ត្រូវមានកម្រិតស្ថិតក្នុងចន្លោះពី ១,៤ - ២ ទ្រីលានរៀល ឬប្រហែលនឹង ៣៣៦,៦ - ៤៩៧,១ លានដុល្លារអាមេរិក ។

## ៦. ការដេញថ្លៃ

គោលបំណងនៃការដេញថ្លៃ គឺដើម្បីទិញ ឬលក់រូបិយប័ណ្ណបរទេសដោយពុំមានផលប៉ះពាល់ទៅលើអត្រាប្តូរប្រាក់ទីផ្សារ ឬដើម្បីកែតម្រូវអត្រាប្តូរប្រាក់ទីផ្សារបន្ទាប់ពីមានការប៉ះទង្គិច ។ ការដេញថ្លៃអាចធ្វើឡើងតាមពីរប្រភេទគឺ Single Price និង Multiple Price ។ Single Price គឺជាការដេញថ្លៃ ដែលអ្នកដេញថ្លៃនឹងត្រូវបង់ថ្លៃនូវតម្លៃដេញទាបបំផុត ដែលចំនួនសរុបនៃរូបិយប័ណ្ណនឹងត្រូវលក់អស់ រីឯបរិមាណនឹងផ្តល់ជូនទៅតាមលំដាប់ពីអ្នកដាក់តម្លៃខ្ពស់ជាងគេនិងបន្តបន្ទាប់ ។ ការលក់ប័ណ្ណរតនាគាររបស់សហរដ្ឋអាមេរិកប្រើប្រាស់ការដេញថ្លៃបែប Single Price នេះ ដោយកំណត់យកថ្លៃដេញទាបជាងគេដែលបានដាក់ដេញដោយវិនិយោគិននៅកម្រិតដែលចំនួនប័ណ្ណសរុបនឹងត្រូវលក់អស់ ហើយផ្តល់ជូនចំនួនប័ណ្ណទៅវិនិយោគិនទៅតាមលំដាប់ ។ ធនាគារកណ្តាលអាយឡែនក៏អនុវត្តការដេញថ្លៃ បែប Single Price នេះដែរក្នុងការទិញរូបិយប័ណ្ណបរទេសពីធនាគារ

ពាណិជ្ជ ។ ចំណែកឯ Multiple Price គឺជាការដេញថ្លៃដែលអ្នកដេញថ្លៃបានទទួលនូវបរិមាណរូបិយប័ណ្ណទៅតាមថ្លៃរៀងៗខ្លួនដែលបានដេញ ។ ធនាគារកណ្តាលតណ្ហាអនុវត្តការដេញថ្លៃបែប Multiple Price នេះ ចំពោះការលក់ប័ណ្ណរតនាគារចាប់ពីពាក់កណ្តាលឆ្នាំ២០១៤ ។

ធនាគារជាតិនៃកម្ពុជាមានសិទ្ធិធ្វើអន្តរាគមន៍លើទីផ្សារ ប្រសិនបើធនាគារជាតិនៃកម្ពុជាយល់ឃើញថាមានសារសំខាន់ក្នុងការរក្សាស្ថិរភាពថ្លៃ ។ ធនាគារជាតិនៃកម្ពុជាសម្រេចធ្វើអន្តរាគមន៍ដោយពិនិត្យលើការប្រែប្រួលអត្រាប្តូរប្រាក់ ។ ប្រសិនបើអត្រាប្តូរប្រាក់ឡើងថ្លៃខ្លាំងមានន័យថា ទីផ្សារមានតម្រូវការប្រាក់រៀលពេលនោះធនាគារជាតិនឹងទិញដុល្លារ និងផ្ទុយមកវិញប្រសិនបើអត្រាប្តូរប្រាក់ធ្លាក់ថ្លៃខ្លាំងមានន័យថា ប្រាក់រៀលមានចំនួនច្រើនលើទីផ្សារ ពេលនោះធនាគារជាតិនឹងលក់ដុល្លារ ។

ជាក់ស្តែង កន្លងមកធនាគារជាតិនៃកម្ពុជាបានធ្វើការលក់ដុល្លារជាមួយស្ថាប័នដែលមានអាជ្ញាប័ណ្ណ ដូចជាធនាគារពាណិជ្ជធំៗ និងអាជីវករប្តូរប្រាក់ ។ ការធ្វើប្រតិបត្តិការនេះធ្វើឡើងដោយធនាគារជាតិបានធ្វើសេចក្តីជូនដំណឹងពីការដេញថ្លៃ ពេលវេលា និងទីកន្លែងដល់ស្ថាប័នដែលមានអាជ្ញាប័ណ្ណ ដើម្បីឲ្យស្ថាប័នទាំងនេះដាក់ពាក្យសុំចូលដេញថ្លៃទៅនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ ។ ការដេញថ្លៃធ្វើឡើងដោយមានគណៈកម្មការមួយសម្រាប់កំណត់អត្រាទិញ-លក់ដំបូងមួយ (dealing rate) ដែលអត្រានេះយ៉ាងតិចស្មើអត្រាទីផ្សារនិងឲ្យស្ថាប័នចូលរួមដេញថ្លៃឡើង ។ ប្រសិនបើស្ថាប័នមួយណាឲ្យតម្លៃខ្ពស់ជាងគេធនាគារជាតិនឹងលក់ដុល្លារជូនដោយយកអត្រាដេញថ្លៃ ។ ឧទាហរណ៍ ៖ ប្រសិនបើអត្រាប្តូរប្រាក់ទីផ្សារ ៤,២០០រៀល ធនាគារជាតិនៃកម្ពុជានឹងកំណត់អត្រាសម្រាប់ដេញថ្លៃចាប់ពី ៤,២០០រៀល ។ ចាប់ពីឆ្នាំ២០១២ មកធនាគារជាតិនៃកម្ពុជាមិនបានលក់ដុល្លារទៀតទេ ដោយសារអត្រាអតិផរណារ និងអត្រាប្តូរប្រាក់មានស្ថិរភាពល្អ ប៉ុន្តែធនាគារជាតិទទួលទិញដុល្លារពីស្ថាប័នដែលមានអាជ្ញាប័ណ្ណ (ធនាគារពាណិជ្ជ ឬអគារប្តូរប្រាក់) ប្រសិនបើស្ថាប័ននោះ មានបំណងលក់ដុល្លារ ដោយកំណត់អត្រាទិញ-លក់ (dealing rate) ខ្ពស់ជាងអត្រាទីផ្សារ និងមិនកំណត់ទំហំនៃការទិញ ។

| ឆ្នាំ | ចំនួនធ្វើប្រតិបត្តិការ | ទិញដុល្លារ (លានដុល្លារ) |
|---|---|---|
| ២០១១ | ៦៨ | ២០៦.៥ |
| ២០១២ | ៣៤ | ១៤៤.១៨ |
| ២០១៣ | ៧២ | ៣១៦.៤៥ |
| ២០១៤ | ១៤៣ | ៨០២.៧ |




ដើម្បីបំពេញបានតាមតម្រូវការប្តូររូបិយវត្ថុ ការដេញថ្លៃគួររៀបចំឡើងដោយទៀងទាត់ដើម្បីអាចឱ្យធនាគារជាតិទទួលបានព័ត៌មានពីតម្រូវការប្តូររូបិយវត្ថុ តាមរយៈឆន្ទៈរបស់អ្នកចូលរួមដេញថ្លៃ ដែលមានទាំងគ្រឹះស្ថានធនាគារ មីក្រូហិរញ្ញវត្ថុ និងអាជីវកម្មប្តូរប្រាក់ដែលបង្ហាញក្នុងពេលដេញថ្លៃ ។

## សន្និដ្ឋាន

ក្នុងបរិការណ៍ដុល្លារូបនីយកម្មខ្ពស់ គោលនយោបាយអត្រាប្តូរប្រាក់មានសារៈសំខាន់ណាស់ក្នុងការរួមចំណែករក្សាស្ថិរភាពថ្លៃ ។ ចាប់ពីដើមទសវត្សរ៍២០០០មក ធនាគារជាតិនៃកម្ពុជាបានអនុវត្តរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រងដោយបានព្យាយាមរក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារ ។ កន្លងមក ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ តាមរយៈការទិញ-លក់ប្រាក់រៀលឆ្លើយតបនឹងការស្នើទិញរបស់អាជីវករប្តូរប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួន ។ ការអន្តរាគមន៍នេះបានរក្សាស្ថិរភាពអត្រាប្តូរប្រាក់ប្រកបដោយប្រសិទ្ធភាព ។ ទោះយ៉ាងណាក៏ដោយ នៅពេលដែលទំហំទីផ្សារប្តូរប្រាក់កើនឡើងជាលំដាប់ ការអនុវត្តនេះអាចនឹងប្រឈមនឹងការមិនអាចឆ្លើយតបនឹងតម្រូវការសរុបពិតរបស់ទីផ្សារបាន ។ ដូច្នេះ ការជំរុញឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក៏ដូចជាអាជីវករប្តូរប្រាក់ចូលរួមឲ្យកាន់តែច្រើន និងសកម្មនៅក្នុងទីផ្សារប្តូរប្រាក់ និងអនុញ្ញាតឲ្យធនាគារជាតិនៃកម្ពុជាកំណត់បាននូវតម្រូវការសរុបពិតរបស់ប្រាក់រៀល ។ ការទទួល បានព័ត៌មានពីតម្រូវការពិតនេះ ជាមូលដ្ឋានកំណត់ទិសដៅនិងទំហំនៃការធ្វើអន្តរាគមន៍ដើម្បីជៀសវាងការធ្វើ អន្តរាគមន៍ច្រើនពេក និងតិចពេក ដែលនឹងអាចបង្កឲ្យមានការកេងចំណេញនៅលើទីផ្សារ និងអាចឈានទៅធ្វើឲ្យអត្រាប្តូរប្រាក់កាន់តែមានការប្រែប្រួលខ្លាំង ហើយនៅក្នុងករណីមួយចំនួនមិនអាចគ្រប់គ្រងបាន ។

អត្ថបទស្រាវជ្រាវនេះបានធ្វើការសិក្សាលម្អិតដោយប្រើម៉ូឌែលមួយចំនួន ដើម្បីរកទំនាក់ទំនងអញ្ញត្តិនានានៅក្នុងវិស័យរូបិយវត្ថុ ជាពិសេស រូបិយវត្ថុក្នុងចរាចរណ៍ អត្រាប្តូរប្រាក់ ការធ្វើអន្តរាគមន៍ និងសន្ទនីយភាពលើស ។ លទ្ធផលនៃម៉ូឌែលបានបង្ហាញថា ការធ្វើអន្តរាគមន៍ ១% បានរួមចំណែកបង្កើនរូបិយវត្ថុក្នុងចរាចរណ៍តែ ០,៤៤% ខណៈដែល ០,៥៦% ទៀត បានគរពូនក្នុងផ្នែកសន្ទនីយភាពលើស ហើយកម្រិតសមស្របនៃការធ្វើអន្តរាគមន៍គួរតែស្ថិតនៅក្នុងកម្រិតពី ១,៤ ទ្រីលានទៅ ១,៦៦ ទ្រីលានរៀល ឬប្រហែលនឹង ៣៣៦,៦ លានដុល្លារអាមេរិកទៅ ៤៩៧,១ លានដុល្លារអាមេរិកក្នុងមួយឆ្នាំក្នុងបរិការណ៍នៃកំណើនសេដ្ឋកិច្ច ៧% និងនិន្នាការកំណើននៃការប្រើប្រាស់ប្រាក់បច្ចុប្បន្ន។

ប៉ុន្តែការសិក្សាតាមម៉ូឌែលទាំងនេះ ក៏មិនអាចប៉ានស្មានចំនួនត្រឹមត្រូវនៃការធ្វើអន្តរាគមន៍ ដើម្បីឆ្លើយតបនឹងតម្រូវការប្រាក់រៀលសរុបពិតនៅលើទីផ្សារបានដែរ ដោយសារតម្រូវការប្រាក់រៀលជាក់ស្តែងគួរតែទទួលបានតាមរយៈការកំណត់រកតម្រូវការទីផ្សារសរុប ដែលអាចទាញចេញបានតាមការអនុវត្តការដេញថ្លៃ (auction) ។ ហេតុនេះ ការចាប់ផ្តើមអនុវត្តយន្តការដេញថ្លៃគឺមានសារៈសំខាន់បំផុត ក្នុងស្ថានភាពដែលទំហំវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាពិសេស ទីផ្សារប្តូរប្រាក់បានកើនឡើងជាលំដាប់។

## អត្រាប្តូរប្រាក់ប្រចាំខែ

| ចុងខែ | អត្រាទីផ្សារ | | | | | អត្រាផ្លូវការ | | | គម្លាតអត្រាមធ្យម | |
|---|---|---|---|---|---|---|---|---|---|---|
| | អត្រាទិញ | អត្រាលក់ | មធ្យម | ប្រែប្រួលប្រចាំខែ | | មធ្យម | ប្រែប្រួលប្រចាំខែ | | អត្រាផ្លូវការ-ទីផ្សារ | |
| | | | | +/- | % | | +/- | % | +/- | % |
| **២០១៣** | | | | | | | | | | |
| ឧសភា | ៤,០៩២ | ៤,១០០ | ៤,០៩៦ | ៣៧ | ០.៩១ | ៤,០៦៥ | ៤៥ | ១.១២ | -៣១ | -០.៧៦ |
| មិថុនា | ៤,០៨៥ | ៤,០៩៣ | ៤,០៨៩ | -៧ | -០.១៧ | ៤,០៦២ | -៣ | -០.០៧ | -២៧ | -០.៦៦ |
| កក្កដា | ៤,០៩៤ | ៤,១០១ | ៤,០៩៨ | ៩ | ០.២២ | ៤,០៦២ | ០ | ០.០០ | -៣៦ | -០.៨៧ |
| សីហា | ៤,០៩២ | ៤,១០១ | ៤,០៩៧ | -២ | -០.០៥ | ៤,០៦២ | ០ | ០.០០ | -៣៥ | -០.៨៤ |
| កញ្ញា | ៤,០៦៧ | ៤,០៧៥ | ៤,០៧១ | -២៥ | -០.៦១ | ៤,០៦២ | ០ | ០.០០ | -៩ | -០.២២ |
| តុលា | ៤,០៣១ | ៤,០៣៨ | ៤,០៣៥ | -៣៦ | -០.៨៩ | ៤,០៤០ | -២២ | -០.៥៤ | ៦ | ០.១៤ |
| វិច្ឆិកា | ៣,៩៩៤ | ៤,០០៥ | ៤,០០០ | -៣៧ | -០.៩២ | ៣,៩៩៥ | -៤៥ | -១.១១ | -៥ | -០.១១ |
| ធ្នូ | ៤,០០៣ | ៤,០១៣ | ៤,០០៨ | ៩ | ០.២៣ | ៣,៩៩៥ | ០ | ០.០០ | -១៣ | -០.៣២ |
| **២០១៤** | | | | | | | | | | |
| មករា | ៣,៩៩៥ | ៤,០០៣ | ៣,៩៩៩ | -៨ | -០.២០ | ៣,៩៩៥ | ០ | ០.០០ | -៤ | -០.១០ |
| កុម្ភៈ | ៣,៩៨១ | ៣,៩៨៩ | ៣,៩៨៥ | -១៤ | -០.៣៥ | ៣,៩៨០ | -១៥ | -០.៣៨ | -៥ | -០.១៣ |
| មីនា | ៣,៩៩៥ | ៤,០០២ | ៣,៩៩៩ | ១៤ | ០.៣៥ | ៤,០១៥ | ៣៥ | ០.៨៨ | ១៧ | ០.៤១ |
| មេសា | ៤,០១២ | ៤,០២២ | ៤,០១៧ | ១៧ | ០.៤៣ | ៤,០១៥ | ០ | ០.០០ | -២ | -០.០៥ |
| ឧសភា | ៤,០៤៣ | ៤,០៥៣ | ៤,០៤៨ | ៣១ | ០.៧៧ | ៤,០៣២ | ១៧ | ០.៤២ | -១៦ | -០.៤០ |
| មិថុនា | ៤,០៤៧ | ៤,០៥៣ | ៤,០៥០ | ៤ | ០.១០ | ៤,០៤០ | ៨ | ០.២០ | -១០ | -០.២៥ |
| កក្កដា | ៤,០៥៤ | ៤,០៦៣ | ៤,០៥៩ | ៧ | ០.១៧ | ៤,០៥០ | ១០ | ០.២៥ | -៩ | -០.២១ |
| សីហា | ៤,០៧៤ | ៤,០៨៣ | ៤,០៧៩ | ២០ | ០.៤៩ | ៤,០៦៥ | ១៥ | ០.៣៧ | -១៤ | -០.៣៣ |
| កញ្ញា | ៤,០៨៧ | ៤,០៩៦ | ៤,០៩២ | ១៣ | ០.៣២ | ៤,០៨៥ | ២០ | ០.៤៩ | -៧ | -០.១៦ |
| តុលា | ៤,០៧៤ | ៤,០៨០ | ៤,០៧៧ | -១៣ | -០.៣២ | ៤,០៧៦ | -៩ | -០.២២ | -១ | -០.០២ |
| វិច្ឆិកា | ៤,០៥៥ | ៤,០៦២ | ៤,០៥៩ | -១៩ | -០.៤៧ | ៤,០៦៣ | -១៣ | -០.៣២ | ៥ | ០.១១ |
| ធ្នូ | ៤,០៦៤ | ៤,០៧៣ | ៤,០៦៩ | ៩ | ០.២២ | ៤,០៧៥ | ១២ | ០.៣០ | ៧ | ០.១៦ |
| **២០១៥** | | | | | | | | | | |
| មករា | ៤,០៥៩ | ៤,០៦៧ | ៤,០៦៣ | -៥ | -០.១២ | ៤,០៥០ | -២៥ | -០.៦១ | -១៣ | -០.៣២ |
| កុម្ភៈ | ៤,០៣២ | ៤,០៤០ | ៤,០៣៦ | -២៧ | -០.៦៧ | ៤,០២៧ | -២៣ | -០.៥៧ | -៩ | -០.២២ |
| មីនា | ៤,០១០ | ៤,០១៨ | ៤,០១៤ | -២២ | -០.៥៥ | ៤,០១០ | -១៧ | -០.៤២ | -៤ | -០.១០ |
| មេសា | ៤,០៦៦ | ៤,០៧៦ | ៤,០៧១ | ៥៦ | ១.៤០ | ៤,០៥០ | ៤០ | ១.០០ | -២១ | -០.៥២ |
| ឧសភា | ៤,០៨៦ | ៤,០៩៦ | ៤,០៩១ | ២០ | ០.៤៩ | ៤,០៦៨ | ១៨ | ០.៤៤ | -២៣ | -០.៥៦ |
| មិថុនា | ៤,០៩៤ | ៤,១០១ | ៤,០៩៨ | ៨ | ០.២០ | ៤,០៩៨ | ៣០ | ០.៧៤ | ១ | ០.០១ |
| កក្កដា | ៤,១១៣ | ៤,១២១ | ៤,១១៧ | ១៩ | ០.៤៦ | ៤,១១៣ | ១៥ | ០.៣៧ | -៤ | -០.១០ |
| សីហា | ៤,០៩៨ | ៤,១០៥ | ៤,១០២ | -១៥ | -០.៣៦ | ៤,០៨១ | -៣២ | -០.៧៨ | -២១ | -០.៥០ |
| កញ្ញា | ៤,០៧៤ | ៤,០៨៧ | ៤,០៨១ | -២៤ | -០.៥៩ | ៤,០៧៦ | -៥ | -០.១២ | -៥ | -០.១១ |
| តុលា | ៤,០៤៩ | ៤,០៦០ | ៤,០៥៥ | -២៥ | -០.៦១ | ៤,០៦១ | -១៥ | -០.៣៧ | ៧ | ០.១៦ |
| វិច្ឆិកា | ៤,០៤៤ | ៤,០៥៦ | ៤,០៥០ | -៥ | -០.១២ | ៤,០៤៤ | -១៧ | -០.៤២ | -៦ | -០.១៥ |
| ធ្នូ | ៤,០៤៨ | ៤,០៥៥ | ៤,០៥២ | ៤ | ០.១០ | ៤,០៥០ | ៦ | ០.១៥ | -២ | -០.០៤ |
| **២០១៦** | | | | | | | | | | |
| មករា | ៤,០៣៧ | ៤,០៤៥ | ៤,០៤១ | -១១ | -០.២៧ | ៤,០៣៧ | -១៣ | -០.៣២ | -៤ | -០.១០ |
| កុម្ភៈ | ៤,០១០ | ៤,០១៦ | ៤,០១៣ | -២៧ | -០.៦៧ | ៤,០០៨ | -២៩ | -០.៧២ | -៥ | -០.១២ |
| មីនា | ៤,០១០ | ៤,០១៨ | ៤,០១៤ | ០ | ០.០០ | ៤,០០៦ | -២ | -០.០៥ | -៨ | -០.២០ |
| មេសា | ៤,០៦១ | ៤,០៧៣ | ៤,០៦៧ | ៥១ | ១.២៧ | ៤,០៦០ | ៥៤ | ១.៣៥ | -៧ | -០.១៧ |
| ឧសភា | ៤,០៨២ | ៤,០៩១ | ៤,០៨៧ | ២១ | ០.៥២ | ៤,០៨៥ | ២៥ | ០.៦២ | -២ | -០.០៤ |
| មិថុនា | ៤,០៨១ | ៤,០៩១ | ៤,០៨៦ | -១ | -០.០២ | ៤,០៨៤ | -១ | -០.០២ | -២ | -០.០៥ |
| កក្កដា | ៤,០៩៤ | ៤,១០៣ | ៤,០៩៩ | ១៣ | ០.៣២ | ៤,០៩៧ | ១៣ | ០.៣២ | -២ | -០.០៤ |
| សីហា | ៤,០៩៦ | ៤,១០៦ | ៤,១០១ | ២ | ០.០៥ | ៤,០៩៦ | -១ | -០.០២ | -៥ | -០.១២ |

## MONTHLY EXCHANGE RATE

| End month | Parallel Market Rate | | | | | Official Exchannge Rate | | | Spread | |
|---|---|---|---|---|---|---|---|---|---|---|
| | Purchase | Sale | Midpoint | Monthly Change | | Midpoint | Monthly Change | | Official-Market | |
| | | | | +/- | % | | +/- | % | +/- | % |
| **2013** | | | | | | | | | | |
| May | 4,092 | 4,100 | 4,096 | 37 | 0.91 | 4,065 | 45 | 1.12 | -31 | -0.76 |
| June | 4,085 | 4,093 | 4,089 | -7 | -0.17 | 4,062 | -3 | -0.07 | -27 | -0.66 |
| July | 4,094 | 4,101 | 4,098 | 9 | 0.22 | 4,062 | 0 | 0.00 | -36 | -0.87 |
| August | 4,092 | 4,101 | 4,097 | -2 | -0.05 | 4,062 | 0 | 0.00 | -35 | -0.84 |
| September | 4,067 | 4,075 | 4,071 | -25 | -0.61 | 4,062 | 0 | 0.00 | -9 | -0.22 |
| October | 4,031 | 4,038 | 4,035 | -36 | -0.89 | 4,040 | -22 | -0.54 | 6 | 0.14 |
| November | 3,994 | 4,005 | 4,000 | -37 | -0.92 | 3,995 | -45 | -1.11 | -5 | -0.11 |
| December | 4,003 | 4,013 | 4,008 | 9 | 0.23 | 3,995 | 0 | 0.00 | -13 | -0.32 |
| **2014** | | | | | | | | | | |
| January | 3,995 | 4,003 | 3,999 | -8 | -0.20 | 3,995 | 0 | 0.00 | -4 | -0.10 |
| February | 3,981 | 3,989 | 3,985 | -14 | -0.35 | 3,980 | -15 | -0.38 | -5 | -0.13 |
| March | 3,995 | 4,002 | 3,999 | 14 | 0.35 | 4,015 | 35 | 0.88 | 17 | 0.41 |
| April | 4,012 | 4,022 | 4,017 | 17 | 0.43 | 4,015 | 0 | 0.00 | -2 | -0.05 |
| May | 4,043 | 4,053 | 4,048 | 31 | 0.77 | 4,032 | 17 | 0.42 | -16 | -0.40 |
| June | 4,047 | 4,053 | 4,050 | 4 | 0.10 | 4,040 | 8 | 0.20 | -10 | -0.25 |
| July | 4,054 | 4,063 | 4,059 | 7 | 0.17 | 4,050 | 10 | 0.25 | -9 | -0.21 |
| August | 4,074 | 4,083 | 4,079 | 20 | 0.49 | 4,065 | 15 | 0.37 | -14 | -0.33 |
| September | 4,087 | 4,096 | 4,092 | 13 | 0.32 | 4,085 | 20 | 0.49 | -7 | -0.16 |
| October | 4,074 | 4,080 | 4,077 | -13 | -0.32 | 4,076 | -9 | -0.22 | -1 | -0.02 |
| November | 4,055 | 4,062 | 4,059 | -19 | -0.47 | 4,063 | -13 | -0.32 | 5 | 0.11 |
| December | 4,064 | 4,073 | 4,069 | 9 | 0.22 | 4,075 | 12 | 0.30 | 7 | 0.16 |
| **2015** | | | | | | | | | | |
| January | 4,059 | 4,067 | 4,063 | -5 | -0.12 | 4,050 | -25 | -0.61 | -13 | -0.32 |
| February | 4,032 | 4,040 | 4,036 | -27 | -0.67 | 4,027 | -23 | -0.57 | -9 | -0.22 |
| March | 4,010 | 4,018 | 4,014 | -22 | -0.55 | 4,010 | -17 | -0.42 | -4 | -0.10 |
| April | 4,066 | 4,076 | 4,071 | 56 | 1.40 | 4,050 | 40 | 1.00 | -21 | -0.52 |
| May | 4,086 | 4,096 | 4,091 | 20 | 0.49 | 4,068 | 18 | 0.44 | -23 | -0.56 |
| June | 4,094 | 4,101 | 4,098 | 8 | 0.20 | 4,098 | 30 | 0.74 | 1 | 0.01 |
| July | 4,113 | 4,121 | 4,117 | 19 | 0.46 | 4,113 | 15 | 0.37 | -4 | -0.10 |
| August | 4,098 | 4,105 | 4,102 | -15 | -0.36 | 4,081 | -32 | -0.78 | -21 | -0.50 |
| September | 4,074 | 4,087 | 4,081 | -24 | -0.59 | 4,076 | -5 | -0.12 | -5 | -0.11 |
| October | 4,049 | 4,060 | 4,055 | -25 | -0.61 | 4,061 | -15 | -0.37 | 7 | 0.16 |
| November | 4,044 | 4,056 | 4,050 | -5 | -0.12 | 4,044 | -17 | -0.42 | -6 | -0.15 |
| December | 4,048 | 4,055 | 4,052 | 4 | 0.10 | 4,050 | 6 | 0.15 | -2 | -0.04 |
| **2016** | | | | | | | | | | |
| January | 4,037 | 4,045 | 4,041 | -11 | -0.27 | 4,037 | -13 | -0.32 | -4 | -0.10 |
| February | 4,010 | 4,016 | 4,013 | -27 | -0.67 | 4,008 | -29 | -0.72 | -5 | -0.12 |
| March | 4,010 | 4,018 | 4,014 | 0 | 0.00 | 4,006 | -2 | -0.05 | -8 | -0.20 |
| April | 4,061 | 4,073 | 4,067 | 51 | 1.27 | 4,060 | 54 | 1.35 | -7 | -0.17 |
| May | 4,082 | 4,091 | 4,087 | 21 | 0.52 | 4,085 | 25 | 0.62 | -2 | -0.04 |
| June | 4,081 | 4,091 | 4,086 | -1 | -0.02 | 4,084 | -1 | -0.02 | -2 | -0.05 |
| July | 4,094 | 4,103 | 4,099 | 13 | 0.32 | 4,097 | 13 | 0.32 | -2 | -0.04 |
| August | 4,096 | 4,106 | 4,101 | 2 | 0.05 | 4,096 | -1 | -0.02 | -5 | -0.12 |

តារាង: **អត្រាការប្រាក់លើប្រាក់បញ្ញើ** (ខែ កក្កដា ឆ្នាំ២០១៦)

| ល.រ | ឈ្មោះធនាគារ | ប្រាក់បញ្ញើជារៀល (%) | | | | | ប្រាក់បញ្ញើជាដុល្លារអាមេរិក (%) | | | | | ប្រាក់បញ្ញើជារូបិយប័ណ្ណផ្សេងៗ (%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សំចៃ | មានកាលកំណត់ | | | | សំចៃ | មានកាលកំណត់ | | | | សំចៃ | មានកាលកំណត់ | | | |
| | | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ ខែ | ៦ ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| ១ | អេស៊ីលីដា | ១,២៥ | ៣,០០ | ៥,០០ | ៦,០០ | ៧,០០ | ០,៥០ | ១,៥០ | ២,៥០ | ៣,៧៥ | ៥,០០ | ០,១៥ | ០,៥០ | ១,៥០ | ២,២៥ | ៣,២៥ |
| ២ | កម្ពុជាសាធារណៈ | ០,៥០ | ១,០០ | ១,២៥ | ១,៧៥ | ២,៥០ | ០,៥០ | ១,៥០ | ២,២៥ | ៣,២៥ | ៤,០០ | ០,៥០ | | | | |
| ៣ | កាណាឌីយ៉ា | ២,០០ | | ៥,០០ | ៦,០០ | ៧,០០ | ០,៧៥ | ២,០០ | ២,៥០ | ៣,៥០ | ៤,៧៥ | ០,២៥ | ១,០០ | ១,៥០ | ២,០០ | ២,៥០ |
| ៤ | អេអ៊ិនហ្សេតរូយ៉ាល់ | | ៣,២៥ | ៣,៥០ | ៤,០០ | ៥,៥០ | ១,០០ | ០,៨០ | ១,១០ | ២,១០ | ៣,០០ | | | | | |
| ៥ | ពាណិជ្ជកម្មក្រៅប្រទេស | ១,៥០ | ៣,០០ | ៥,០០ | ៦,០០ | ៧,០០ | ០,៧៥ | ១,៥០ | ២,៥០ | ៣,៧៥ | ៥,០០ | | | | | |
| ៦ | អភិវឌ្ឍន៍និងវិនិ. | | ៣,៥០ | ៤,៦០ | ៥,៥៥ | ៦,៥០ | ០,៧៥ | ២,២៥ | ៣,០០ | ៤,២៥ | ៥,៥០ | | | | | |
| ៧ | មេយប៊ែង | | | | | | ១,៥០ | ២,៥០ | ៣,០០ | ៤,០០ | ៥,០០ | | | | | |
| ៨ | ធនាគារវឌ្ឍនៈ | ០,៥០ | ១,៥០ | ២,០០ | ៣,០០ | ៣,៥០ | ០,៥០ | ១,៥០ | ២,០០ | ៣,០០ | ៣,៥០ | | | | | |
| ៩ | សហពាណិជ្ជ | ០,៧៥ | | | | | ១,០០ | | ២,០០ | ៣,០០ | ៣,៧៥ | | | | | |
| ១០ | វឌ្ឍនៈអាស៊ី | ០,៧៥ | | | | | ០,៧៥ | ២,២៥ | ៣,២៥ | ៤,២៥ | ៥,២៥ | | | | | |
| ១១ | កម្ពុជាពាណិជ្ជ | ០,៣៥ | | ១,៥០ | ១,៥០ | ១,៥០ | ០,៣៥ | | ១,៥០ | ១,៥០ | ១,៥០ | ០,៣៥ | | ១,៥០ | ១,៥០ | ១,៥០ |
| ១២ | ពាណិជ្ជកម្មទី១ | | | | | | | | | | | | | | | |
| ១៣ | ក្រុងថៃមហាជន | | | | | | ០,១០ | | ០,៥០ | ០,៧៥ | ១,០០ | | | | | |
| ១៤ | កម្ពុជាអាស៊ី | | | | | | ២,០០ | ២,៥០ | ៣,៨០ | ៤,៨០ | ៥,៨០ | | | | | |
| ១៥ | មេគង្គកម្ពុជា | ៣,៧៥ | | | | ៨,០០ | ២,០០ | | ២,៧៥ | ៣,៥០ | ៤,០០ | | | | | |
| ១៦ | ធនាគារកាថេ | | | | | | ០,៥០ | | ២,៥០ | ៣,០០ | ៤,០០ | | | | | |
| ១៧ | ឥណ្ឌា | | | | | | ០,៧៥ | ១,០០ | ២,២៥ | ៣,០០ | ៤,០០ | | | | | |
| ១៨ | ម៉ារូហាន់ | ៤,០០ | ៥,០០ | ៦,០០ | ៧,០០ | ៩,៥០ | ៤,០០ | ៤,៥០ | ៥,០០ | ៥,៥០ | ៧,៥០ | ៤,០០ | ៤,៥០ | ៥,០០ | ៥,៥០ | ៧,៥០ |
| ១៩ | ប៊ូយ៉ុងខ្មែរ | ១,០០ | ៣,០០ | ៤,០០ | ៥,០០ | ៦,០០ | ០,៥០ | ១,៥០ | ២,៥០ | ៣,០០ | ៣,៥០ | | | | | |
| ២០ | ស៊ីនហានខ្មែរ | | | | | | ០,២៥ | ១,២៥ | ២,២៥ | ៣,៥០ | ៤,២៥ | | | | | |
| ២១ | គូកមិនកម្ពុជា | ០,៧០ | ១,៧០ | ២,៥០ | ៣,២០ | ៣,៦០ | ០,៥០ | ១,២០ | ២,០០ | ២,៧០ | ៣,១០ | | | | | |
| ២២ | អអេជប៊ី | ១,៥០ | ៣,៥០ | ៤,០០ | ៥,០០ | ៦,០០ | ១,០០ | ២,០០ | ២,៥០ | ៣,៥០ | ៤,៧៥ | | | | | |
| ២៣ | ហ្វុងឌីប៊ីអេស | | | | | | ១,០០ | ២,២៥ | ៣,០០ | ៤,២៥ | ៥,៥០ | | | | | |
| ២៤ | ភ្នំពេញ ពាណិជ្ជ | | | | | | ២,២០ | ២,៥០ | ៤,០០ | ៥,០០ | ៦,០០ | | | | | |
| ២៥ | សាខម | ០,៥០ | ២,២៥ | ៣,០០ | ៣,៥០ | ៥,២៥ | ០,៥០ | ២,២៥ | ៣,០០ | ៣,៥០ | ៥,២៥ | | | | | |
| ២៦ | ស៊ីអាយអិមប៊ី | | | | | | ១,៥០ | ១,៥០ | ២,២៥ | ៣,២៥ | ៤,០០ | | | | | |
| ២៧ | អាគ្រី | ១,២៥ | ៣,៥០ | ៤,២៥ | ៤,២៥ | ៥,២៥ | ០,៥០ | ១,៥០ | ៣,០០ | ៣,២៥ | ៤,២០ | | | | | |
| ២៨ | ចិន | ០,១៣ | ០,១៣ | ០,១៣ | ០,១៣ | ០,១៣ | ០,៥០ | ១,២៥ | ២,២៥ | ២,៧៥ | ៣,២៥ | ០,៣៥ | ១,៥០ | ៣,២៥ | ៣,១៥ | ៣,០០ |
| ២៩ | មេហ្គា | | | | | | ០,០២ | ០,៤០ | ០,៦០ | ០,៨០ | ១,១០ | | | | | |
| ៣០ | អាយស៊ីប៊ីស៊ី | | | | | | ០,៥០ | ១,៥០ | ២,២៥ | ៣,០០ | ៣,៥០ | | | ២,៩៥ | | |
| ៣១ | អ៊ុមប៊ី គីអិលស៊ី | ០,៧៥ | ៣,៥០ | ៤,៥០ | ៥,០០ | ៦០០ | ០,៥០ | ២,៧៥ | ៣,២០ | ៤,២០ | ៥,០០ | | | | | |
| ៣២ | អេសហេជប៊ី | ១,០០ | ២,៨៥ | ៣,៧៥ | ៥,៤៥ | ៥,៥០ | ១,០០ | ៣,៧៥ | ៤,៧៥ | ៤,៨៥ | ៥,៧៥ | | | | | |
| ៣៣ | តៃវ៉ាន់ខូអបរេធីវ | | | | | | ០,១៣ | ០,៣០ | ០,៣៥ | ០,៧០ | ១,១០ | | | | | |
| ៣៤ | ហុងលីអ៊ុង | ១,០០ | | | | | ០,៧៥ | ១,៧៥ | ២,៥០ | ៣,៧៥ | ៤,៧៥ | | | | | |
| ៣៥ | ប្រៃសណីយ៍ | ២,០០ | ៣០០ | ៤,០០ | ៥,០០ | ៧,០០ | ១,២៥ | ២,០០ | ៣,០០ | ៤,០០ | ៦,០០ | ២,០០ | ៣,០០ | ៤,០០ | ៥,០០ | ៧,០០ |
| ៣៦ | ធនាគារបាងកក | ០,៥០ | ១,០០ | ២,០០ | ៣,០០ | ៤,០០ | ០,៥០ | ១,០០ | ២,០០ | ៣,០០ | ៤,០០ | ០,១៣ | | ០,២៥ | ០,៥០ | ០,៧៥ |
| ៣៧ | អភិវឌ្ឍន៍ជនបទ | ១,៥០ | ៣,៥០ | ៤,០០ | ៥,០០ | ៦,០០ | ១,០០ | ៣,០០ | ៣៥០ | ៤,០០ | ៥,០០ | | | | | |
| ៣៨ | ខេមខូ លីមីតធីត | | | | | | | | | | | | | | | |
| ៣៩ | តីអេចអែសអឹមអ៊ី | | | | | | | | | | | | | | | |
| ៤០ | វិនិយោគទីមួយ | | | | | | | | | | | | | | | |
| ៤១ | អានកូ | | | | | | | | | | | | | | | |
| ៤២ | តូម៉ាតូ | | | | | | | | | | | | | | | |
| ៤៣ | អង្គរ កាពីតាល | | | | | | | | | | | | | | | |
| ៤៤ | ខេមកាប់គីថល | | | | | | | | | | | | | | | |
| ៤៥ | ឌីហ្វ | | | | | | | | | | | | | | | |
| ៤៦ | អកស៍ឡី | | | | | | | | | | | | | | | |
| ៤៧ | ធនាគារឯកទេសវីង | | | | | | | | | | | | | | | |
| ៤៨ | ធនាគារឯកទេសអ៊ីអន | | | | | | | | | | | | | | | |
| | **មធ្យមភាគ** | ១,២១ | ២,៦៨ | ៣,៥០ | ៤,២៧ | ៥,៣៧ | ០,៨៦ | ១,៨៦ | ២,៥៤ | ៣,៣៣ | ៤,២៤ | ០,៩៧ | ២,១០ | ២,៤៩ | ២,៨៤ | ៣,៦៤ |

Table: INTEREST RATE ON DEPOSITS ( in April, 2016)

| No. | NAME OF BANKS | Deposit in Riel (%) | | | | | Deposit in USD (%) | | | | | Deposit in Other Foreign Currency (%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | Saving | Fixed | | | | Saving | Fixed | | | | Saving | Fixed | | | |
| | | | 1M. | 3M. | 6M. | 12M. | | 1M. | 3M. | 6M. | 12M. | | 1M. | 3M. | 6M. | 12M. |
| 1 | ACLEDA | 1.25 | 3.00 | 5.00 | 6.00 | 7.00 | 0.50 | 1.50 | 2.50 | 3.75 | 5.00 | 0.15 | 0.50 | 1.50 | 2.25 | 3.35 |
| 2 | Cambodian Public | 0.50 | 1.00 | 1.25 | 1.75 | 2.50 | 0.50 | 1.50 | 2.25 | 3.25 | 4.00 | 0.50 | | | | |
| 3 | Canadia Bank Ltd. | 2.00 | | 5.00 | 6.00 | 7.00 | 0.75 | 2.00 | 2.50 | 3.50 | 4.75 | 0.25 | 1.00 | 1.50 | 2.00 | 2.50 |
| 4 | ANZ Royal | | 3.25 | 3.50 | 4.00 | 5.50 | 1.00 | 0.90 | 1.10 | 2.10 | 3.00 | | | | | |
| 5 | Foreign Trade | 1.50 | 3.00 | 5.00 | 6.00 | 7.00 | 0.75 | 1.50 | 2.50 | 3.75 | 5.00 | | | | | |
| 6 | Investment & Develop | | 3.50 | 4.60 | 5.55 | 6.50 | ០.75 | 2.25 | 3.00 | 4.25 | 5.50 | | | | | |
| 7 | May Bank | | | | | | 0.50 | 2.50 | 3.00 | 4.00 | 5.00 | | | | | |
| 8 | Vattanac Bank | 0.50 | 1.50 | 2.00 | 3.00 | 3.50 | 0.50 | 1.50 | 2.00 | 3.00 | 3.50 | | | | | |
| 9 | Union Commercial | 0.75 | | | | | 1.00 | | 2.00 | 3.00 | 3.75 | | | | | |
| 10 | Advanced Bank of Asia | 0.75 | | | | | 0.75 | 2.50 | 3.25 | 4.25 | 5.25 | | | | | |
| 11 | CambodianCommercial | 0.35 | | 1.50 | 1.50 | 1.50 | 0.35 | | 1.50 | 1.50 | 1.50 | 0.35 | | 1.50 | 1.50 | 1.50 |
| 12 | First Commercial | | | | | | | | | | | | | | | |
| 13 | Krung Thai | | | | | | 0.10 | | 0.50 | 0.75 | 1.00 | | | | | |
| 14 | Cambodia Asia | | | | | | 2.00 | 2.50 | 3.80 | 4.80 | 5.80 | | | | | |
| 15 | Cambodia Mekong | 3.75 | | | | 8.00 | 2.00 | | 2.75 | 3.50 | 4.00 | | | | | |
| 16 | Cathay United | | | | | | 0.50 | | 2.50 | 3.00 | 4.00 | | | | | |
| 17 | Bank of India | | | | | | 0.75 | 1.00 | 2.25 | 3.00 | 4.00 | | | | | |
| 18 | Maruhan Japan | 4.00 | 5.00 | 6.00 | 7.00 | 9.50 | 4.00 | 4.50 | 5.00 | 5.50 | 7.50 | 4.00 | 4.50 | 5.00 | 5.50 | 7.50 |
| 19 | Booyoung Khmer | 1.00 | 3.00 | 4.00 | 5.00 | 6.00 | 0.50 | 1.50 | 2.50 | 3.00 | 3.50 | | | | | |
| 20 | Shinhan Khmer | | | | | | 0.25 | 1.25 | 2.25 | 3.50 | 4.25 | | | | | |
| 21 | KOOKMIN | 0.70 | 1.70 | 2.50 | 3.20 | 3.60 | 0.50 | 1.20 | 2.00 | 2.70 | 3.10 | | | | | |
| 22 | RHB Indochina | 1.50 | 3.50 | 4.00 | 5.00 | 6.00 | 1.00 | 2.00 | 2.50 | 3.50 | 4.75 | | | | | |
| 23 | Hwang DBS | | | | | | 1.00 | 2.25 | 3.00 | 4.25 | 5.50 | | | | | |
| 24 | Phnom Penh | | | | | | 2.20 | 2.50 | 4.00 | 5.00 | 6.00 | | | | | |
| 25 | SACOMBANK | 0.50 | 2.25 | 3.00 | 3.50 | 5.25 | 0.50 | 2.25 | 3.00 | 3.50 | 5.25 | | | | | |
| 26 | CIMB Bank Plc | | | | | | 1.50 | 1.50 | 2.25 | 3.25 | 4.00 | | | | | |
| 27 | AGRI Bank | 1.25 | 3.50 | 4.25 | 4.25 | 5.25 | 0.50 | 1.50 | 3.00 | 3.25 | 4.20 | | | | | |
| 28 | Bank of China | 0.13 | 0.13 | 0.13 | 0.13 | 0.13 | 0.50 | 1.25 | 2.25 | 2.75 | 3.25 | 0.35 | 1.50 | 3.25 | 3.15 | 3.00 |
| 29 | MEGA International | | | | | | 0.02 | 0.40 | 0.60 | 0.80 | 1.10 | | | | | |
| 30 | ICBC Limited | | | | | | 0.50 | 1.50 | 2.25 | 3.00 | 3.50 | | | 2.95 | | |
| 31 | MB Bank Plc. | 0.75 | 3.50 | 4.50 | 5.00 | 6.00 | 0.50 | 2.75 | 3.20 | 4.20 | 5.00 | | | | | |
| 32 | SHB Plc. | 1.00 | 2.85 | 3.75 | 5.45 | 5.50 | 1.00 | 3.75 | 4.75 | 4.85 | 5.75 | | | | | |
| 33 | Taiwan Cooperative | | | | | | 0.13 | 0.30 | 0.35 | 0.70 | 1.10 | | | | | |
| 34 | Hong Leong | 1.00 | | | | | 0.75 | 1.75 | 2.50 | 3.75 | 4.75 | | | | | |
| 35 | Cambodian Post | 2.00 | 3.00 | 4.00 | 5.00 | 7.00 | 1.25 | 2.00 | 3.00 | 4.00 | 6.00 | 2.00 | 3.00 | 4.00 | 5.00 | 7.00 |
| 36 | Bangkok Bank | 0.50 | 1.00 | 2.00 | 3.00 | 4.00 | 0.50 | 1.00 | 2.00 | 3.00 | 4.00 | 0.13 | | 0.25 | 0.50 | 0.75 |
| 37 | Rural Development | 1.50 | 3.50 | 4.00 | 5.00 | 6.00 | 1.00 | 3.00 | 3.50 | 4.00 | 5.00 | | | | | |
| 38 | Camko Bank Limited. | | | | | | | | | | | | | | | |
| 39 | PHSME Specialized | | | | | | | | | | | | | | | |
| 40 | First Investment | | | | | | | | | | | | | | | |
| 41 | ANCO Specialized | | | | | | | | | | | | | | | |
| 42 | Tomato Specialized | | | | | | | | | | | | | | | |
| 43 | Angkor Capital | | | | | | | | | | | | | | | |
| 44 | CAM Capital | | | | | | | | | | | | | | | |
| 45 | Chief Specialized | | | | | | | | | | | | | | | |
| 46 | Oxley Worldbridge | | | | | | | | | | | | | | | |
| 47 | Wing Specialize Bank | | | | | | | | | | | | | | | |
| 48 | AEON Specialized Bank | | | | | | | | | | | | | | | |
| **Average** | | **1.21** | **1.68** | **3.50** | **4.27** | **5.37** | **0.86** | **1.86** | **2.54** | **3.33** | **4.24** | **0.97** | **2.10** | **2.49** | **2.84** | **3.64** |

## តារាង: **អត្រាការប្រាក់លើប្រាក់កម្ចី** (ខែកក្កដា ឆ្នាំ២០១៦)

| ល.រ | ឈ្មោះធនាគារ | ខ្ចីជារៀល (%) | | | | ខ្ចីជាដុល្លារអាមេរិក (%) | | | | ខ្ចីជារូបិយប័ណ្ណផ្សេងៗ (%) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ ខែ | ៣ ខែ | ៦ ខែ | ១២ខែ | ១ ខែ | ៣ ខែ | ៦ ខែ | ១២ខែ | ១ខែ | ៣ខែ | ៦ ខែ | ១២ខែ |
| ១ | អេស៊ីលីដា | | | | ១៥,៦០ | | | | ១០,០០ | | | | ១៥,៦០ |
| ២ | កម្ពុជាសាធារណៈ | | | | | ៨,៧៥ | ៨,៧៥ | ៨,៧៥ | ៨,៧៥ | | | | |
| ៣ | កាណាឌីយ៉ាចំកាត់ | | | | | | | | ១៣,២០ | | | | |
| ៤ | អេអ៊ិនហ្សេតរូយ៉ាល់ | | | | | | | | ៦,៤៨ | | | | |
| ៥ | ពាណិជ្ជកម្មក្រៅប្រទេស | ១៨,០០ | ១៨,០០ | ១៨,០០ | ១៨,០០ | ១៨,០០ | ១៨,០០ | ១៨,០០ | ១៨,០០ | | | | |
| ៦ | អភិវឌ្ឍន៍ និងវិនិយោគ | | | | | ១០,០០ | ១០,០០ | ១០,០០ | ១០,០០ | | | | |
| ៧ | មេយប៊ែង | | | | | | | | ១២,២៥ | | | | |
| ៨ | ធនាគារវឌ្ឍនៈ | | | | | ១៣,២០ | ១៣,២០ | ១៣,២០ | ១៣,២០ | | | | |
| ៩ | សហពាណិជ្ជ ក.អ | | | | | ១៥,០០ | ១៥,០០ | ១៥,០០ | ១៥,០០ | | | | |
| ១០ | វឌ្ឍនៈអាស៊ី ចំកាត់ | | | | | ៨,៤៦ | ៨,៩៨ | ៩,១៨ | ១០,០១ | | | | |
| ១១ | កម្ពុជាពាណិជ្ជ ចំកាត់ | | | | | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ |
| ១២ | ពាណិជ្ជកម្មទី១ | | | | | | | | ២០,៤០ | | | | |
| ១៣ | ក្រុងថៃមហាជន | | | | | | | | ៦,០០ | | | | |
| ១៤ | កម្ពុជាអាស៊ី ចំកាត់ | | | | | | | | ១២,០០ | | | | |
| ១៥ | មេគង្គកម្ពុជា | | | | | | | | ១២,០០ | | | | |
| ១៦ | ធនាគារកាថេ | | | | | | ៦,១៣ | ១៥,០០ | ១២,០០ | | | | |
| ១៧ | ឥណ្ឌូ សាខាភ្នំពេញ | | | | | | | | ១២,០០ | | | | |
| ១៨ | ម៉ារូហាន់ | ២១,០០ | ២១,០០ | ២០,៤០ | ២០,៤០ | ២១,០០ | ២១,០០ | ១៥,៦០ | ១៥,៦០ | ២១,០០ | ២១,០០ | ២០,៤០ | ២០,៤០ |
| ១៩ | ប៊ូយ៉ុងខ្មែរ | | | | | | | | ៩,០០ | | | | |
| ២០ | ស៊ីនហានខ្មែរ | | | | | ១៥,០០ | ១៥,០០ | ១៥,០០ | ១៥,០០ | | | | |
| ២១ | គូកមិនកម្ពុជា ភីអិលស៊ី | | | | | ១៤,០០ | ១៤,០០ | ១៤,០០ | ១៤,០០ | | | | |
| ២២ | អ អេជ ប៊ី ឥណ្ឌូឆៃណា | | | | | | | | ១៤,០០ | | | | |
| ២៣ | ហុងឌីប៊ីអេស | | | | | | | | ១២,០០ | | | | |
| ២៤ | ភ្នំពេញ ពាណិជ្ជ | | | | | | | | ១៨,០០ | | | | |
| ២៥ | សាខម | | | | | ១៤,៤០ | ១៤,៤០ | ១៤,៤០ | ១៤,៤០ | | | | |
| ២៦ | ស៊ីអាយអិមប៊ី ភីអិលស៊ី | | | | | ១២,០០ | ១២,០០ | ១២,០០ | ១២,០០ | | | | |
| ២៧ | អាហ្គ្រី សាខាកម្ពុជា | ១៦,៨០ | ១៦,៨០ | ១៦,៨០ | ១៦,៨០ | ១០,០០ | ១០,០០ | ១០,០០ | ១០,០០ | | | | |
| ២៨ | ចិន សាខាភ្នំពេញ | | | | | | | | ១១,០០ | | | | |
| ២៩ | មេហ្គាអ៊ិនធើណេសិនណល | | | | | | | | ៨,០០ | | | | |
| ៣០ | អាយស៊ីប៊ីស៊ី ចំកាត់ | | | | | | | | ៧,៥០ | | | | ៥,១០ |
| ៣១ | អ៊ឹមប៊ី ភីអិលស៊ី | | | | | ១០,២៥ | ១០,២៥ | ១០,២៥ | ១០,២៥ | | | | |
| ៣២ | អេសហេជប៊ី ភីអិលស៊ី | | | | | | | | ៨,០៣ | | | | |
| ៣៣ | តៃវ៉ាន់ខូអបរេធីវ | | | | | | | | ១១,០០ | | | | |
| ៣៤ | ហុងលីអ៊ុង ភីអិលស៊ី | | | | | | | | ១០,០០ | | | | |
| ៣៥ | ប្រៃសណីយ៍ ភីអិលស៊ី | | | ២៨,៨០ | ៣៦,០០ | | | ៣០,០០ | ៣១,២០ | | | ៣០,០០ | ៣០,០០ |
| ៣៦ | ធនាគារបាងកក | | | | | ៦,៥០ | ៦,៥០ | ៦,៥០ | ៩,០០ | | | | |
| ៣៧ | អភិវឌ្ឍន៍ជនបទ | | | | ១៤,០០ | | | | ៩,០០ | | | | |
| ៣៨ | ខេមខូ លីមីតធីត | | | | | | | | ២០,០០ | | | | |
| ៣៩ | ភីអេចអេសអឹមអ៊ី | | | | | | | | ១៨,០០ | | | | |
| ៤០ | វិនិយោគទីមួយ | | | | | | | | ២០,៤០ | | | | |
| ៤១ | អានកូ | | | | | | | | ២២,០០ | | | | |
| ៤២ | តូម៉ាតូ | | | | | | | | ១០,០០ | | | | |
| ៤៣ | អង្គរ កាពីតាល | | | | | | | ៣០,០០ | ១៥,៨៨ | | | | |
| ៤៤ | ខេមកាប់ភីថល | | | | | | | | ២៤,០០ | | | | |
| ៤៥ | ធីហ្វ | | | | | | ១៨,០០ | ១៨,០០ | ១៨,០០ | | | | |
| ៤៦ | អកស់ឡី | | | | | | | | ៩,៨២ | | | | |
| ៤៧ | ធនាគារឯកទេសវីង | | | | | | | | | | | | |
| ៤៨ | ធនាគារឯកទេសអ៊ីអន | | | | | | | | | | | | |
| មធ្យមភាគ | | ១៨,៦០ | ១៨,៦០ | ២១,០០ | ២០,១៣ | ១២,៦០ | ១២,៥៧ | ១៤,៥៨ | ១៣,២៣ | ១៥,៧៥ | ១៥,៧៥ | ២០,៣០ | ១៦,៣២ |

## Table: INTEREST RATE ON LOAN (in July 2016)

| No. | NAME OF BANKS | Loan in Riel (%) | | | | Loan in USD (%) | | | | Loan in Other Foreign Currency (%) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | 1 M. | 3 M. | 6 M. | 12 M. | 1 M. | 3 M. | 6 M. | 12 M. | 1 M. | 3 M. | 6 M. | 12 M. |
| 1 | ACLEDA Bank | | | | 15.60 | | | | 10.00 | | | | 15.60 |
| 2 | Cambodian Public | | | | | 8.75 | 8.75 | 8.75 | 8.75 | | | | |
| 3 | Canadia Bank Ltd. | | | | | | | | 13.20 | | | | |
| 4 | ANZ Royal Cambodia | | | | | | | | 6.48 | | | | |
| 5 | Foreign Trade Bank | 18.00 | 18.00 | 18.00 | 18.00 | 18.00 | 18.00 | 18.00 | 18.00 | | | | |
| 6 | Investment & Development | | | | | 10.00 | 10.00 | 10.00 | 10.00 | | | | |
| 7 | May Bank | | | | | | | | 12.25 | | | | |
| 8 | Vattanac Bank | | | | | 13.20 | 13.20 | 13.20 | 13.20 | | | | |
| 9 | Union Commercial Bank Plc. | | | | | 15.00 | 15.00 | 15.00 | 15.00 | | | | |
| 10 | Advanced Bank of Asia Ltd. | | | | | 4.46 | 8.98 | 9.18 | 10.01 | | | | |
| 11 | Cambodian Commercial | | | | | 10.50 | 10.50 | 10.50 | 10.50 | 10.50 | 10.50 | 10.50 | 10.50 |
| 12 | First Commercial Bank | | | | | | | | 20.40 | | | | |
| 13 | Krung Thai Bank Public | | | | | | | | 6.00 | | | | 10.00 |
| 14 | Cambodia Asia Bank Ltd. | | | | | | | | 12.00 | | | | |
| 15 | Cambodia Mekong Bank Ltd | | | | | | | | 12.00 | | | | |
| 16 | Cathay United Bank | | | | | | 6.13 | | 12.00 | | | | |
| 17 | Bank of India | | | | | | | | 12.00 | 33.60 | 32.40 | 30.00 | 34.80 |
| 18 | Maruhan Japan Bank Plc. | 21.00 | 21.00 | 20.40 | 20.40 | 21.00 | 21.00 | 15.60 | 15.60 | | | | |
| 19 | Booyoung Khmer Bank | | | | | | | | 9.00 | | | | |
| 20 | Shinhan Khmer Bank | | | | | 15.00 | 15.00 | 15.00 | 15.00 | | | | |
| 21 | KOOKMIN | | | | | 14.00 | 14.00 | 14.00 | 14.00 | | | | |
| 22 | OSK Indochina Bank | | | | | | | | 14.00 | | | | |
| 23 | Hwang DBS | | | | | | | | 12.00 | | | | |
| 24 | Commercial Bank | | | | | | | | 18.00 | | | | |
| 25 | SACOMBANK | | | | | 14.00 | 14.00 | 14.00 | 14.00 | | | | |
| 26 | CIMB Bank Plc | | | | | 12.00 | 12.00 | 12.00 | 12.00 | | | | |
| 27 | AGRI Bank | 16.80 | 16.80 | 16.80 | 16.80 | 10.00 | 10.00 | 10.00 | 10.00 | | | | |
| 28 | Bank of China | | | | | | | | 11.00 | | | | |
| 29 | MEGA | | | | | | | | 8.00 | | | | |
| 30 | ICBC Limited | | | | | | | | 7.50 | | 3.50 | | 5.10 |
| 31 | MB Bank Plc. | | | | | 10.25 | 10.25 | 10.25 | 10.25 | | | | |
| 32 | SHB Plc. | | | | | | | | 8.03 | | | | |
| 33 | Taiwan Cooperative | | | | | | | | 11.00 | | | | |
